ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- មជ្ឈមណ្ឌលឯកសារកម្ពុជាពង្រីកការិយាល័យផ្ដល់ព័ត៌មានសាធារណៈ
- អាស៊ានត្រូវតែមានគោលជំហររួបរួម ប្រកបដោយឥទ្ធិពល ចំពោះសិទ្ធិក្នុងការរស់រានមានជីវិត និងសិទ្ធិមនុស្ស
- ប្រវត្តិឃុំគគីរ តាមរយៈវេទិកាប្រវត្តិសាស្ត្រគ្រួសារ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៧២ ខែសីហា ឆ្នាំ២០២២

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៧២ ខែសីហា ឆ្នាំ២០២២



នារីនៅកងសិល្បៈក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា


### សំបុត្រ

◆ មជ្ឈមណ្ឌលឯកសារកម្ពុជាពង្រីកការិយាល័យផ្ដល់ព័ត៌មានសាធារណៈ ..................... ១

◆ អាស៊ានត្រូវតែមានគោលជំហររួបរួម...... ៥

### ផ្នែកឯកសារ

◆ ឆេង កយ ហៅ សារ៉ាត ប្រធានមន្ទីរ ........ ៧

◆ ស ខន៖ អ្នកយាមឃ្លាំងអង្ករនៅមន្ទីរ .... ១០

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ជួបប្រជុំពិភាក្សាជាមួយអាជ្ញាធរស្រុកកំពង់សៀម ...១៣

◆ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះធ្វូ.. ១៥

◆ ការឆ្លុះបញ្ចាំងអំពីតំបន់ទេសចរណ៍ប្រវត្តិ.. ១៧

◆ ប្រវត្តិឃុំគគីរ តាមរយៈវេទិកា............ ១៩

◆ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើប្រធានក្រុម.. ២២

◆ យ៉ាន់រ៉ាន់៖ អ្នកគ្រប់គ្រងកន្លែងធ្វើប្រហុក... ២៤

◆ គល់ សឿន៖ កងចល័តកម្លាំងទីមួយ..... ២៦

◆ ង៉ែត មោង្ស៖ អតីតទាហានកន្សែងស.... ២៨

◆ កើត ឈុន៖ អនុក្រុមនៅក្នុងរបបខ្មែរ .... ៣០

◆ លឹម អេង៖ អតីតកងនេសាទក្នុង........ ៣២

◆ សោម គង់៖ កងមនុស្សចាស់ ........... ៣៤

◆ ស៊ីង គីមស្រ៊ុន៖ អតីតកងចល័តវ័យ...... ៣៦

◆ ខ្ញុំខឹងប្រធានកងធ្វើបាបទើបសុំចូលធ្វើកង ... ៣៨

◆ ចាប គីមណា៖ កងនារីក្នុងរបបខ្មែរក្រហម ... ៤០

◆ ទេព សារឿន៖ កងចល័តនៅក្នុងរបប .. ៤២

◆ នួន នៅ៖ អតីតពេទ្យក្នុងរបបខ្មែរក្រហម ... ៤៤

### ផ្នែក វេទិកាពិភាក្សាសាធារណៈ

◆ យុវសិស្សចំនួន ៣០នាក់ នៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចូលរួមវេទិកា .......... ៤៧

◆ សិស្សមកពីវិទ្យាល័យចំនួន ៣ ក្នុងខេត្តត្បូងឃ្មុំ ទទួលការអប់រំស្ដីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ....... ៥១

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ **«ទួលពិឃាដ» (ត)**

៨. ជម្រៀសក្នុងជម្រៀសវប្បធម៌បញ្ច្រាសទិសនៃអង្គការបដិវត្តន៍............................ ៥៦


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥៣.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** ឆាំង យុ, ដាត ចាន់សុនិតា, ភា រស្មី, អេង វណ្ណីកា, អានម៉ា ហ្គារ៉េត ចូហាន់សេន, ហ៊ាន ពិសី, ឈុំ រ៉ា, សៀង កញ្ញា, មេក វិន, ថុន ស្រីពេជ្រ, រីម ស្រីស្រស់, ទូច វណ្ណេត, ង៉ាន់ វីន, សូ ហាន់, គាត ស្រីឡែន, វី ស៊ីថា និង ឡុង វង្សសមិទ្ធ

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លឹម អ៊ុភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# មជ្ឈមណ្ឌលឯកសារកម្ពុជាពង្រីកការិយាល័យផ្តល់ព័ត៌មានសាធារណៈ

ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា



ឯកអគ្គរដ្ឋទូតតួកគីប្រចាំប្រទេសកម្ពុជា អាយដា អ៊ុនលូ (Ayda Unlu) ទស្សនកិច្ចការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សកំព្រាមកពីអង្គការសុខសប្បាយ ទស្សនកិច្ចការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងក្រុមគ្រួសារកម្ពុជានីមួយៗ គិតចាប់ពីព្រះរាជវង្សានុវង្សនៃសម្តេចព្រះបរមរតនកោដ្ឋ និងសម្តេចម៉ែរហូតដល់ក្រុមគ្រួសារនៃកសិករក្រីក្រយ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់បានបាត់បង់ជីវិត ឬបាត់ដំណឹងសូន្យសុងនៅក្នុងអំឡុងរបបខ្មែរក្រហមដ៏ឃោរឃៅ។ ប្រជាជនប្រមាណជាងពីរលាននាក់ត្រូវបានសម្លាប់, បង្អត់អាហារ, ឬធ្វើការហួសកម្លាំងរហូតដល់បាត់បង់ជីវិត នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ ប្រជាជនជាច្រើនបានបាត់បង់ជីវិតនៅក្នុងអំឡុងពេលជាច្រើនឆ្នាំនៃសង្គ្រាម, អំពើប្រល័យពូជសាសន៍, អស្ថិរភាព និងទុរ្ភិក្ស។ កេរដំណែលនៃប្រវត្តិសាស្ត្ររបបនេះនៅតែដិតជាមជាមួយនឹងក្រុមគ្រួសារកម្ពុជាសព្វថ្ងៃ។ ប្រទេសកម្ពុជា គួបផ្សំបង្កើតឡើងដោយ



លោក ម៉ែន គឹមសួ ទស្សនកិច្ចការិយាល័យកណ្ដាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមគ្រួសារដែលខ្ទេចខ្ទាំដ៏ធំមួយ ហើយការធ្វើឲ្យជាសះស្បើយ ទាមទារនូវរយៈកាលជាច្រើនជំនាន់។ ទោះបីជាយ៉ាងណាក្តី ការធ្វើឲ្យសះស្បើយ មិនមែនជាដំណើរការអកម្មនោះទេ។ ការធ្វើឲ្យសះស្បើយគឺជាដំណើរការដ៏សកម្មមួយ ដែលទាមទារនូវភាពមិនងាយទ្រុឌទ្រោម ក៏ដូចជាការផ្លាស់ប្តូរ ហើយការផ្លាស់ប្តូរគឺពឹងផ្អែកទៅលើការសិក្សារៀនសូត្រ។

ដើម្បីជួយសម្រួលដល់ការទទួលបានព័ត៌មានប្រសើរជាងមុន និងដើម្បីពង្រឹងមធ្យោបាយក្នុងការអប់រំនិងការសិក្សាស្រាវជ្រាវ មជ្ឈមណ្ឌលឯកសារកម្ពុជាមានសេចក្តីសោមនស្សក្នុងការប្រកាសអំពីការពង្រីកការិយាល័យផ្តល់ព័ត៌មានសាធារណៈរបស់ខ្លួននៅតាមបណ្តាខេត្តចំនួនប្រាំបន្ថែមទៀត រួមជាមួយនឹងបណ្ណាល័យសម្តេចម៉ែនៃប្រទេសកម្ពុជា។ បុគ្គលគ្រប់រូបអាចចូលទៅប្រើប្រាស់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមជំហានៗនៅលើបណ្តាញឯកសារអនឡាញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬតាមរយៈការដាក់សំណើនិងអនុវត្តតាមបែបបទដែលបានចែងដូចខាងក្រោម។ អ្នកសិក្សាស្រាវជ្រាវកម្ពុជាម្នាក់ៗមានទំនួលខុសត្រូវចំពោះការផ្លាស់ប្តូររបស់កម្ពុជា ក្នុងកម្រិតជាបុគ្គល និងជាសមូហភាព។ តាមរយៈព័ត៌មាន, ការអប់រំ និងការសិក្សាស្រាវជ្រាវ យើងប្រាកដជាអាចសម្រេចបានការផ្តល់អំណាច, នវានុវត្តភាព និងការរីកចម្រើនក្នុងកម្រិតបុគ្គល និងជាតិជាក់ជាមិនខាន។

លោកឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ អេ, ហែលស្រ្ទេស ទីប្រឹក្សាខុទ្ទកាល័យព្រះមហាក្សត្រកម្ពុជាបានមានប្រសាសន៍ថា "បណ្ណាល័យ ដែលបង្កើតឡើងដើម្បីថ្វាយព្រះរាជកិត្តិយសជូនសម្តេចព្រះវររាជមាតាជាតិខ្មែរ គួរតែបើកទទួលស្វាគមន៍សាធារណជនជាពិសេសគឺប្រជាជនកម្ពុជាដែលមិនសូវមានធនធានពោលគឺអ្នកទាំងឡាយដែលពុំមានឱកាសទៅនិងសិក្សានៅឯបរទេស។ បណ្តុំឯកសារនៅក្នុងបណ្ណាល័យសម្តេចម៉ែដែលកម្រមួយគ្មានពីរ និងត្រូវតែចែកផ្សាយទៅកាន់អ្នកគ្រប់គ្នា"។



ការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ចម្ការដំឡូងមីនៅខាងមុខការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## បទបញ្ញត្តិសម្រាប់អ្នកសិក្សាស្រាវជ្រាវ ក្នុងការប្រើប្រាស់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬការិយាល័យព័ត៌មានសាធារណៈ

*ភ្ញៀវទាំងអស់ ដែលមកកាន់ការិយាល័យព័ត៌មានសាធារណៈនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ណាល័យ សម្តេចម៉ែ ត្រូវតែអនុវត្តតាមបទបញ្ញត្តិចែងដូចខាងក្រោម៖*

*រៀងរាល់ទស្សនកិច្ចនីមួយៗ ត្រូវចំណាយពេលយ៉ាងហោចណាស់ពីរថ្ងៃមុន អ្នកសិក្សាស្រាវជ្រាវ ឬអ្នកអានឯកសារ ត្រូវតែបំពេញពាក្យស្នើសុំជាអ្នកសិក្សាស្រាវជ្រាវ ឬអ្នកអានឯកសារ។ គោលបំណងនៃការសិក្សាស្រាវជ្រាវរួមជាមួយនឹងគម្រោង ឬសំណើស្រាវជ្រាវរបស់អ្នកសិក្សាស្រាវជ្រាវ ត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងពិនិត្យមើលពាក្យស្នើសុំ ព្រមទាំងផ្តល់យោបល់ដល់អ្នកដាក់ពាក្យថាតើពាក្យស្នើសុំរបស់អ្នកទាំងនោះត្រូវបានយល់ស្របតាមដែរឬទេ។*

*ពេលវេលាបើកដំណើរការ៖ ការិយាល័យព័ត៌មានសាធារណៈ បើកពីម៉ោង៨ព្រឹករហូតដល់ម៉ោង៥ល្ងាច រៀងរាល់ថ្ងៃធ្វើការ។ ការិយាល័យនេះ នឹងបិទសម្រាកចាប់ពីពេលថ្ងៃត្រង់រហូតដល់ម៉ោង១និង៣០នាទីរសៀល នៅរៀងរាល់ថ្ងៃធ្វើការ។ ការិយាល័យនេះក៏នឹងបិទរៀងរាល់ថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកជាតិនានា។*

*កាបូបស្ពាយ និងសម្ភារផ្ទាល់ខ្លួនទាំងអស់ ត្រូវតែរក្សាទុកនៅក្នុងទូសម្ភារដែលផ្តល់ឲ្យនៅខាងមុខច្រកចូល។ ការិយាល័យព័ត៌មានសាធារណៈ មិនទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតលើសម្ភារផ្ទាល់ខ្លួនឡើយ។*

*ទូរស័ព្ទចល័ត ទូរស័ព្ទទំនើប និងឧបករណ៍បន្ទឺសំឡេងឬអាចថតសំឡេងទាំងអស់ មិនត្រូវបានអនុញ្ញាតឲ្យយកចូលក្នុងការិយាល័យព័ត៌មានសាធារណៈទេ។ បុគ្គលដែលប៉ុនប៉ងប្រើប្រាស់ឧបករណ៍ទាំងនេះ នឹងត្រូវទាមទារឲ្យចាកចេញពីការិយាល័យ។*

*យើងខ្ញុំសូមអរគុណចំពោះការសហការរបស់អ្នក ក្នុងការរក្សាបន្ទប់អានឲ្យមានភាពស្ងប់ស្ងាត់។*

*ការជក់បារី, ការហូបភេសជ្ជៈ ឬចំណី អាហារ ត្រូវហាមឃាត់ដាច់ខាតនៅក្នុងការិយាល័យព័ត៌មានសាធារណៈ និងទីតាំងតម្កល់ទុកឯកសារ។*

*បញ្ជីឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានរៀបចំជាស្រេចសម្រាប់ការស្វែងរកឯកសារនៅក្នុងបណ្ដុំផ្ទុកឯកសាររបស់យើង។ អ្នកសិក្សាស្រាវជ្រាវ ឬអ្នកអានឯកសារ គួរធ្វើជាបញ្ជីមួយរួមបញ្ចូលនូវលេខឯកសារដែលចង់ស្នើសុំ និងបង្ហាញបញ្ជីនោះទៅកាន់បុគ្គលិករបស់យើងដើម្បីអាចចូលទៅអានឯកសារទាំងនោះ។ មជ្ឈមណ្ឌលឯកសារកម្ពុជារក្សាសិទ្ធិក្នុងការកំណត់ចំនួនឯកសារដែលស្នើសុំ។*

*នៅពេលដែលកាន់ឯកសារដើម អ្នកសិក្សាស្រាវជ្រាវ ឬអ្នកអានឯកសារ ត្រូវតែរក្សាឯកសារទាំងនោះឲ្យស្អាតនិងតាមលំដាប់លំដោយ។ រាល់ឯកសារដែលបានផ្ដល់ឲ្យ ត្រូវតែប្រគល់ត្រឡប់មកកាន់បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាវិញ។ ការដកយកឯកសារទាំងមូលឬដោយផ្នែកចេញពីការិយាល័យព័ត៌មានសាធារណៈ គឺត្រូវហាមឃាត់ដាច់ខាត ហើយអ្នកប្រព្រឹត្តទង្វើនេះនឹងត្រូវដកហូតសិទ្ធិចូលប្រើប្រាស់ឯកសារ។*

*ការកត់ត្រា, ការដៅសញ្ញា ឬការសរសេរនៅលើឯកសារ គឺត្រូវហាមឃាត់ដាច់ខាត។*

*អ្នកសិក្សាស្រាវជ្រាវ ឬអ្នកអានឯកសារ អាចអាន និង/ឬ ស្នើសុំសិទ្ធិក្នុងការថតចម្លងឯកសារ។ មជ្ឈមណ្ឌលឯកសារកម្ពុជារក្សាសិទ្ធិក្នុងការប្រានបោលសំណើណាមួយ។*

*ការប្រើប្រាស់អ៊ីនធឺណេតអាចធ្វើឡើងទៅបាន ប្រសិនមានការស្នើសុំ ដើម្បីធ្វើការស្រាវជ្រាវស្វែងរកអនឡាញ។ សំណើសុំប្រើប្រាស់អ៊ីនធឺណេតនេះ ត្រូវតែរួមបញ្ចូលនៅក្នុងពាក្យស្នើសុំសម្រាប់អ្នកសិក្សាស្រាវជ្រាវឬអ្នកអានឯកសារ។ ដោយសារតែចំនួនកុំព្យូទ័រមានកម្រិត រយៈពេលនៃការប្រើប្រាស់អ៊ីនធឺណេត ត្រូវបានកំណត់ត្រឹម៣០នាទីសម្រាប់អ្នកប្រើប្រាស់ម្នាក់ក្នុងការទស្សនកិច្ចនីមួយៗ។ សូមពិនិត្យមើលតារាងតម្លៃក្នុងការប្រើប្រាស់សេវានេះ។ ការទូទាត់ត្រូវធ្វើឡើងនៅមុនពេលដែលអ្នកសិក្សាស្រាវជ្រាវ ឬអ្នកអានឯកសារ ចាកចេញពីទីតាំង។*

*សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់បទបញ្ញត្តិ/ពាក្យស្នើសុំ៖* http://d.dccam.org/Abouts/History/pdf/Regulations.pdf

*ជំហានក្នុងការចូលទៅប្រើប្រាស់៖* http://d.dccam.org/Abouts/History/DocAccess.pdf



*សិស្សកំព្រាមកពីអង្គការសុខសប្បាយទស្សនកិច្ចការិយាល័យកណ្ដាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# អាស៊ានត្រូវតែមានគោលជំហររួបរួម ប្រកបដោយឥទ្ធិពលចំពោះសិទ្ធិក្នុងការរស់រានមានជីវិត និងសិទ្ធិមនុស្ស

**ឆាំង យុ**

ដំណាក់កាលសំខាន់ៗតែងតែត្រូវបានកត់សម្គាល់នៅក្នុងសៀវភៅប្រវត្តិសាស្ត្រជាជាងនៅក្នុងព្រឹត្តិការណ៍បច្ចុប្បន្ន។ យើងបានឈានចូលមកដល់ដំណាក់កាលដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រតំបន់អាស៊ីអាគ្នេយ៍ ដែលជាចំណុចកំណត់ថាតើមនុស្សជំនាន់ក្រោយនឹងសិក្សាអំពីការសាមគ្គីរួបរួមប្រកបដោយឥទ្ធិពលនៅក្នុងកម្រិតតំបន់ប្រឆាំងនឹងសកម្មភាពឃោរឃៅប្រព្រឹត្តឡើងដោយរបបយោធាមីយ៉ាន់ម៉ា ឬក៏អាននូវសាច់រឿងផ្សេងមួយទៀតគឺ ការឆ្លើយតបដ៏ទន់ខ្សោយ និងបែកខ្ញែក ទោះបីមិនមែនសាទរ ក៏ប៉ុន្តែគឺអត់ឱនចំពោះ ការបំពារបំពានលើច្បាប់និងបញ្ញត្តិអន្តរជាតិ និងសិទ្ធិមនុស្ស។

កាលពីថ្ងៃទី២៥ ខែកក្កដា របបយោធាមីយ៉ាន់ម៉ាបានប្រកាសអំពីការប្រហារជីវិតបុគ្គលបួនរូបគឺ៖ ព្យូ ហ្សេយ៉ារ ថ (Phyo Zeya Thaw), ច មីនយូ (Kyaw Min Yu) (ហៅក្រៅថា "ជីមមី កូ"), ឡា មីយូ អោង (Hla Myo Aung) និងអោង ធូរ៉ា ហ្សា (Aung Thura Za)។ បុគ្គលទាំងបួនរូបនេះ ត្រូវបានកាត់ទោសជាសម្ងាត់ដោយតុលាការគ្រប់គ្រងដោយរបបយោធា ដែលការកាត់ទោសនេះហាក់ដូចជាមិនស្របទៅតាមបទដ្ឋានអន្តរជាតិឡើយ។ របបយោធាបានបង្គាប់បញ្ឈូនូវភាពព្រៃផ្សៃនៅក្នុងតុលាការនេះ លើការកាត់ទោស និងការប្រហារជីវិត ដោយមិនបានជូនដំណឹងទៅកាន់ក្រុមគ្រួសារនៃបុគ្គលទាំងបួនរូបសោះឡើយ។ ស្ថានភាពរឹតតែតានតឹងឡើងដោយសារតែការពិតដែលថារបបយោធាមីយ៉ាន់ម៉ា គ្រោងនឹង



អ្នកនយោបាយ និងសកម្មជនទាំង៤រូប គឺ ព្យូ ហ្សេយ៉ារ ថ (Phyo Zeya Thaw), ច មីនយូ (Kyaw Min Yu) (ហៅក្រៅថា "ជីមមី កូ"), ឡា មីយូ អោង (Hla Myo Aung) និងអោង ធូរ៉ា ហ្សា (Aung Thura Za) ត្រូវបានកាត់ទោសជាសម្ងាត់ដោយតុលាការគ្រប់គ្រងដោយរបបយោធាមីយ៉ាន់ម៉ា។
(រូបភាពខាងលើ ៖ គូរដោយសកម្មជនរ៉ូហ៊ីងយ៉ា ឈ្មោះរ៉ូ ដេវ៉ា ពូតា)

ប្រហារជីវិតអ្នកទោសនយោបាយចំនួន ៤១នាក់ផ្សេងទៀត ហើយបើតាមស្ថានការណ៍នាពេលបច្ចុប្បន្ន របបយោធាមីយ៉ាន់ម៉ាហាក់មិនមានការខ្វះខាតអ្វីទេក្នុងការអនុវត្តទង្វើនេះ។

នៅពេលដែលគោលការណ៍នៃសង្គមប្រកបដោយអារ្យធម៌មួយត្រូវបានរឹតត្បិត នេះមិនមែនសំដៅត្រឹមតែចំពោះអំពើបំពារបំពានលើគោលការណ៍តែប៉ុណ្ណោះទេ ប៉ុន្តែសំដៅដល់ការសំដែងចេញនូវការមាក់ងាយចំពោះអារ្យធម៌ថែមទៀតផង។ យើងមិនត្រូវអនុញ្ញាតឲ្យគោលការណ៍នៅក្នុងតំបន់ឬរបស់ស្ថាប័ននយោបាយ និងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ចុះទន់ខ្សោយទេ។ អាស៊ានត្រូវតែមានគោលជំហររួបរួមប្រកបដោយឥទ្ធិពលចំពោះសិទ្ធិក្នុងការរស់រានមានជីវិត និងសិទ្ធិមនុស្ស - មិនមែនដើម្បីតែប្រជាជនមីយ៉ាន់ម៉ាតែប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺដើម្បីអនាគតនៃតំបន់ទាំងមូល។

លោក ឆាំង យុ គឺជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, ជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម "វាលពិឃាត" ។ ក្នុងចំណោមកិច្ចការជាច្រើនរបស់លោក ក្នុងការរួមចំណែកចំពោះ ការពិត និង យុត្តិធម៌ លោកក៏បានផ្តល់សក្ខីកម្មនៅចំពោះមុខសាលាក្តីខ្មែរក្រហម បានបង្កើតកម្មវិធីអប់រំអំពីអំពើប្រល័យពូជសាសន៍នៅទូទាំងប្រទេស និងបានបង្កើតមជ្ឈមណ្ឌលថ្នាក់តំបន់ចំនួនប្រាំនៅទូទាំងប្រទេសកម្ពុជា ដើម្បីជួយដល់ការអប់រំ ការស្រាវជ្រាវ និងការផ្សះផ្សា។ លើសពីនេះ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ដល់លោក ឆាំង យុ ជាការទទួលស្គាល់ស្នាដៃដ៏ល្បីល្បាញរបស់លោក នៅក្នុងព្រះរាជាណាចក្រកម្ពុជា។



រូបខាងស្តាំ៖ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅប្រទេសភូមា នៅខែមិថុនា ឆ្នាំ២០១៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឆេង កយ ហៅ សាវ៉ាត ប្រធានមន្ទីរពាណិជ្ជកម្ម តំបន់៥ ភូមិភាគពាយ័ព្យ

ផាត ចាន់សុនិតា



កម្មករបដិវត្តន៍នៅរោងចក្រផលិតកៅស៊ូក្រែប នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆេង កយ ហៅ សាវ៉ាត មានតួនាទីជាប្រធានមន្ទីរពាណិជ្ជកម្មតំបន់៥ ភូមិភាគពាយ័ព្យ។ សាវ៉ាត ត្រូវបានអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧៧ បន្ទាប់ពីខ្សែបណ្ដាញផ្សេងទៀត ត្រូវបានអង្គការចាប់ខ្លួនពីបទរៀបចំផែនការធ្វើរដ្ឋប្រហារនៅខែសីហា ឆ្នាំ១៩៧៧។ ក្នុងចម្លើយសារភាពដែលចុះហត្ថលេខាដោយ សាវ៉ាត នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៧ បានរៀបរាប់អំពីសកម្មភាពរបស់ខ្លួនតាំងពីកុមារភាពរហូតដល់ថ្ងៃអង្គការចាប់ខ្លួនដូចខាងក្រោម ៖

ខ្ញុំឈ្មោះ ឆេង កយ ហៅ សាវ៉ាត អាយុ៣៩ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧) មានទីកន្លែងកំណើតស្ថិតនៅភូមិព្រែកនរិន្ទ ឃុំព្រែកខ្ពប ស្រុកសង្កែ (បច្ចុប្បន្នស្រុកឯកភ្នំ) ខេត្តបាត់ដំបង។ ខ្ញុំចូលរៀននៅវត្តព្រែកនរិន្ទ នៅអាយុ១៣ឆ្នាំ ជាមួយគ្រូចៅអធិការវត្តដល់ថ្នាក់ទី៩។ នៅឆ្នាំ១៩៥០ ខ្ញុំមកធ្វើកម្មករលីសែងឲ្យថៅកែ លី ហាក់ហេង នៅខេត្តបាត់ដំបង។ នៅឆ្នាំ១៩៥៥ ខ្ញុំចូលរៀនបន្តនៅសាលាខេត្តគរុៈបឋមសិក្សាបំពេញវិជ្ជា ទីតាំងនៅស្រុកបាត់ដំបង ខេត្តបាត់ដំបងដល់ថ្នាក់ទី៨។ នៅឆ្នាំ១៩៥៧ ខ្ញុំមកស៊ី

ឈ្មួលរត់សំបុត្រកុននៅរោងកុនក្រុងបាត់ដំបង។ នៅឆ្នាំ១៩៦៣ ខ្ញុំចូលធ្វើទាហានរយៈពេល១៨ខែ នៅបន្ទាយព្រៃស្វាយ ស្រុកម៉ោងឫស្សី ខេត្តបាត់ដំបង។ អំឡុងពេលនោះ លិម វ៉ា ពាក់ស័ក្តិ៤ គឺជាអ្នកចាត់តាំងខ្ញុំឲ្យទៅយកការណ៍ និងតាមដានក្រុមខ្មែរក្រហម។ នៅឆ្នាំ១៩៦៥ គ្រប់កំណត់រយៈពេល១៨ខែ ហើយខ្ញុំក៏ឈប់ធ្វើទាហានមករស់នៅផ្ទះបាត់ដំបងវិញ។ ក្រោយមក ឆ្នាំ១៩៦៧ មេឃុំស្វាយប៉ោ បានកៀរជីវពលមកការពារភូមិ។ ខ្ញុំត្រូវបានចាត់ឲ្យទៅយាមទឹកនៅភ្នំវាយចាប ដើម្បីការពារកុំឲ្យខ្មែរក្រហមចុះមកដងទឹកដឹក។ នៅឆ្នាំ១៩៦៨ ខ្ញុំត្រឡប់ទៅធ្វើការនៅរោងកុនថៅកែបាត់ហោ នៅប៉ៃលិន រហូតដល់ថ្ងៃរដ្ឋប្រហារ។

បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ ខ្ញុំត្រូវចាប់ឲ្យធ្វើទាហានម្តងទៀត និងបញ្ជូនទៅរៀននៅសាលាកំពង់ផ្កោ ផ្លូវជាតិលេខ១១រយៈពេល១២ថ្ងៃ។ កងទ័ពរំដោះ (ខ្មែរក្រហម) បានវាយចូលមកដល់ពេលនោះ ខ្ញុំរត់ទៅនៅឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ក្រោយមក ខ្ញុំបានស្នើសុំសំបុត្រពីសង្កាត់ ដើម្បីធ្វើដំណើរត្រឡប់មកស្រុកវិញ។ នៅឆ្នាំ១៩៧១ ខ្ញុំបានចូលបដិវត្តន៍តាមរយៈឈ្មោះ ណៃ ដែលជាលេខាតំបន់ ៥។ ណៃ អប់រំខ្ញុំថា សភាពការក្នុងប្រទេសមានការតឹងតែងឡើងៗ និងលំបាកខ្លាំង។ តាំងពីមានសង្គ្រាមមក យើងចង់ទៅណាមកណា ធ្វើការងាររកស៊ី ទាល់តែមានការចាត់តាំង មិនដូចពីសង្គមចាស់ទេ យើងរស់នៅស្រួលធ្វើអ្វីបានតាមចិត្ត។ ណៃ ហៅកម្មាភិបាលសំខាន់ដែលជាខ្សែចាត់តាំងមកប្រជុំរៀបចំផែនការកសាងកម្លាំងឲ្យបានគ្រប់ផ្នែក ដើម្បីប្រឆាំងជាមួយអង្គការ។ អ្នកទាំងនោះ រួមមាន សន លេខាស្រុកសេរីសោភ័ណ, ឆាត អនុលេខាស្រុកថ្មពួក, ម៉ោង លេខាស្រុកព្រះនេត្រព្រះ, ហួត លេខាស្រុកថ្មពួក, ភី លេខាវរសេនាតូចលេខ៥១៣, ទុយ លេខាវរសេនាតូចលេខ ៤២៥ និងរូបខ្ញុំ។ បន្ទាប់ពីប្រជុំចប់ ខ្ញុំទទួលផែនការចុះទៅរកខ្សែរយៈនៅតាមភូមិ។

នៅឆ្នាំ១៩៧២ ណៃ ចាត់តាំងកម្មាភិបាលទាំងអស់ឲ្យទៅធ្វើការតាមមុខព្រួញរៀងៗខ្លួន ដើម្បីកសាងកម្លាំង។ នៅឆ្នាំ១៩៧៣ ណៃ ចាត់តាំងខ្ញុំឲ្យទៅជួប សាវ៉ង អតីតទាហានពាក់ស័ក្តិមួយនៅស្រុកក្រឡាញ់ ដើម្បីប្រាប់ សាវ៉ង ឲ្យនាំកូនទាហានមកកៀរប្រជាជនចេញ។ នៅឆ្នាំ១៩៧៤ ណៃ បានហៅប្រធានយោធាទាំងអស់នៅក្នុងតំបន់មកប្រជុំនៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប។ អ្នកដែលមានឈ្មោះមកប្រជុំមាន ម៉ោង ប្រធានកងអនុសេនាធំ១០២, ឡូយ ប្រធានកងអនុសេនាធំ១០១, ឆ្នង ប្រធានកងអនុសេនាធំ១០៤, តាំង ឃឺន ប្រធានកងអនុសេនាធំ១០៩, នៅ លេខាវរសេនាតូច៤១៥, ខឿន អនុលេខាវរសេនាតូច៤១៥ និងខ្ញុំ។ កិច្ចប្រជុំទាក់ទងនឹងផែនការវាយយកស្រុកភ្នំស្រុក តំបន់៥ ឲ្យបានមុនអង្គការ។ នៅឆ្នាំ១៩៧៥ ផែនការរដ្ឋប្រហារដែល ណៃ ត្រៀមរៀបចំយូមកហើយត្រូវបែកការ ដោយអង្គការក្តាប់សភាពការបានមុន១៥ថ្ងៃ ទើបអង្គការចាត់វិធានការកម្ទេចនិងបោសសម្អាតខ្សែចាត់តាំងរបស់ ណៃ ទាំងអស់នៅមូលដ្ឋាន។ ក្រោយមក អង្គការចាត់តាំងឈ្មោះ ហឹង្ស អតីតសាស្ត្រាចារ្យឲ្យមកធ្វើជាលេខាតំបន់៥ ដើម្បីជួយរៀបចំតំបន់នេះឡើងវិញ។ ហឹង្ស បានហៅខ្ញុំទៅជួបសួរនាំអំពីការងាររកន្ទងមក និងបានណែនាំខ្ញុំអំពីការរៀបចំការងារសារថ្មី។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការបានរំដោះទូទាំងប្រទេស។ ហឹង្ស ចាត់តាំងខ្ញុំឲ្យទទួលខុសត្រូវផ្នែកពាណិជ្ជកម្មតំបន់៥។ បន្ទាប់ពី រៀបចំការងាររួច ហឹង្ស នាំខ្ញុំទៅបាត់ដំបងខេ្មសនាមឲ្យស្គាល់ខ្សែចាត់តាំងរបស់គាត់៤នាក់ រួមមាន ម៉ន លេខាពាណិជ្ជកម្មភូមិភាគពាយ័ព្យ, កែវ ទទួលខុសត្រូវខាងផ្នែកប្រេងភូមិភាគពាយ័ព្យ, ឆយ លេខាផ្នែកបច្ចេកទេសគ្រឿងម៉ាស៊ីនតំបន់៥, លេង លេខាអង្គភាពចម្ការកប្បាសតំបន់៥, ឡុំ លេខាការដ្ឋានតំបន់៥ និងវ៉ាន់ ប្រធានកងចល័តតំបន់៥។ ហឹង្ស បានណែនាំអ្នកដែលបានចូលរួមប្រជុំឲ្យបន្តធ្វើសកម្មភាពបំផ្លិចបំផ្លាញសម្ភារនៅក្នុងឃ្លាំងឲ្យខូចខាតប្រើ

ប្រាសមិនកើត ដើម្បីបន្ថាក់ដំណើរបដិវត្តន៍មិនឲ្យជឿនលឿនទៅមុខ។ ក្រោយមក ខ្ញុំក៏ចុះទៅតាមមូលដ្ឋានជួបខ្មែរចាត់តាំងរបស់ខ្ញុំដើម្បីអប់រំណែនាំធ្វើសកម្មភាព។

ឆ្នាំ១៩៧៦ ហ៊ីង្ស បានហៅខ្ញុំនិងខ្មែរបណ្តាញផ្សេងទៀតទៅជួបពិភាក្សារៀបចំសេដ្ឋកិច្ចដើម្បីត្រៀមធ្វើរដ្ឋប្រហារនៅពេលខាងមុខ។ បន្ទាប់ពីទទួលបានផែនការរដ្ឋប្រហារនេះហើយ ខ្ញុំបានត្រៀមរៀបចំស្បៀងបម្រុងទុកចំនួន ១០០បាវ នៅឃ្លាំងពាណិជ្ជកម្ម, អំបិលចំនួន ៥០ ការ៉ុង នៅឃ្លាំងធំវ៉ារទេះភ្លើងស្រុកសេរីសោភ័ណ។ នៅឆ្នាំ១៩៧៧ ហ៊ីង្សបានហៅកម្មាភិបាលសំខាន់ៗមួយចំនួនដែលជាខ្មែរចាត់តាំងរបស់គាត់មកប្រជុំសម្ងាត់នៅកន្លែងគាត់ធ្វើការ ដើម្បីជម្រាបខ្មែរចាត់តាំងទាំងនោះអំពីផែនការរដ្ឋប្រហារ ខែសីហា ឆ្នាំ១៩៧៧ ខាងមុខនៅតំបន់៥ ភូមិភាគពាយ័ព្យ។ ខ្លឹមសារផែនការរដ្ឋប្រហារគឺ ទី១) ត្រូវបំផ្លិចបំផ្លាញកម្ទេចឲ្យអស់សម្ភារនៅក្នុងឃ្លាំងតាំងពីស្រូវអង្ករ និង រោងចក្រ ២) រំដោះយកស្រុកសេរីសោភ័ណនិងតំបន់៥ ទាំងមូល ៣) ចូលទៅកម្ទេចក្បាលម៉ាស៊ីនដឹកនាំនៅក្នុងភូមិភាគ និងវាយយកទីក្រុងបាត់ដំបង ៤) យើងមានកម្លាំងជំនួយមកពីសៀមដែលមានខ្មែរចាត់តាំងរបស់យើងសម្រាប់ទាក់ទងមកពីខាងក្រៅ។ ពេលទទួលផែនការហើយ ខ្ញុំទៅរៀបចំធ្វើសកម្មភាពក្នុងតំបន់និងអង្គភាពដែលខ្ញុំទទួលខុសត្រូវ។ ក្រោយមកទៀត ផែនការរដ្ឋប្រហារត្រូវបែកការ ហើយអង្គការចាប់ខ្លួនខ្ញុំនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧៧ ។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00៣៧០។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ឆេង កយ ហៅ សាវ៉ាត ពិតប្រាកដយ៉ាងណានោះទេ។***




កម្មាភិបាលខ្មែរក្រហមនៅកំពង់ផែក្រុងកំពង់សោម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស ខន៖ អ្នកយាមឃ្លាំងអង្ករនៅមន្ទីរភូមិភាគបូព៌ា

ភា រស្មី



*កងចល័តនៅសហករណ៍កំពុងប្រមូលស្រូវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ស ខន ហៅ ស៊ី ណា ភេទប្រុស អាយុ ៣០ឆ្នាំ (ក្នុងឆ្នាំ១៩៧៨)។ ពីមុនមកខ្ញុំគឺជាអ្នកយាមឃ្លាំងអង្ករនៅមន្ទីរភូមិភាគបូព៌ា មុនពេលធ្លាក់ខ្លួនមកធ្វើជាមេចោរព្រៃនៅក្នុងតំបន់ ២០ ។ ខ្ញុំបែកពីឪពុកម្តាយតាំងពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ទៅចូលធ្វើជាកងឈ្លបនៅឃុំតាសួស ក្នុងតំបន់២៣រហូតដល់ឆ្នាំ១៩៧៤។ ចាប់ពីឆ្នាំ១៩៧៤ ដល់ឆ្នាំ១៩៧៨ ខ្ញុំចូលធ្វើការក្នុងមន្ទីរភូមិភាគបូព៌ាដោយមានតួនាទីគឺជាអ្នកយាមឃ្លាំង ស្រូវ អង្ករ។

នៅក្នុងឆ្នាំ១៩៧៨ មានហេតុការណ៍កើតឡើងដោយអង្គការចាប់ផ្តើមតាមចាប់ខ្លួនមេដឹកនានៅក្នុងភូមិភាគបូព៌ា សោ ភឹម រួមជាមួយបក្ខពួកត្រូវបានចោទពីបទក្បត់ជាមួយបដិវត្តន៍។ អំឡុងពេលនោះមានអតីតកម្មាភិបាលខ្មែរក្រហមជាច្រើននាក់រត់គេចខ្លួនពីការតាមចាប់របស់អង្គការទៅចូលធ្វើជាចោរព្រៃ។ ក្រោយមក មានចោរព្រៃ ៥នាក់ មកបបួលខ្ញុំនិងមិត្តចំនួន ៦នាក់ ដែលកំពុងធ្វើការជាអ្នកយាមឃ្លាំង ឲ្យរត់ចូលព្រៃដើម្បីកុំឲ្យអង្គការយកទៅសម្លាប់។ មុនដំបូង យើងទាំងអស់គ្នាមិនព្រមទៅជាមួយទេ ប៉ុន្តែក្រោយមកយើងបានសម្រេចចិត្តទៅជាមួយដោយមានឈ្មោះ សេត ហៅ គុល គឺជាអតីតយោធានៅភូមិភាគបូព៌ា និង ស្មាន់ នៅមន្ទីរភូមិភាគបូព៌ា គឺជាអ្នកដឹកនាំក្រុមចោរព្រៃតំបន់ ២០។

គុល បាននាំយើងចូលទៅដល់ព្រៃជ្រៅមួយកន្លែងដែលមានឈ្មោះថា ព្រៃតាសិត ស្ថិតនៅឃុំដូនតី ជាប់ឆ្មារ ហូតដល់ព្រៃក្របៅ ឃុំក្របៅ ស្រុកកំចាយមារ។ មកដល់កន្លែងលាក់ខ្លួន ខ្ញុំជួបមនុស្សប្រហែល១០នាក់បន្ថែមទៀត ក្នុងនោះមានឈ្មោះ ជំរឿន គឺជាអតីតប្រធានកងឈ្លបឃុំដូនតី, ឈ្មោះ ធួក គឺជាប្រជាជននៅក្នុងសហករណ៍បុសទី, ឈ្មោះ ភឿង គឺជាប្រជាជននៅក្នុងសហករណ៍បុសទី និងឈ្មោះ សារ៉ាត គឺជាប្រជាជននៅក្នុងសហករណ៍បុសទី ចំណែកអ្នកផ្សេងទៀតមិនស្គាល់ច្បាស់។ ខ្ញុំទៅនៅព្រៃតាសិតបានរយៈពេល ៥ថ្ងៃ ជំរឿន ឲ្យគ្នាយើង១០នាក់ រួមទាំងខ្ញុំចេញទៅយកអង្ករពីសហករណ៍ភូមិក្របៃ ឃុំដូនតី ពេលនោះអង្គការមិនទាន់ជម្លៀសប្រជាជនចេញទេ។ យើងចេញទៅនៅវេលាម៉ោង៧ ដល់ម៉ោង១២ យើង ត្រឡប់មកវិញដោយបានស្រូវចំនួន ៣០បាវ និងអំបិលប្រហែលមួយ បុពីរបាវ។ យើងបានយកស្រូវទាំងអស់នោះទៅទុកនៅ ខាងលិចកន្លែងស្នាក់នៅជិតដើមឈើធំមួយ។ ខ្ញុំស្នាក់នៅព្រៃតាសិតបានរយៈពេល៥ថ្ងៃ គុល នាំក្រុមខ្ញុំទៅព្រៃទទក ដែលស្ថិតនៅ ខាងកើតឈៀងខាងត្បូង ភូមិទួលឃ្លាំង ឃុំដូនតី និងឆ្ងាយពីក្របៅប្រហែល ៥គីឡូម៉ែត្រ។ ទៅដល់ទីនោះខ្ញុំឃើញមានចោរព្រៃរស់នៅប្រហែល ៣០នាក់ បន្ថែមទៀត ព្រមទាំងមានកាំភ្លើង ២០ដើម គ្រាប់៦០ ឡាំង និងស្រូវ ៣០ បាវឆ្អែត សម្រាប់ធ្វើជាស្បៀង។ ចំណែកឯការហូបចុក គឺយើងហូបមួយថ្ងៃពីរពេលគឺ ពេលព្រឹក និងពេលល្ងាច ដោយពេលព្រឹកយើងហូបបបរនៅម៉ោង ៥ ភ្លឺ និងពេលល្ងាចហូបបាយ ហើយពេលខ្លះបបរទាំងពីរពេល។ ខ្ញុំនៅព្រៃទទកបានរយៈពេល ៨ថ្ងៃ គុល នាំចោរព្រៃ ២០នាក់ ទៅកៀរប្រជាជនក្នុងភូមិសម្បួរ បានចំនួន ២០គ្រួសារ។ លុះដល់ព្រឹកឡើង ក្រុមខ្ញុំទៅកៀរប្រជាជននៅភូមិបុសទីបានចំនួន២០គ្រួសារ បន្ថែមទៀត។ ប្រជាជនមួយចំនួនរត់ត្រឡប់ទៅនៅជាមួយអង្គការវិញ ហើយខ្លះទៀតទៅស្រុកយួន និងខ្លះទៀត ចោរព្រៃយកទៅដាក់នៅព្រៃទ្រាប់ទ្រា។ នៅពេលដែលក្រុមចោរព្រៃទៅកៀរប្រជាជននៅភូមិសម្បួរ ក៏ដោយទាំងគ្រួសាររបស់ខ្ញុំ និងម្តាយក្មេករបស់ខ្ញុំមកជាមួយដែរ។

បន្ទាប់មកគុលឲ្យគ្នាខ្ញុំ៤នាក់ទៅ ទាក់ទងជាមួយប្រធានសហករណ៍ និងប្រជាជនភូមិអញ្ចាញ ឃុំដូនតីដើម្បីរកអង្ករ អំបិល ដោយពេលនោះមានឈ្មោះ ជឿន អតីតកងការពាររបស់ សោ ភឹម គឺជាអ្នកទំនាក់ទំនង។ យើងចេញដំណើរម៉ោង ៧យប់ ទៅខាងកើតភូមិ។ នៅប្រហែល ១០០ម៉ែត្រ ទៅដល់ភូមិ ជឿន ឲ្យយើងរង់ចាំ ហើយរយៈពេលកន្លះម៉ោង ទើបគាត់ត្រឡប់មកវិញ និងប្រាប់ខ្ញុំថាទំនាក់ទំនងបានហើយ។ បន្តិចក្រោយមកឃើញមានឈ្មោះ ឡោ គឺជាអតីតប្រធានសហករណ៍ភូមិអញ្ចាញ និងឈ្មោះ សារ៉ាត បានសែងអង្ករកន្លះបាវ និងអំបិលត្រឡប់មកវិញ។ ក្រុមរបស់យើងបានដើរឆ្លងកាត់ស៊ីងព្រៃស្តៅ ជាប់ជាមួយព្រៃម៉ឺនដែរ ហូតដល់ម៉ោង៩យប់ទើបមកដល់កន្លែងលាក់ខ្លួន។ គុល បានឲ្យជំរឿន ដឹកនាំមនុស្ស១២នាក់ មានទាំងបុរស និងនារីដើម្បីទៅកិនស្រូវដែលបានលាក់ទុកនៅព្រៃតាសិត ដោយធ្វើដំណើរកាត់តាមព្រៃអណ្តូងព្រីង និងបានចូលជំរំចោរនៅទីនោះផងដែរ។ យើងបានកិនស្រូវរយៈពេល៥ថ្ងៃដោយកិនស្រូវពេលយប់ និងអុំអង្ករនៅពេលថ្ងៃ។ ក្រុមរបស់ខ្ញុំអុំអង្ករបានចំនួនជាង ៣បាវ រួចហើយបញ្ជូនទៅព្រៃទទកទាំងអស់។ អង្គការបានធ្វើការរុកមនុស្សនៅព្រៃទទក និងបានជួបក្រុមខ្ញុំ ហើយបានបាញ់ស្លាប់អស់បីនាក់ ប៉ុន្តែមិនចូលដល់ជំរំធំទេ។

ថ្ងៃក្រោយមកទៀត គុល នាំក្រុមខ្ញុំ៤នាក់មកជាមួយដើម្បីចាំបាញ់ឡានអង្គការដែលដឹកស្រូវ អង្ករចេញចូល ត្រង់ថ្នល់ខាងត្បូងភូមិក្របៃ ដែលជាកន្លែងអង្គការធ្លាប់ដឹកឆ្លងកាត់ពីមុនៗ។ នៅវេលាម៉ោង ៨ទៅ ៩ ព្រឹកឡានមកដល់ គុល ឲ្យក្រុមខ្ញុំបាញ់ឡានកង់ ៦ ដែលបើកក្រោយគេឲ្យបែកកង់ផ្អៀងមួយចំហៀង ហើយក្រុមខ្ញុំក៏រត់ចូលព្រៃ ព្រោះពេលនោះមានឡានដឹកយោធាខ្មែរក្រហមមកពីក្រោយ។ ប៉ុន្មានថ្ងៃក្រោយមក គុល បញ្ជូនចោរព្រៃ៣នាក់ឲ្យទៅមើល

ស្ថានភាពនៅព្រៃទ្រាប់ទ្រា ក្នុងឃុំក្រសាំង តំបន់២៣ ដើម្បីបញ្ជូនមនុស្សឲ្យទៅរស់នៅទីនោះ។ ដោយឃើញព្រៃនៅទីនោះអំណោយផលល្អអាចរស់នៅបាន គុល បញ្ជូនប្រជាជនឲ្យទៅរស់នៅប្រហែល១០០គ្រួសារ ដោយបញ្ជូនម្តងបន្តិចៗកុំឲ្យបែកការណ៍។

ប្រហែលពាក់កណ្តាលខែសីហា ឆ្នាំ១៩៧៨ គុល បានហៅយើងប្រហែល៤នាក់ ទៅជាមួយគាត់ដើម្បីស្នើសុំយោធាពីតំបន់ ២១ មកខ្លះ ព្រោះនៅតំបន់ ២០ សម្បូរតែប្រជាជន ចំណែកតំបន់ ២១ មិនសូវមានប្រជាជនរស់នៅទេ។ យើងបានធ្វើដំណើរអស់រយៈពេល ១១ យប់ ដោយមាន គុល ជាអ្នកនាំផ្លូវ។ យើងធ្វើដំណើរកាត់តាមព្រៃអណ្តូងក្រេះ ព្រៃតាអាំ និងព្រៃជាច្រើនទៀត តែខ្ញុំមិនចាំឈ្មោះ រហូតទៅដល់ភូមិមួយឈ្មោះភូមិហួច។ យើងរង់ចាំយោធាតំបន់ ២១ ប្រហែល៣ទៅ៤ម៉ោងទើបមាននីរសារតំបន់២១ម្នាក់មកនិយាយជាមួយ គុល រួចហើយក៏ត្រឡប់ទៅវិញ។ រហូតដល់ម៉ោងជាង ១២យប់ បានឃើញមានយោធាតំបន់ ២១ ប្រមាណជា ៥០នាក់ ដឹកនាំដោយ សេង លីហេង មកដល់។ យើងធ្វើដំណើរអស់រយៈពេល ១១យប់ ទើបមកដល់ព្រៃទទកវិញ ដោយកាត់តាមព្រៃសំបុកមាន់។ នៅតាមផ្លូវ សេង លីហេង បានសួរនាំពីការហូបចុកនៅតំបន់ ២០ ព្រោះតំបន់ ២១ មិនសូវមានអាហារគ្រប់គ្រាន់នោះទេ។ ក្រោយមក គុល បានឲ្យខ្ញុំ និង ស្មាន់ ទៅព្រៃទ្រាប់ទ្រាបន្តទៀត ដើម្បីមើលផ្លូវនាំប្រជាជនទៅស្រុកយួន។ យើងបានចេញដំណើរនៅវេលាម៉ោងប្រហែល៦ល្ងាច ដោយឆ្លងកាត់តាមខាងត្បូងព្រៃក្រញាំ និងឆ្លងស្ទឹងម៉ុនដ័យ ទៅខាងត្បូងឈាងខាងលិចប៉ុស្តិ៍ប៉ូលិសតំបន់ម៉ុនដ័យ។ យើងចំណាយពេលមួយយប់ ទើបដល់ព្រៃទ្រាប់ទ្រា ហើយបានជួបចោរព្រៃ ៥ នាក់ ក្នុងតំបន់នោះ។

រយៈក្រោយមក គុល មកដល់ព្រៃទ្រាប់ទ្រាព្រមទាំងចាត់តាំងឲ្យ ស្មាន់ ដឹកនាំឈ្មោះ ជឿន, រឿង ទៅស៊ើបផ្លូវដើម្បីបញ្ជូនប្រជាជនទៅយួន ចំណែកខ្ញុំនិងប្រជាជនជាង១០នាក់ទៀត ទៅព្រៃទទកដើម្បីយកស្បៀង ប៉ុន្តែបានស្រូវតែ១០ថាំងប៉ុណ្ណោះ។ ក្រោយមកឈ្មោះ ញឹម បាននាំខ្ញុំរួមទាំងប្រជាជន ១០នាក់ទៀតធ្វើស្ពានយោលមួយ ដោយចងខ្សែពីដើមឈើមួយទៅដើមឈើមួយទៀត ដើម្បីបញ្ជូនប្រជាជនទៅស្រុកយួន។ យើងប្រើពេលធ្វើស្ពានរយៈពេល ២ថ្ងៃ ទើបអាចឆ្លងស្ពានស្ទឹងម៉ុនដ័យ ម្តុំព្រៃក្រហម។ បន្ទាប់មក គុល បានបញ្ជូនចោរព្រៃ៤នាក់ទៀត រួមទាំងខ្ញុំ ដើម្បីពិនិត្យមើលក្រែងលោអង្គការចូលមករុកព្រៃ។ ក្រោយមកទៀត គុល នាំក្រុមខ្ញុំចំនួន ៣នាក់ទៀតដើម្បីទៅកៀរប្រជាជននៅភូមិកន្ទែងជ្រៅ ស្រុកកំចាយមារ បានចំនួនជិត៥០គ្រួសារ ដោយមានការជួយពីឈ្មោះ យឹម គឺជាអនុប្រធានសហករណ៍។ មុនពេលចុះទៅកៀរប្រជាជន យឹម បានឃោសនាថា ពុកម៉ែបងប្អូនរស់នៅក្នុងភូមិនេះបន្តទៀតមិនបានទេ អង្គការនឹងយកទៅសម្លាប់ចោលទាំងអស់មិនថាក្មេងឬចាស់ ដូច្នេះប្រជាជនជឿ ហើយមកតាមក្រុមរបស់ខ្ញុំទាំងអស់។ ក្រោយប្រមូលប្រជាជនបាន គុល ឲ្យក្រុមខ្ញុំចំនួន ៤នាក់ រួមជាមួយ យឹម ទៅភូមិកន្ទែងជ្រៅ ដើម្បីជញ្ជូនស្រូវទៅទុកនៅព្រៃខាងកើតភូមិសិន រួចបញ្ជូនទៅព្រៃទ្រាប់ទ្រាតែម្តង។ ក្រោយមកឈ្មោះ ស្មាន់ ត្រឡប់មកវិញហើយប្រាប់ គុល ថាយើងបានដោះមីនតាមផ្លូវទៅព្រំដែនយួនបានហើយ។ ចំណែកខ្ញុំត្រូវការពារប្រជាជននៅកន្ទែង រង់ចាំដើងក្រោយៗ បន្ទាប់ពីប្តូរវេនយាមរួច ខ្ញុំសម្រាករហូតដល់ម៉ោង៨ ទៅម៉ោង៩ព្រឹក ហើយពេលដឹងខ្លួនឡើង មិនដឹងថាអង្គការរុកព្រៃឮតែសំឡេងស្រែកហៅប្រជាជនក៏រត់ទៅរក ដោយស្មានតែហៅគ្នាទៅស្រុកយួន។ ពេលទៅដល់អង្គការចាប់ខ្ញុំបាននៅពេលនោះ និងបញ្ជូនខ្ញុំរយៈពេល ៣យប់ បានមកដល់ទីកន្លែងឃុំឃាំងនៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ១៩៧៨។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ D៤១៧៥៥ ។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ស ខន ហៅ ស៊ី ណា ពិតប្រាកដយ៉ាងណានោះទេ។***

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ជួបប្រជុំ ពិភាក្សាជាមួយអាជ្ញាធរស្រុកកំពង់សៀមស្តីអំពីគម្រោងប្រវត្តិសាស្ត្រ និងសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*អេង វណ្ណីកា*



លោកស្រី សុខ ម៉ាលីស អភិបាលរងស្រុកកំពង់សៀម (រូបទីពីររាប់ពីឆ្វេង) និងក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃពុធ ទី១៧ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង៩ព្រឹក ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយ ទូច វណ្ណេត, អេង វណ្ណីកា និង ស៊ាង ចិន្តា ទទួលបានការអនុញ្ញាតឲ្យចូលជួបប្រជុំជាមួយលោកស្រី សុខ ម៉ាលីស អភិបាលរងស្រុកកំពង់សៀម និងមន្ត្រីពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីការស្នើសុំកិច្ចសហការ និងការអនុញ្ញាតឲ្យអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមចុះបំពេញកិច្ចការងារទៅលើគម្រោង«ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៅតាមភូមិ និងឃុំនានាក្នុងស្រុកកំពង់សៀម។

ជាកិច្ចចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលជាសាខារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្លែងអំណរគុណដល់លោកស្រីអភិបាលរងស្រុក ចំពោះការអនុញ្ញាតឲ្យក្រុមការងារចូលជួបប្រជុំ និងបង្ហាញអំពីគោលបំណងនៃគម្រោង ដែលរួមមាន៖ ទី១) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតាមគោលដៅដែលបានកំណត់, ទី២) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទី៣) ធ្វើការ

សិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមសហគមន៍។

ដើម្បីសម្រេចបាននូវគោលបំណងនេះ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ស្នើសុំកិច្ចការអនុញ្ញាតពីលោកអភិបាល នៃគណៈអភិបាលស្រុកកំពង់សៀម ក្នុងការចុះអនុវត្តសកម្មភាពការងារគម្រោងនៅក្នុងភូមិ និងឃុំនានាក្នុងស្រុកកំពង់សៀម និងកិច្ចសហការក្នុងការជ្រើសរើសអ្នកស្ម័គ្រចិត្តចេញពីមូលដ្ឋានភូមិ និងឃុំនានាក្នុងស្រុកកំពង់សៀមចំនួន ២០នាក់ដើម្បីចុះអនុវត្តកិច្ចការងារក្នុងពេលឆាប់ៗនេះ។

លោកស្រី សុខ ម៉ាលីស អភិបាលរងស្រុក ថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ក្នុងការកំណត់យកស្រុកកំពង់សៀមជាគោលដៅអទិភាព និងសម្តែងការពេញចិត្តចំពោះគម្រោងនេះ ដែលយកចិត្តទុកដាក់ទៅលើមិនត្រឹមតែបទពិសោធន៍ជីវិតនោះឡើយ ក៏ប៉ុន្តែថែមទាំងស្ថានសុខភាពបច្ចុប្បន្នរបស់អ្នករានមានជីវិតពីរបបខ្មែរក្រហម។ លោកស្រីអភិបាលរងស្រុក បន្ថែមទៀតថា «សន្តិភាពគឺ ពិតជាមានសារសំខាន់ណាស់ ដែលយើងគ្រប់គ្នាត្រូវតែចូលរួមការពារ។ ការស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអាចជួយលើកកម្ពស់ការអត់ឱន និងការយោគយល់គ្នាទៅវិញ ដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ។ បន្ថែមលើនេះទៀត គម្រោងប្រវត្តិសាស្ត្រនិងសុខភាព នេះគឺល្អសម្រាប់យុវជន-យុវនារី ក៏ដូចជារូបខ្ញុំផ្ទាល់ ដែលកើតក្រោយរបបខ្មែរក្រហម អាចចុះជួបនិងស្តាប់អំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានភូមិនិងឃុំរបស់ខ្លួន ដើម្បីយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងចូលរួមការការពារសន្តិភាព និងការអភិវឌ្ឍន៍»។

ជាចុងបញ្ចប់នៃកិច្ចប្រជុំនេះ លោកស្រីអភិបាលរងស្រុក ផ្តល់កិច្ចសហការក្នុងការជួយជ្រើសរើសយុវជន-យុវនារីស្ម័គ្រចិត្តក្នុងស្រុក ដើម្បីចូលរួមបំពេញកិច្ចការងារក្នុងការជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងភូមិសាស្ត្រស្រុកកំពង់សៀម។



លោកស្រី សុខ ម៉ាលីស អភិបាលរងស្រុកកំពង់សៀម។
(ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទេសភាពវាលស្រែនៃស្រុកកំពង់សៀម
ខេត្តកំពង់ចាម ក្នុងរដូវវស្សា។
(ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម
## ចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូង

*អាន ម៉ាហ្គារ៉េត ចូហាន់សេន*



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ក្រុមការងារប្រវត្តិសាស្ត្រនិងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅខេត្តត្បូងឃ្មុំ ដើម្បីសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ៣នាក់ គឺ ១) ដន ដុង អាយុ ៦៤ឆ្នាំ ២) អ៊ិន សាម៉ុន អាយុ ៧៦ឆ្នាំ និង ៣) លឹម លា អាយុ ៥៦ឆ្នាំ រស់នៅក្នុងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្នុងគោលបំណងដើម្បីស្វែងយល់អំពីបទពិសោធន៍សម័យខ្មែរក្រហមរបស់គាត់ មុនពេលគាត់អញ្ជើញមកចូលរួមការប្រជុំនៅថ្ងៃបន្ទាប់។

ក្នុងអំឡុងពេលជួបជាមួយអ្នករស់រានមានជីវិតនីមួយៗ អ្នកស្រី សូ ហ្វារីណា នាយិការងមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក កូលីន ស៊ីមសារីន (Colin Simsarian) និស្សិតមកពីសកលវិទ្យាល័យប៉ាឡូអាល់តូ ដែលសិក្សាលើផ្នែកសុខភាពសាធារណៈ បានសួរគាត់អំពីរឿងរ៉ាវពីសម័យខ្មែរក្រហម និងស្ថានភាពសុខភាពរបស់គាត់ទាំងអស់គ្នា។ អ្នកស្រី សូ ហ្វារីណា ក៏បានណែនាំក្រុមការងារ និងជម្រាបអំពីគម្រោងប្រវត្តិសាស្ត្រនិងសុខភាព រួមទាំង ខ្លឹមសារកូនសៀវភៅណែនាំអំពីសុខភាព ដែលស្ថិតក្នុងសេចក្តីពង្រាង និងបានអញ្ជើញអ្នករស់រានមានជីវិតទាំងនោះចូលរួមវេទិកាស្តីអំពីការរៀបចំកូនសៀវភៅណែនាំអំពីសុខភាពសហគមន៍នៅថ្ងៃបន្ទាប់។ លោក កូលីន ស៊ីមសារីន ក៏បានសន្ទនាជាមួយអ្នករស់រាន



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានជីវិតពីរបបខ្មែរក្រហមអំពីស្ថានភាពសុខភាពផ្លូវកាយ និងផ្លូវចិត្តបច្ចុប្បន្នរបស់ពួកគាត់ ហើយបានផ្តល់ការណែនាំអំពីវិធីមួយចំនួនធ្វើឲ្យប្រសើរឡើងដល់សុខភាព។

ក្រោយពីបានជួបអ្នករស់មានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូងហើយ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មក៏បន្តជួបគ្រូពេទ្យនៅក្នុងភូមិ ។ នៅទីនោះ ក្រុមការងារ បានបង្ហាញកូនសៀវភៅណែនាំអំពីសុខភាពដល់លោកគ្រូពេទ្យ ហ៊ា នរី ហើយស្នើសុំយោបល់ពីគាត់។ លោកគ្រូពេទ្យ បានមានប្រសាសន៍ថាកូនសៀវភៅណែនាំអំពីសុខភាពនេះ មានសារសំខាន់សម្រាប់អ្នកស្រុកដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ បន្ថែមលើព័ត៌មានដែលមាននៅក្នុងកូនសៀវភៅនេះ លោកគ្រូពេទ្យភូមិ បានផ្តល់យោបល់ថា ប្រសិនបើអាច យើងគួរបន្ថែមព័ត៌មានអំពីជំងឺគ្រុនឈាម និងជំងឺសត្វល្អិតទៀត ពីព្រោះទាំងនេះគឺជាជំងឺដែលគាត់ខស្សាហ៍ប្រទះឃើញក្នុងចំណោមអ្នកជំងឺរបស់គាត់នៅក្នុងភូមិក្តុលផ្សារ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

បន្ទាប់មក ក្រុមការងារបានទៅទស្សនាមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលមានទីតាំងនៅក្នុងសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កោះថ្ម។



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងារត្រូវបានអមដំណើរដោយលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានណែនាំអំពីពិព័រណ៍រូបថត និងផ្ទាំងរូបភាពដែលដាក់តាំងបង្ហាញនៅមជ្ឈមណ្ឌលឯកសារកោះថ្ម។

# ការឆ្លុះបញ្ចាំងអំពីតំបន់ទេសចរណ៍
## ប្រវត្តិសាស្ត្រអន្លង់វែង តាមរយៈដំណើរទស្សនកិច្ចរបស់យុវជន

*ហ៊ាន ពិសី*



ក្រុមយុវជនមកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទទស្សនកិច្ចសារមន្ទីរអតីតផ្ទះតាម៉ុក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង បាន និងកំពុងក្លាយទៅជាទីតាំងសម្រាប់ទស្សនកិច្ចបែបសិក្សារៀនសូត្រ និងឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងរយៈកាលចុងក្រោយនៃចលនាខ្មែរក្រហមនៅអន្លង់វែងនៅត្រឹមឆ្នាំ១៩៩៨។ នៅក្នុងខែសីហា ឆ្នាំ២០២២ យុវជន ទៀង សៀងហៃ ស្ថិតក្នុងចំណោមយុវជនចំនួន១៤នាក់ នៃវិទ្យាល័យ ហ៊ុនសែនត្រពាំងប្រាសាទ ដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សាមកកាន់អន្លង់វែង ស្តីអំពី សន្តិភាព និងសិទ្ធិមនុស្ស ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯសារកម្ពុជា។

យុវជនវ័យ១៩ឆ្នាំរូបនេះ បានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ សារមន្ទីរ អតីតផ្ទះតាម៉ុក អតីតផ្ទះប្រជុំតាម៉ុក បច្ចុប្បន្ន គឺជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង, ទីតាំងបូជាសព ប៉ុល ពត គឺជាអតីតនាយករដ្ឋមន្ត្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលដែលឃើញនិង

ស្តាប់មគ្គុទ្ទេសក៍ធ្វើបទបង្ហាញទាក់ទងនឹងទីតាំងនីមួយៗ ទៀង សៀងហៃ ចាប់ផ្តើមនឹកឃើញដល់ការរៀបរាប់ប្រាប់របស់ឪពុកនិងម្តាយរបស់ខ្លួនដែលធ្លាប់ជាសមាជិកម្នាក់របស់ចលនាខ្មែរក្រហមដែរ។

សៀងហៃ និយាយថា ម្តាយរបស់ខ្ញុំឈ្មោះ ផៃ ធឿង មានទីកន្លែងកំណើតនៅខេត្តកំពង់ធំ។ ពីមុន គាត់ធ្លាប់ជាអតីតកងនារីដឹកជញ្ជូនគ្រាប់ និងថ្នាំពេទ្យយកទៅឲ្យកងទ័ពនៅសមរភូមិ។ ម្តាយរបស់ខ្ញុំតែងនិយាយប្រាប់ខ្ញុំថា ជីវិតនៅក្នុងសម័យសង្គ្រាមគឺលំបាកណាស់ និងធ្វើការគ្មានពេលសម្រាកឡើយ។ ខ្មែរក្រហមបានបិទសិទ្ធិគ្រប់យ៉ាង សូម្បីតែការរៀបការ ក៏ត្រូវបានខ្មែរក្រហមចាប់បង្ខំដែរ។ ម្តាយនិងឪពុកខ្ញុំ បានរៀបការជាមួយគ្នា ទាំងមិនបានស្រឡាញ់គ្នា។ គ្មាននរណាម្នាក់ហ៊ានតវ៉ាឡើយ ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល។ ការរៀបការនេះ មានច្រើនគូ ហើយគូនីមួយៗ ត្រូវឈរតម្រង់ជួរដោយបែរមុខរកគ្នា។ បន្ទាប់មក ចាប់ដៃគ្នា និងប្តេជ្ញានៅចំពោះមុខអង្គការខ្មែរក្រហម។ រីឯឪពុកខ្ញុំឈ្មោះ ទោង ផែន មានទីកន្លែងកំណើតនៅខេត្តមណ្ឌលគិរី។ គាត់គឺជាយោធាខ្មែរក្រហមដែលពិការជើងដោយសារផ្ទុះគ្រាប់មីនក្នុងអំឡុងពេលធ្វើសង្គ្រាម។ បន្ទាប់ពីការតស៊ូអស់ជាច្រើនឆ្នាំ គឺគ្មានសេសសល់អ្វីទាល់សោះ ក្រៅពីការចងចាំដ៏ឈឺចាប់ និងរបួសស្នាមនៅជាប់នឹងខ្លួន។

ក្រោយពីដំណើរទស្សនកិច្ច និងការនឹកឃើញឡើងវិញនូវរឿងរ៉ាវទាំងអស់នោះ ទៀង សៀងហៃ ចាប់ផ្តើមមានទស្សនពីរផ្សេងគ្នា។ ដំបូងយុវជនរូបនេះបានត្រឹមនិយាយអំពីការសោកស្តាយ និងការចងចាំដ៏សោកសង្រេងចំពោះអ្វីដែលប្រវត្តិសាស្ត្របានបន្សល់ទុក។ ប៉ុន្តែ ខ្លួនក៏នៅមានមោទកភាពចំពោះឪពុកខ្លួន និងអតីតកងកម្លាំងយោធាខ្មែរក្រហមផ្សេងទៀត ដែលបានតស៊ូលះបង់គ្រប់យ៉ាងក្នុងការចូលរួមតស៊ូការពារទឹកដី។ ជាចុងក្រោយ យុវជនរូបនេះយល់ឃើញថា អ្នកបម្រើការឲ្យខ្មែរក្រហមមិនសុទ្ធសឹងតែអាក្រក់ទាំងអស់នោះទេ អ្វីដែលអាក្រក់ គឺការដឹកនាំរបស់មេដឹកនាំនៃរបបនោះទេ ដែលធ្វើឲ្យប្រទេសកម្ពុជាត្រូវធ្លាក់ក្នុងភាពលំបាកវេទនា។




ក្រុមយុវជនមកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទ ទស្សនកិច្ចទីតាំងបូជាសព ប៉ុល ពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រវត្តិឃុំគគីរ តាមរយៈវេទិកាប្រវត្តិសាស្ត្រគ្រួសារ

ឈុំ រ៉ា



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មកំពុងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ពីថ្ងៃទី១៤ដល់ថ្ងៃទី១៦ខែសីហាឆ្នាំ២០២២ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ១២ គ្រួសារ នៅក្នុងឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឃុំគគីរ មានចម្ងាយប្រមាណ ៥០គីឡូម៉ែត្រ ពីមជ្ឈ-មណ្ឌលឯកសារកោះថ្ម និងចម្ងាយប្រមាណ ២៥ គីឡូម៉ែត្រ ពីទីរួមស្រុកមេមត់ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៧ បត់ស្តាំចូលតាមផ្លូវក្រាលកៅស៊ូនៃភូមិផ្លាកសំរោង ឃុំដារ ចម្ងាយប្រមាណ ១៥ គីឡូម៉ែត្រ និងបត់ស្តាំតាមផ្លូវលំក្នុងចម្ការកៅស៊ូប្រមាណ ៥គីឡូម៉ែត្រ ទើបដល់ឃុំគគីរ។ បច្ចុប្បន្នឃុំគគីរមានភូមិចំណុះចំនួន ៨ភូមិ គឺភូមិគគីរជើង, ភូមិគគីរត្បូង, ភូមិក្រោក, ភូមិចំការថ្មី, ភូមិទួលថ្ម, ភូមិព្រែកពួយ, ភូមិសាឡង់៣ និងភូមិស្រែពោល។ ឃុំគគីរមានព្រំប្រទល់ខាងត្បូង ជាប់ឃុំមេមត់ ខាងជើងជាប់ឃុំកំពាន់ ខាងលិចជាប់ឃុំដារ និងខាងកើតឃុំមេមង។

កាលពីជំនាន់បារាំង ឃុំគគីរ មានប្រជាជនរស់នៅតិចតួច និងប្រកបរបរធ្វើស្រែចម្ការ។ នៅក្នុងភូមិមានដើមគគីរដុះច្រើន មានទាំងដើមតូច និងធំៗ កាលនោះប្រជាជននាំគ្នាទៅធ្វើស្រែនៅត្រើយម្ខាង



ទេសភាពផ្លូវលំនៅក្នុងឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រែកៗ ដោយសារគ្មានស្ពានឆ្លងកាត់ព្រែកអ្នកភូមិបានយកដើមគគីរធ្វើស្ពានសម្រាប់ដើរឆ្លងព្រែកទៅធ្វើស្រែចម្ការៗ ក្រោយមក អ្នកស្រុកបាននាំគ្នាហៅភូមិនេះថា ភូមិគគីរៗ បារាំង បានមកធ្វើចម្ការកៅស៊ូនៅឃុំគគីរ ស្រុកមេមត់ ដោយជួលកម្មករជនជាតិខ្មែរ-ចាម និងវៀតណាមធ្វើការៗ នៅក្នុងឃុំគគីរមានជនជាតិបារាំងម្នាក់នៅមើលការខុសត្រូវ និងធ្វើរបាយការណ៍ផ្ញើទៅថ្នាក់លើៗ នៅក្នុងរបបសង្គមរាស្ត្រនិយមអាជ្ញាធរបានបង្កើតជាឃុំគគីរ ដោយមានភូមិគគីរ និងភូមិផ្សេងៗទៀត ជាចំណុះរហូតមកដល់សព្វថ្ងៃៗ

បន្ទាប់ពី មានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ប្រជាជនស្រុកមេមត់ បានធ្វើបាតុកម្មដើម្បីទាមទារឲ្យសម្តេចព្រះ នរោត្តម សីហនុ ចូលមកគ្រប់គ្រងប្រទេសឡើងវិញៗ អំឡុងពេលធ្វើបាតុកម្មមានការប៉ះទង្គិចគ្នារវាងទាហាន លន់ នល់ និងប្រជាជនដែលគាំទ្រសម្តេចព្រះ នរោត្តម សីហនុៗ ខណៈពេលនោះមានទាំងប្រជាជនដែលគាំទ្រសម្តេចសីហនុ និងទាហាន លន់ នល់ រងរបួសៗ ទាហានលន់ នល់ មានកាំភ្លើងគ្រប់គ្នាៗ ចំណែកប្រជាជនមានតែ កាំបិតពូថៅ និងដំបងៗ ប្រជាជនធ្វើបាតុកម្មនៅខ្នងក្រពើស្រុកមេមត់អស់រយៈពេល ៣ថ្ងៃទើបឈប់ៗ នៅតាមដងផ្លូវ ប្រជាជននាំគ្នាស្រែកថា “ជ័យយោ សម្តេចឪ អ្នកណាមិនទៅ កាប់ចោល” ៗ ពេលបាតុកម្មចប់ប្រជាជននាំគ្នាត្រឡប់មកផ្ទះធ្វើស្រែចម្ការរៀងៗខ្លួនវិញៗ នៅក្នុងឆ្នាំ១៩៧០ដដែល ទាហានអាមេរិកបានទម្លាក់គ្រាប់បែកលើ ឃុំគគីរ ពីព្រោះមានវត្តមានកងទ័ពវៀតកុងលាក់ខ្លួននៅក្នុងឃុំនេះៗ ការទម្លាក់គ្រាប់បែកនេះ បណ្តាលឲ្យប្រជាជនស្លាប់ និងរបួសចំនួន៤០នាក់ៗ នៅឆ្នាំ១៩៧៣ ទើបកងទ័ពវៀតកុងដកចេញអស់ពីឃុំគគីរ និងលែងមានការទម្លាក់គ្រាប់បែកទៀតៗ

នៅពេលខ្មែរក្រហមឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជន១៧ មេសា មកដាក់នៅក្នុងឃុំគគីរ



ផ្លូវនៅក្នុងឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រយៈពេល២ខែ រួចហើយក៏ជម្លៀសបន្តឲ្យទៅនៅភូមិកំពែ ភូមិខ្ពប ឃុំរំចេក ទាំងអស់។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបង្កើតជាសហករណ៍ ហើយខ្មែរក្រហមបានបែងចែកប្រជាជនជាក្រុមៗ។ ប្រធានក្រុមនីមួយៗ បានឲ្យសមាជិកក្នុងក្រុមប្រមូលរបស់របរនៅតាមផ្ទះដូចជាក្របី គោ មាន់ ទា និងទ្រព្យសម្បត្តិផ្សេងៗមកដាក់រួម ទាំងអស់ ទុកតែស្លាបព្រាមួយ និងចានមួយ សម្រាប់ហូបបបរ ប៉ុណ្ណោះ។

នៅចុងឆ្នាំ១៩៧៦និងដើមឆ្នាំ១៩៧៧ ខ្មែរក្រហមបានជ្រើសរើសប្រជាជននៅក្នុងឃុំគគីរឲ្យចូលធ្វើជាកងចល័ត ធ្វើទាហាន និងធ្វើជាគ្រូពេទ្យជាដើម។ ក្មេងៗ ប្រុសស្រី ដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ត្រូវបាត់តាំងឲ្យធ្វើជាកងចល័តលើកទំនប់ជីកប្រឡាយ ច្រូតកាត់ ដកស្ទូង ដែលស្ថិតនៅឆ្ងាយៗពីភូមិ។

នៅឆ្នាំ១៩៧៨ កងទ័ពមកពីភូមិភាគនិរតីបានចូលមកចាប់កម្មាភិបាលដែលជាប្រធានកងតូច ប្រធានកងធំ គ្រូពេទ្យ គ្រូបង្រៀននៅខាងភូមិភាគបូព៌ាយកទៅសម្លាប់នៅព្រៃកន្ធូង ក្នុងស្រុកឆ្លូង ខេត្តក្រចេះ។ ចំណែកប្រជាជន ត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិទាំងអស់ ប្រជាជនខ្លះជម្លៀសទៅដល់ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងមានប្រជាជនខ្លះបានរត់ទៅប្រទេសវៀតណាម រហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀត-ណាមចូលមកវាយផ្ដួលរំលំរបបខ្មែរក្រហម និងទទួលបានជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបប្រជាជនដែលរត់គេចខ្លួនទាំងនោះវិលត្រឡប់មកស្រុកភូមិវិញ។



ខ្លោងទ្វារវត្តនៅឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ទេសភាពនៅតាមវាលស្រែក្នុងរដូវភ្លៀងធ្លាក់នៅឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្មែរក្រហមចាត់តាំងខ្ញុំឱ្យធ្វើប្រធានក្រុម ដោយសារខ្ញុំអាចធ្វើការងារបានច្រើនមុខ

ស្វៀង កញ្ញា



ជា លន់ អាយុ៧២ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជា លន់ អាយុ ៧២ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ កាលពីកុមារភាពខ្ញុំរៀននៅសាលាវត្តដើមបេង ប៉ុន្តែបច្ចុប្បន្នសាលានេះត្រូវបានដូរមកហៅថាសាលាផាន់ផនវិញ។ ខ្ញុំរៀនដល់ថ្នាក់ទី៩ កាលពីសង្គមចាស់ បើធៀបនឹងឥឡូវស្មើថ្នាក់ទី៣ ព្រោះកាលពីសង្គមចាស់រាប់បញ្ច្រាស់មកវិញ។ ខ្ញុំគឺជាក្មេងកំព្រា ហើយត្រូវបានមីងយកមកចិញ្ចឹម ដោយសារគាត់មានកូនបង្កើតតែម្នាក់។ មីងរបស់ខ្ញុំបានយកខ្ញុំមកនៅជាមួយគ្រាន់បានជាគ្នា។

ឪពុករបស់ខ្ញុំស្លាប់ក្នុងជំនាន់ឥស្សរៈ នៅខេត្តបាត់ដំបង ដោយសារសម័យនោះ គាត់ធ្វើការងារខាងកាប់ដើមឈើធំៗ ហើយក្រោយមក គាត់ក៏ធ្លាក់ខ្លួនឈឺមើលមិនជារហូតដល់ស្លាប់។ ខ្ញុំគិតថាឪពុកខ្ញុំស្លាប់ដោយសារព្រាយដើមឈើកាច់គាត់។ ចំណែកឯម្ដាយរបស់ខ្ញុំស្លាប់នៅក្នុងខេត្តពោធិ៍សាត់ ដោយសារអត់អាហារនៅក្នុងរបបខ្មែរក្រហម។

ខ្ញុំបានរៀបការនៅអាយុ១៧ឆ្នាំ ជាមួយបុរសម្នាក់ឈ្មោះ ជូរ ឈិន រស់នៅក្នុងភូមិដើមបេងជាមួយគ្នា។ ក្រោយពីរៀបការរួចហើយ ខ្ញុំមានកូន ២នាក់។ នៅឆ្នាំ១៩៧០ អាចារ្យ អ៊ុន មកហៅប្ដី របស់ខ្ញុំឲ្យចូលធ្វើទាហាន លន់ នល់ ហើយប្ដីរបស់ខ្ញុំក៏បានចាកចេញទៅ។ ក្រោយមក ខ្ញុំបានប្រាប់ប្ដីរបស់ខ្ញុំឲ្យឈប់ធ្វើទាហាន លន់ នល់ ព្រោះខ្ញុំដឹងថាប្ដីរបស់ខ្ញុំខ្លាចស្នូរកាំភ្លើងខ្លាំងណាស់។ ខ្ញុំមិនចង់ឲ្យប្ដីរបស់ខ្ញុំទៅសមរភូមិទេ។

ខ្ញុំបានជិះម៉ូតូ សេអិល របស់ខ្ញុំទៅយកប្ដីខ្ញុំនៅបន្ទាយទាហាននៅក្នុងស្រុកគិរីវង់។ ប្ដីរបស់ខ្ញុំព្រមត្រឡប់មកផ្ទះជាមួយខ្ញុំ ហើយមេបញ្ជាការប្ដីខ្ញុំ បានឲ្យកាំភ្លើងមួយដើមមកប្ដីរបស់ខ្ញុំដាក់ជាប់ខ្លួនរហូតមកដល់ផ្ទះ។ មកដល់ឆ្នាំ១៩៧៤ ខ្ញុំនិងប្ដីបានភៀសខ្លួនមករស់នៅ ទីក្រុងភ្នំពេញ និងប្រកបរបរលក់ម៉ូតូ។ យើងទាំងពីរនាក់ទិញម៉ូតូពីភ្នំពេញយកទៅលក់នៅខេត្តបាត់ដំបង ដោយដឹកតាមយន្តហោះឈ្នួល។ ខ្ញុំជួញដូរម៉ូតូបានតែពីរដើងប៉ុណ្ណោះ យោធាខ្មែរក្រហមវាយរំដោះបានក្រុងភ្នំពេញ ហើយយើងទាំងពីរនាក់ក៏ជាប់នៅក្នុងខេត្តបាត់ដំបង។ ខ្ញុំតែងតែលាក់ប្រវត្តិ មិនឲ្យខ្មែរក្រហមនិងអ្នកជិតខាងដឹងថាប្ដីរបស់ខ្ញុំធ្លាប់ធ្វើទាហានឡើយ។

ខ្ញុំនិងប្តីរបស់ខ្ញុំរស់នៅក្នុងស្រុកមោង ដែលជាស្រុកកំណើតរបស់ឪពុកខ្ញុំ។ នៅក្នុងរបបខ្មែរក្រហម ប្រធានភូមិបានឲ្យខ្ញុំធ្វើការនៅរោងបាយ និងដឹកបាយសម្ល ឲ្យប្រជាជនដែលចេញទៅធ្វើការនៅតាមការដ្ឋានផ្សេងៗ។ នៅពេលនោះ ខ្ញុំគឺជាប្រជាជន ១៧ មេសា ប៉ុន្តែដោយសារខ្ញុំមានចិត្តល្អ មានសុជីវធម៌ល្អ ទើបប្រជាជនទូទៅស្រឡាញ់រាប់អានខ្ញុំ។ ចំណែកឯប្តីរបស់ខ្ញុំ ប្រធានភូមិឲ្យគាត់ទៅនៅក្នុងផ្នែកសេដ្ឋកិច្ច គឺជាកន្លែងបើកអង្ករឲ្យអ្នកនៅតាមកងនីមួយៗ។

នៅពេលនោះ ខ្មែរក្រហមនៅក្នុងភូមិ នឹកស្មានថាខ្ញុំមិនចេះដកសំណាប ព្រោះខ្ញុំគឺជាប្រជាជនថ្មី ក៏សាកល្បងឲ្យខ្ញុំចុះទៅដកសំណាបម្នាក់ឯងឲ្យបានពីរផ្លូនក្នុងមួយថ្ងៃ។ ប៉ុន្តែខ្ញុំអាចធ្វើបាន ព្រោះខ្ញុំគឺជាកូនអ្នកស្រែស្រាប់ និងមិនរួញរាជាមួយការងារបែបនេះឡើយ។ ក្រោយមកទៀត ខ្មែរក្រហមបានឲ្យខ្ញុំទៅបុកអង្ករ ក៏ខ្ញុំចេះបុកអង្ករយ៉ាងស្អាតជំនាញ ព្រមទាំងចេះបុកអង្ករបន្ទឺឡើងដូចជាសំឡេងភ្លេងពិរោះទៀតៗ ពេលដែលប្រធានភូមិដឹងថា ខ្ញុំចេះធ្វើការងារច្រើនមុខ ក៏ចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានក្រុម។ ការងារប្រធានក្រុមមិនពិបាកដូចអ្នកដែលនៅក្រោមបង្គាប់នោះទេ។ ខ្ញុំគ្រាន់តែដើរមើល និងដើរប្រាប់សមាជិកក្រុមតែប៉ុណ្ណោះ។ ជីវិតខ្ញុំកាលពីជំនាន់នោះ មិនសូវលំបាកពេកទេ។ នៅតំបន់របស់ខ្ញុំរស់នៅមានអាហារហូបចុកគ្រប់គ្រាន់ និងមិនខ្វះខាតឡើយ។ បន្ទាប់មក ឮដំណឹងថា កងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជាដើម្បីជួយរំដោះប្រជាជនចេញពីរបបខ្មែរក្រហម ទើបខ្ញុំនិងប្តីនាំគ្នាត្រឡប់មកស្រុកវិញ។ យើងបានធ្វើដំណើរអស់រយៈពេល ២៨ថ្ងៃ ចេញពីខេត្តបាត់ដំបង ទើបមកដល់ស្រុកគីរីវង់។

បន្ទាប់មក ប្តីរបស់ខ្ញុំត្រូវបានប្រជាជនស្នើឲ្យឡើងធ្វើជាមេភូមិ ព្រោះប្តីរបស់ខ្ញុំគឺជាមនុស្សស្លូតត្រង់ ហើយថែមទាំងមានចំណេះដឹងទៀត។ ក្រោយមក ប្តីរបស់ខ្ញុំបានស្លាប់នៅក្នុងឆ្នាំ១៩៨៤ ដោយសារកងទ័ពខ្មែរក្រហមបាញ់ នៅពេលដែលប្តីរបស់ខ្ញុំទៅចូលរួមក្នុងផែនការ «ក៥» ។ នៅពេលដែលប្តីរបស់ខ្ញុំស្លាប់ ខ្ញុំទើបតែមានកូនខ្ចីមួយទៀត ដែលមានអាយុទើបតែមួយខែ។ ខ្ញុំគ្មានកម្លាំងធ្វើអ្វីឡើយ ក្រៅពីយំសោកស្តាយស្រណោះប្តី។ បន្ទាប់ពីបាត់បង់ប្តី ខ្ញុំខិតខំប្រឹងប្រែងរកស៊ីដើម្បីចិញ្ចឹមកូនទាំង ៧ នាក់។ ក្រោយមក ខ្ញុំគិតថា ប្តីរបស់ខ្ញុំស្លាប់ដោយបុព្វហេតុជាតិ ដូច្នេះខ្ញុំក៏បន្តការងារពីប្តីដើម្បីជួយអភិវឌ្ឍន៍ភូមិឃុំឲ្យបានប្រសើរឡើង ហើយពេលបច្ចុប្បន្នខ្ញុំគឺជាសមាជិកភូមិដើមបេង ទទួលបន្ទុកការងារយេនឌ័រ។



ជា លន់ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា កាលពីខែសីហា ឆ្នាំ ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ជា លន់ (រូបឈរកណ្តាល) ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យ៉ាន់ វ៉ាន់ ៖ អ្នកគ្រប់គ្រងកន្លែងធ្វើប្រហុក

ផុន ស្រីពេជ្រ



យ៉ាន់ វ៉ាន់ រស់នៅភូមិបុស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ យ៉ាន់ វ៉ាន់ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅអំឡុងពេលចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យ៉ាន់ វ៉ាន់ អាយុ៦៦ឆ្នាំ រស់នៅភូមិបុស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ឪពុកខ្ញុំឈ្មោះ កៅ យ៉ាន់ ធ្លាប់ធ្វើជាជំទប់ទី១ នៅក្នុងសម័យសង្គមរាស្ត្រនិយម និងម្តាយឈ្មោះ ជា យឿន គឺជាកសិករ។ ម្តាយរបស់ខ្ញុំស្លាប់នៅក្នុងរបបខ្មែរក្រហម ដោយសារមិនមានអាហារហូបចុកគ្រប់គ្រាន់ និងមិនមានថ្នាំសង្កូវសម្រាប់ព្យាបាល។ ខ្ញុំមានបងប្អូនចំនួន១១នាក់ ក្នុងនោះស្រីចំនួន៦នាក់ ហើយសព្វថ្ងៃ បងប្អូនរបស់ខ្ញុំ នៅរស់រានមានជីវិតតែ៣នាក់ប៉ុណ្ណោះ។

ខ្ញុំចូលរៀនដំបូងនៅអាយុ១៨ឆ្នាំ ជាមួយព្រះសង្ឃនៅវត្តសំរោងវត្ត។ ខ្ញុំរៀនជាមួយក្មេងៗឯទៀតអំពីអក្សរសាស្ត្រខ្មែរ លេខនព្វន្ត បូកដក គុណចែក រួមទាំងចំណោទ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០។ មកដល់របប លន់ នល់ ខ្ញុំលែងបានរៀនតទៅទៀត ដោយសារនៅក្នុងភូមិចាប់ផ្តើមមានការទម្លាក់គ្រាប់បែក។ ប្រជាជនតែងនាំគ្នារត់ចូលពួនក្នុងលេណដ្ឋាន ដើម្បីគេចពីការទម្លាក់គ្រាប់បែក។ ផ្ទះសម្បែង សត្វពាហនៈ និងមនុស្សមួយចំនួនបានស្លាប់។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមទទួលជ័យជម្នះទៅលើរបប លន់ នល់ ទាំងស្រុង ខ្ញុំត្រូវបានអង្គការបញ្ជូនចូលទៅក្នុងកងពិសេស ដើម្បីធ្វើការងារជីកប្រឡាយ។ ខ្ញុំជីកព្រែក និងប្រឡាយ ពីឈើទាល ដល់បឹងខ្វី។ ក្រោយពីនេះ ខ្ញុំបានជីកប្រឡាយនៅស្រុកកំចាយមារ។

នៅឆ្នាំ១៩៧៦ ពេលខ្ញុំត្រឡប់មកដល់ភូមិវិញ អង្គការបានផ្សំផ្គុំ និងរៀបការប្រពន្ធឲ្យខ្ញុំ។ ពិធីរៀបការខ្ញុំរៀបចំធ្វើនៅវត្តជីផុច រួមជាមួយគូផ្សេងទៀតសរុបទាំងអស់ចំនួន១៧០គូ មកពីភូមិទាំង១៨ ក្នុងឃុំជីផុច។ ពិធីរៀបការនេះថ្វីត្បិតតែមានច្រើនគូពិតមែន ប៉ុន្តែខ្ញុំសង្កេតឃើញថា មានមនុស្សមិនតិចទេ មិនពេញចិត្តទៅនឹងការផ្សំផ្គុំរបស់អង្គការ ព្រោះពុំបានស្រឡាញ់គ្នា និងពុំដែលធ្លាប់ជួបគ្នាពីមុនមក។ អ្នកខ្លះនៅពេលរៀបការរួចក៏រត់ទៅសម្លាប់ខ្លួន រីឯអ្នកខ្លះទៀតទៅពួនយំមិនឲ្យអង្គការដឹងឡើយ។ នៅក្នុងពិធីរៀបការរបស់ខ្ញុំមិនមានខោអាវថ្មីសម្រាប់ស្លៀកពាក់ទេ។ ខោអាវដែលខ្ញុំស្លៀកក្នុងថ្ងៃរៀបការ គឺខោអាវប្រឡាក់

សុទ្ធតែភក់ៗ ខ្ញុំនិងភរិយាបានប្តេជ្ញាចំពោះអង្គការថា យើងនឹងស្រឡាញ់គ្នាអស់មួយជីវិត។ បន្ទាប់ពីរៀបការរួចបានរយៈពេល៣ថ្ងៃ ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមហៅឲ្យទៅរៀនវគ្គនយោបាយ និងត្រៀមចូលបម្រើយោធា។ ការរៀនសូត្រនោះខ្មែរក្រហមបណ្តុះស្មារតីឲ្យក្រុមយោធាមានភាពស្វាហាប់ រឹងមាំក្លាហាន និងមិនខ្លាចក្នុងការចូលប្រយុទ្ធនៅសមរភូមិមុខ បើទោះបីជាមានគ្នាតែ៣នាក់ ក៏មិនរាថយដែរ។ ខ្ញុំត្រៀមខ្លួនរួចជាស្រេច ប៉ុន្តែខ្ញុំមិនដែលបានចូលប្រយុទ្ធនៅក្នុងសមរភូមិឡើយ ព្រោះខ្ញុំត្រូវផ្លាស់មកនៅជិតក្រុងព្រៃវែងដើម្បីមកមើលការខុសត្រូវកន្លែងធ្វើត្រីប្រហុក។ ការមកធ្វើការនៅជិតក្រុងព្រៃវែងនេះ ខ្ញុំមិនដែលមានទំនាស់ជាមួយសមាជិកនៅក្នុងកងឡើយ ខ្ញុំរួសរាយ ខ្ញុំដាក់ខ្លួន និងខិតខំប្រឹងប្រែងធ្វើការងារ។ លើសពីនេះ ខ្ញុំក៏បំពេញចិត្តគណៈស្រុកពាមរក៍ដែលគ្រប់គ្រងនៅទីនោះដែរ។ ជារៀងរាល់ថ្ងៃ ខ្ញុំយកត្រីធំៗបានពីខាងនេសាទ និងបាយដំណើបទៅជូនគណៈស្រុក។

នៅដើមខែមករា ឆ្នាំ១៩៧៩ គណៈស្រុកពាមរក៍ឲ្យខ្ញុំជិះកប៉ាល់ឆ្ពោះទៅកាន់តំបន់ភាគខាងលិច។ កាលនោះខ្ញុំមិនចង់ទៅទេព្រោះខ្ញុំដឹងថានៅទីនោះមានការលំបាកទាំងការងារ ការហូបចុក និងការស្នាក់នៅជាពិសេសបើធ្វើការងារមិនល្អនឹងត្រូវនាំខ្លួនយកទៅសម្លាប់ចោល ដូច្នេះខ្ញុំក៏សុំអនុញ្ញាតពីអង្គការត្រឡប់មកផ្ទះវិញ។ នៅពេលមកដល់ឃុំព្រៃឃ្នេស ស្រុកមេសាង ខ្ញុំបានជួបប្រពន្ធរបស់ខ្ញុំ បន្ទាប់មកយើងនាំគ្នាវិលត្រឡប់មកផ្ទះវិញ។ កាលនោះប្រសិនបើខ្ញុំទៅភាគខាងលិច ប្រហែលជាខ្ញុំស្លាប់បាត់ទៅហើយ ព្រោះប្រជាជនភាគច្រើនដែលទៅរស់នៅតំបន់នោះមិនមានជីវិតរស់នៅច្រើនទេ។ ជាក់ស្តែង ប្រជាជននៅក្នុងភូមិរបស់ខ្ញុំចំនួន៥គ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសទៅតំបន់ភាគខាងលិចបានស្លាប់ស្ទើរទាំងអស់ គឺមានតែម្នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ដោយសារតែគាត់ធ្វើពុតជាស្លាប់ នៅពេលកម្មាភិបាលខ្មែរក្រហមបានអាករបស់គាត់ទម្លាក់ចូលទៅក្នុងរណ្តៅនៅពេលយប់។

ក្រោយមក ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាមេភូមិបុស្សរីសាញ់ ហើយខ្ញុំតែងតែចែករំលែករឿងរ៉ាវដែលខ្ញុំឆ្លងកាត់ទៅក្មេងជំនាន់ក្រោយឲ្យបានដឹង និងយកទៅគិតពិចារណា បើទោះជាក្មេងៗទាំងនោះជឿឬពុំជឿក៏ដោយ។ ខ្ញុំចង់ឲ្យយុវជនជំនាន់ក្រោយចេះស្រឡាញ់គ្នា និងកុំយកគំរូតាមការដឹកនាំរបស់ខ្មែរក្រហម ដែលនាំឲ្យមានការកាប់សម្លាប់ និងធ្វើឲ្យបាត់បង់ធនធានមនុស្ស។



យ៉ាន់ វ៉ាន់ ទទួលកញ្ចប់អនុស្សាវរីយ៍ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គល់ សឿន ៖ កងចល័តកម្លាំងទីមួយ

ថុន ស្រីពេជ្រ



គល់ សឿនរស់នៅភូមិពន្លៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
(ផេង ពងរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គល់ សឿន អាយុ៧៣ឆ្នាំ កើតនៅភូមិពន្លៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនចំនួន៧នាក់ គឺប្រុស២នាក់ និងស្រី៥នាក់។ បងប្អូនរបស់ខ្ញុំស្លាប់អស់ចំនួន ៤នាក់ ដោយសារជំងឺ។ ក្នុងចំណោមបងប្អូនទាំង៧ នាក់ គឺមានតែខ្ញុំម្នាក់ប៉ុណ្ណោះដែលមានសំណាង និងត្រូវបានឪពុកម្តាយបញ្ជូនឲ្យទៅរៀននៅវត្តពន្លៃ។ កាលនោះ ខ្ញុំរៀនជាមួយព្រះសង្ឃឈ្មោះ ឈុំ។ ខ្ញុំរៀនដល់ត្រឹមថ្នាក់ទី៨ ក៏ឈប់រៀនហើយបួសជាព្រះសង្ឃនៅឆ្នាំ១៩៦៧។ នៅឆ្នាំ១៩៦៩ ខ្ញុំសឹកពីបួសហើយមកជួយឪពុកម្តាយធ្វើស្រែ។

នៅឆ្នាំ១៩៧០ ក្រោយ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ខ្ញុំផ្លាស់ទៅរស់នៅព្រៃអំពៅមួយរយៈដើម្បីគេចពីការតាមចាប់ធ្វើទាហានរបស់រដ្ឋាភិបាល លន់ នល់ ប៉ុន្តែនៅទីនោះក៏ជាតំបន់គ្រោះថ្នាក់ដែរ ដោយសារមានការទម្លាក់គ្រាប់បែកធ្វើឲ្យផ្ទះប្រជាជននៅក្បែរៗនោះ បែកបាក់ស្ទើរគ្មានសល់។

បន្ទាប់ពីយោធាខ្មែរក្រហមឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ការងាររបស់ខ្ញុំគឺនៅក្រុមកងចល័តទីមួយដែលជាក្រុមឈានមុខគេ និងមានកម្លាំងពេញក្នុងការបំពេញការងារ ដូចជា លើកប្រព័ន្ធភ្លឺស្រែ លើកទំនប់ និងជីកប្រឡាយពីពន្លៃទៅសំបួរ។ ដំបូង គឺខ្ញុំនៅហូបបាយនៅតាមផ្ទះរៀងខ្លួន។ ពេលនោះ ខ្ញុំហូបបានឆ្អែត ប៉ុន្តែចាប់ពីឆ្នាំ១៩៧៦ មក ខ្ញុំហូបពុំបានឆ្អែតទៀតឡើយ។ ប្រជាជនទទួលបានរបបអាហារក្នុងមួយថ្ងៃត្រឹមតែពីរពេលប៉ុណ្ណោះ ប៉ុន្តែអង្គការបានចែកថ្នាំកម្លាំងម្នាក់មួយគ្រាប់សម្រាប់កូរជាមួយទឹកផឹក មុនហូបអាហារថ្ងៃត្រង់ ដែលថ្នាំនោះជាប្រភេទថ្នាំគ្រាប់មូលៗផលិតពីកន្ទក់និងស្ករត្នោត ដើម្បីធ្វើឲ្យប្រជាជនមានកម្លាំងធ្វើការ។

ចាប់ពីខែមាឃ ដល់ខែចេត្រ ក្នុងឆ្នាំ១៩៧៦ ប្រជាជនមកពីភូមិពន្លៃ ភូមិស្រះតាអឹម ភូមិសួរ ភូមិគោកប្រេះ ត្រូវបានអង្គការស្នើសុំឲ្យទៅជីកអាងទឹកនៅវត្តស្រះតាអឹមដែលមានជម្រៅ១ម៉ែត្រ និងមានផ្ទៃក្រឡាប្រមាណ ២ ហិចតា។ នៅទីនោះខ្ញុំទទួលបានរបបអាហារហូបចុកគ្រប់គ្រាន់ជាងនៅក្នុងភូមិ ព្រោះអង្គការលើកទឹកចិត្តដល់ប្រជាជនដែលធ្វើការងារធ្ងន់ទទួលរបបអាហារច្រើនជាងអ្នកដែលនៅធ្វើការនៅ

ជិតៗផ្ទះ។ យូរៗម្តងអង្គការមានរៀបចំពីធីជប់លៀង ធ្វើម្ហូបឆ្ងាញ់ៗឲ្យប្រជាជនដែលខំប្រឹងប្រែងធ្វើការ។

មកដល់ឆ្នាំ១៩៧៨ ការងារកាន់តែលំបាកទៅៗ ហើយខ្ញុំត្រូវបានអង្គការផ្លាស់ទៅចន្ទ្រជិតព្រំដែនវៀតណាម ដើម្បីលើកទំនប់ជម្រៅ៣ម៉ែត្រ ទទឹង៥ម៉ែត្រ តភ្ជាប់ពីភូមិមួយទៅភូមិមួយក្នុងស្រុកមេសាង។ នៅទីនោះ ដីរឹងពិបាកជីកខ្លាំងណាស់។ ប្រជាជនភាគច្រើនពុំសូវមានកម្លាំងក្នុងការកាប់ដី ចំណែកទឹកក៏មិនសូវមានសម្រាប់ផឹក និងផឹកដែរ។ រយៈពេល២ទៅ៣ថ្ងៃម្តង ទើបខ្ញុំនិងប្រជាជននៅក្នុងកងចល័តដើរទៅផឹកទឹកនៅព្រែកក្រសាំង។ ព្រែកក្រសាំងនេះនៅជិតព្រំដែនវៀតណាម និងឆ្ងាយពីកន្លែងខ្ញុំធ្វើការ។ ពេលធ្វើការនៅចន្ទ្រ ប្រជាជនក៏ជួបគ្រោះថ្នាក់ដែរ ព្រោះជាតំបន់ជម្លោះរវាងវៀតណាម និងខ្មែរក្រហម។ ថ្ងៃមួយវៀតណាម បានផ្លោងគ្រាប់មកចំប្រជាជនដែលកំពុងលើកទំនប់បណ្តាលឲ្យស្លាប់អស់ជាច្រើននាក់។ ជាសំណាង ដែលខ្ញុំមិនបានស្ថិតនៅទីកន្លែងនោះ។ ក្រោយមកការងារនៅចន្ទ្រត្រូវបានរំសាយ ដោយសារតែមានមនុស្សស្លាប់ច្រើន។ ខ្ញុំបានវិលត្រឡប់មករស់នៅផ្ទះក្នុងភូមិវិញ ហើយអង្គការប្រើឲ្យខ្ញុំឃ្វាលគោក្របី។

នៅដើមខែមករា ឆ្នាំ១៩៧៩ ប្រធានសហករណ៍បានកៀរប្រជាជននៅក្នុងភូមិទៅតំបន់ភាគខាងលិច គេចពីកងទ័ពវៀតណាមដែលវាយចូលមក។ ពេលខ្ញុំទៅដល់អ្នកលឿង ស្រាប់តែមានការបំផ្ទុះឃ្លាំងមួយយ៉ាងធំ ដោយក្រុមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ធ្វើឲ្យប្រជាជនមិនអាចធ្វើដំណើរទៅមុខទៀតបាន។ នៅគ្រានោះ ដោយសារតែចលាចលខ្លាំងពេក ខ្ញុំក៏វង្វេងប្រពន្ធកូន។ រហូតដល់ព្រឹកថ្ងៃបន្ទាប់ទើបខ្ញុំរកក្រុមគ្រួសារខ្ញុំឃើញ។ ចាប់តាំងពីពេលនោះមកប្រទេសជាតិចាប់ផ្តើមមានសុខសន្តិភាព។ ខ្ញុំបាននាំក្រុមគ្រួសារត្រឡប់មករស់នៅភូមិកំណើតនិងចាប់ផ្តើមកសាងជីវភាពគ្រួសារឡើងវិញដោយប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។



គល់ សឿន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ក្នុងអំឡុងចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែកក្កដា ឆ្នាំ២០២២។
( ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ង៉ែត មោង្ស ៖ អតីតទាហានកន្សែងស

## រឹម ស្រីស្រស់



ង៉ែត មោង្ស សព្វថ្ងៃរស់នៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ង៉ែត មោង្ស អាយុ៧៧ឆ្នាំ ប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំកើតនៅភូមិភ្នំដិនឃុំភ្នំដិនស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់ ក្នុងនោះមានស្រី៣នាក់ ហើយសព្វថ្ងៃបងប្អូនរបស់ខ្ញុំនៅរស់តែ២នាក់ប៉ុណ្ណោះ។ កាលពីកុមារភាព ខ្ញុំរស់នៅជាមួយឪពុកម្តាយ និងចូលរៀននៅសាលាក្នុងភូមិភ្នំដិន ឃុំភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំរៀនដល់ត្រឹមថ្នាក់ទី១១។ នៅឆ្នាំ១៩៥៩ ខ្ញុំបានឈប់រៀនហើយមកជួយធ្វើស្រែចម្ការឪពុកម្តាយ ព្រោះឪពុកម្តាយរបស់ខ្ញុំមិនមានកម្លាំងគ្រប់គ្រាន់។

នៅឆ្នាំ១៩៦៧ ខ្ញុំបានចូលធ្វើទាហានកន្សែងសតាមការអូសទាញពីអ្នកនៅក្នុងភូមិ ហើយម៉្យាងទៀត ខ្ញុំក៏មានបំណងចង់ចូលដែរដើម្បីជាតិមាតុភូមិ។ យូរៗម្តង ខ្ញុំបានចូលរួមប្រជុំជាមួយសមាជិកឯទៀតនៅក្នុងអង្គភាព ហើយក្រៅពីប្រជុំ គឺខ្ញុំស្នាក់នៅផ្ទះ និងដើរធ្វើការតាមភូមិឃុំ ជាពិសេសភូមិឃុំដែលនៅជាប់ព្រំដែនវៀតណាម។ សមាជិករបស់ទាហានកន្សែងសមានទាំងខ្មែរក្រោម និងខ្មែរលើ។ កងរបស់ខ្ញុំគឺមានឈ្មោះ បេ.សេ.១១៦ (BC116)។

បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ កងទ័ពកន្សែងសបានសហការជាមួយកងទ័ព លន់ នល់ និងធ្វើសកម្មភាពកាន់តែផុសផុលជាងមុន។ នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការប្រពន្ធ។ បន្ទាប់ពីរៀបការបានរយៈពេល៩ខែ យោធាខ្មែរក្រហម បានចូលមកកាន់កាប់ខេត្តតាកែវទាំងមូល។ ខ្ញុំជាមួយប្រពន្ធ និងកូនម្នាក់របស់ខ្ញុំបានភៀសខ្លួនទៅប្រទេសវៀតណាម។ អ្នកភូមិជាច្រើននាក់ ក៏បានភៀសខ្លួនចេញដំណាលខ្ញុំដែរ។ ខ្ញុំទៅរស់នៅភូមិព្រៃស្វាយ ឃុំព្រៃស្វាយ ស្រុកស្វាយទង (ឬស្រុកទីតូង) ខេត្តមាត់ជ្រូក (ឬខេត្តចូវដុក)។ នៅទីនោះភាគច្រើនប្រជាជនខ្មែរកម្ពុជាក្រោមរស់នៅ។

ខ្ញុំទទួលបានអំណោយពីរដ្ឋអំណាចវៀតណាម ហើយកញ្ចប់អំណោយដែលខ្ញុំទទួលបាន គឺសរសេរអក្សរយូអេសអេ (USA)។ ខ្ញុំយល់ថា អំណោយទាំងនោះគឺជាជំនួយរបស់អាមេរិកាំង។ ក្រៅពីទទួលអំណោយប្រចាំខែ ខ្ញុំនិងគ្រួសារខិតខំរកស៊ីធ្វើស្រែចម្ការលើដីដែលរដ្ឋអំណាចវៀតណាមផ្តល់ឲ្យ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមប្រកាសថា នឹងធ្វើការដោះដូរ

ប្រជាជនជាមួយនឹងវៀតណាម។ ប្រជាជនខ្មែរទាំងអស់ដែលបានភៀសទៅប្រទេសវៀតណាមតាំងពីពីឆ្នាំ១៩៧៨ ក៏ត្រូវវិលត្រឡប់មកស្រុកកំណើតវិញដែរ។ ពេលនោះខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាវិញ។ មកដល់ព្រំដែន ខ្ញុំមិនឃើញមានជនជាតិវៀតណាមណាម្នាក់ឆ្លងកាត់ព្រំដែនចូលក្នុងប្រទេសរបស់ខ្លួនឡើយ។ ខ្មែរក្រហមបានយកឡានមកទទួលខ្ញុំ។ អ្នកបើកឡានមិនបានឈប់នៅភូមិកំណើតរបស់ខ្ញុំនៅស្រុកគិរីវង់ឡើយ គឺបើកបង្ហួសទៅកាន់ស្រុកត្រាំកក់ ជាកន្លែងដែលខ្ញុំស្នាក់នៅពេញមួយរបបខ្មែរក្រហម។ ខ្ញុំត្រូវបានអ្នកបើកបរខ្មែរក្រហមឲ្យចុះពីលើឡាន និងឲ្យស្នាក់នៅបណ្ដោះអាសន្ននៅភូមិខ្ពបត្របែក ឃុំអូរសារាយ មុននឹងបញ្ជូនខ្ញុំទៅកាន់ភូមិត្រពាំងដង់ទឹកបន្តទៀត។

មកដល់ដំបូង ខ្មែរក្រហមមិនឲ្យខ្ញុំហូបឆ្អែតទេ។ ប្រធានកងប្រើខ្ញុំឲ្យធ្វើស្រែ និងភ្ជួររាស់។ នៅពេលដែលខ្ញុំកំពុងធ្វើស្រែ ខ្ញុំឃើញកម្មាភិបាលខ្មែរក្រហមបណ្ដើរមនុស្សទាំងខ្សែកាត់តាមវាលស្រែចូលទៅក្នុងព្រៃ។ ខ្ញុំមិនដឹងថាកម្មាភិបាលខ្មែរក្រហមយកអ្នកទាំងនោះទៅកាន់ទីណាឡើយ។ ខ្ញុំគិតថាប្រហែលជាកម្មាភិបាលខ្មែរក្រហមនាំយកអ្នកទាំងនោះទៅសម្លាប់ចោល។ ខ្ញុំរស់នៅ និងធ្វើការងារគ្រប់យ៉ាងតាមតែកម្មាភិបាលប្រើឲ្យធ្វើ។ ខ្ញុំមិនដែលប្រកែក ឬស្ដីកស្រពន់ឡើយ។ ខ្ញុំតែងតែលាក់ប្រវត្តិរូបរបស់ខ្ញុំដែលធ្លាប់ធ្វើជាទាហានកន្សែងស។ ខ្ញុំដឹងច្បាស់ថា ប្រសិនបើខ្មែរក្រហមដឹងថាខ្ញុំគឺជាទាហានកន្សែងស ខ្ញុំប្រាកដជាស្លាប់ចោលប្រពន្ធកូនជាមិនខាន។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវផ្លាស់ប្ដូរទីកន្លែងរស់នៅម្ដងទៀត គឺមករស់នៅភូមិត្រាំកក់ ឃុំត្រាំកក់។ នៅឆ្នាំ១៩៧៨ដដែល មានយន្តហោះមកបាចត្រាក់នៅក្នុងស្រុកត្រាំកក់។ ខ្ញុំបានរើសត្រាក់នោះមកអាន ទើបដឹងថា មានការវាយរំដោះប្រជាជនកម្ពុជាចេញពីរបបខ្មែរក្រហម។ ភ្លាមៗបន្ទាប់ពីការបាចត្រាក់ កម្មាភិបាលខ្មែរក្រហមបានដើរប្រមូលត្រាក់ទាំងនោះពីប្រជាជន និងបានហាមប្រជាជនមិនឲ្យជជែកគ្នាពីអត្ថន័យដែលសរសេរនៅក្នុងត្រាក់នោះឡើយ។

មិនយូរប៉ុន្មាន ប្រទេសជាតិត្រូវបានរំដោះ ហើយខ្ញុំបានវិលត្រឡប់មកភូមិកំណើតវិញ។ ខ្ញុំរស់នៅឃុំភ្នំដិន ស្រុកគិរីវង់ បានមួយរយៈខ្លី ក៏ត្រូវបានកងទ័ពវៀតណាមចាប់ខ្លួនយកទៅសួរចម្លើយ និងដាក់គុក ព្រោះកងទ័ពវៀតណាមទាំងនោះសង្ស័យថា ខ្ញុំគឺជាកម្មាភិបាលខ្មែរក្រហម។ កងទ័ពវៀតណាមយកកាំភ្លើងវាយសួរចម្លើយខ្ញុំថា តើខ្ញុំចូលខ្មែរក្រហមតាំងពីពេលណា? និងដឹកនាំកងកម្លាំងបានប៉ុន្មានឆ្នាំហើយ? ខ្ញុំបានបដិសេធ និងប្រាប់ថា ខ្ញុំគឺជាប្រជាជនមិនមែនខ្មែរក្រហមទេ និងមិនដឹកនាំកម្លាំងអ្វីឡើយ។ ខ្ញុំត្រូវបានឃុំឃាំងនៅសាលាបឋមសិក្សាទន្លាប់ អស់រយៈពេល១៦ថ្ងៃ។ បន្ទាប់មក ខ្ញុំត្រូវបានដោះលែងឲ្យមករស់នៅជួបជុំប្រពន្ធកូនវិញ។ ខ្ញុំចាប់ផ្ដើមប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត។ មួយរយៈក្រោយមក គ្រួសាររបស់ខ្ញុំបានស្នើសុំផ្លាស់ប្ដូរទីលំនៅពីឃុំភ្នំដិន មកនៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ រហូតមកដល់សព្វថ្ងៃ។



ង៉ែត មោងរ្យ ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# កើត ឈុន ៖ អនុក្រុមនៅក្នុងរបបខ្មែរក្រហម

**ភា រស្មី**



កើត ឈុន រស់នៅភូមិពន្លៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ កើត ឈុន អាយុ៧៩ឆ្នាំ កើតនៅភូមិពន្លៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ កាលពីដើមគ្រួសាររបស់ខ្ញុំមានជីវភាពក្រីក្រ។ នៅអាយុ១២ឆ្នាំ ខ្ញុំចូលរៀនជាមួយព្រះសង្ឃនៅក្នុងវត្តពន្លៃ។ ខ្ញុំបានរៀនពេលសម្រាកពីធ្វើស្រែក្នុងរដូវប្រាំងប៉ុណ្ណោះ ចំណែករដូវវស្សា ខ្ញុំត្រូវទៅជួយឪពុកខ្ញុំភ្ជួរស្រែ។ ខ្ញុំរៀននៅក្នុងវត្តពន្លៃរហូតដល់អាយុ២២ឆ្នាំ ទើបខ្ញុំសម្រេចចិត្តចូលបួសនៅវត្តពន្លៃបន្តទៀត។ ខ្ញុំចូលបួសនៅក្នុងវត្តពន្លៃបានរយៈពេលពីរព្រះវស្សា និងរៀនធម៌បាលី អានសាស្ត្រាផ្សេងៗទើបខ្ញុំសម្រេចចិត្តសឹក ដើម្បីមកជួយធ្វើស្រែឪពុករបស់ខ្ញុំបន្តទៀត ព្រោះគាត់ឈឺជាញឹកញាប់។

បន្ទាប់ពីសឹកបានរយៈពេលមួយឆ្នាំ នៅឆ្នាំ១៩៦៨ ខ្ញុំរៀបការជាមួយឈ្មោះ ម៉ែន ហន ប្រពន្ធរបស់ខ្ញុំសព្វថ្ងៃ ដែលជាអ្នកភូមិពន្លៃជាមួយគ្នា។ ក្រោយពីរៀបការរួច យើងចាប់ផ្ដើមធ្វើស្រែដើម្បីចិញ្ចឹមជីវិត។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ខ្ញុំរស់នៅក្នុងភូមិដដែល ប៉ុន្តែមានប្អូនប្រុសរបស់ខ្ញុំម្នាក់បានរត់ចូលព្រៃម៉ាគីជាមួយយុវជនផ្សេងទៀត ដើម្បីតស៊ូយកអំណាចថ្វាយព្រះអង្គវិញ។ មួយរយៈក្រោយមកក៏មានការទម្លាក់គ្រាប់ និងផ្លោងគ្រាប់ចូលក្នុងភូមិពន្លៃជាញឹកញាប់ ហេតុនេះហើយបានជាគ្រួសារខ្ញុំ និងអ្នកភូមិផ្សេងទៀតនាំគ្នារត់ចូលក្នុងលេណដ្ឋាននៅខាងក្រៅភូមិដើម្បីលាក់ខ្លួន។

នៅចន្លោះពីឆ្នាំ១៩៧៣ ដល់ ឆ្នាំ១៩៧៤ ការទម្លាក់គ្រាប់បែកនៅក្នុងភូមិពន្លៃមានសភាពស្ងប់ស្ងាត់ ទើបខ្ញុំអាចប្រកបរបរធ្វើស្រែបានធម្មតា និងឆ្លៀតពេលជួញដូរគោក្របីទៅខាង លន់ នល់។ ខ្ញុំធ្វើជំនួញមិនបានប៉ុន្មាន សេនាជនភូមិពន្លៃមកចាប់ខ្លួនខ្ញុំ និងចោទខ្ញុំថាជាក្រុមខ្មែរស។ ក្រោយមក ឈ្មោះ ផុន គឺជាប្រធានសហករណ៍ក្នុងភូមិពន្លៃមកជួយនិយាយសម្រួលជាមួយសេនាជនភូមិ ទើបខ្ញុំបានរួចខ្លួន។

អំឡុងពេលនោះខ្ញុំក៏ស្គាល់គណៈគ្រប់គ្រងភូមិពន្លៃជាច្រើននាក់ដែរ ព្រោះ ផុន តែងតែហៅខ្ញុំទៅសម្លាប់សត្វជ្រូក ឬ គោ ផ្ដល់ឲ្យទៅខាងរោងបាយ។ ជាធម្មតានៅពេលខ្ញុំសម្លាប់សត្វឲ្យអង្គការ ប្រធានសហករណ៍តែងតែឲ្យស្រាមកខ្ញុំផឹក ហើយខ្ញុំអាចយកសាច់បន្តិចបន្តួចមកផ្ញើប្រពន្ធកូននៅផ្ទះ ប៉ុន្តែខ្ញុំត្រូវលាក់ការណ៍ឲ្យស្ងាត់បំផុត។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីយោធាខ្មែរក្រហមវាយដណ្ដើមបានទីក្រុងភ្នំពេញ អង្គការប្រើ

ខ្ញុំឲ្យទៅធ្វើការនៅកងភ្ជួរ។ ក្នុងមួយភូមិពន្លៃមានអ្នកភ្ជួរបល័តចំនួន ៥នាក់ និងមានទន្លីលចំនួន ៥ ។ យើងដើរភ្ជួរបល័តពីភូមិមួយ ទៅភូមិមួយទៀតនៅក្នុងឃុំអង្គរសទាំងមូល។ ចំណែករដូវប្រាំង ខ្ញុំត្រូវទៅជីកប្រឡាយ និងលើកទំនប់នៅក្បែរៗភូមិ។

នៅដើមឆ្នាំ១៩៧៧ ខ្ញុំឃើញមានកម្មាភិបាលខ្មែរក្រហមមកពីខាងស្វាយរៀង បណ្ដើរប្រជាជនយកមកសម្លាប់នៅជិតភូមិរបស់ខ្ញុំចំនួន ៣លើក ហើយមួយលើកៗមានប្រជាជនប្រមាណ៦នាក់។ កន្លែងដែលខ្មែរក្រហមសម្លាប់មនុស្សមានឈ្មោះថា ភូមិតាកែនដែលមានចម្ងាយប្រមាណកន្លះគីឡូម៉ែត្រពីផ្ទះរបស់ខ្ញុំ។ កម្មាភិបាលខ្មែរក្រហមសម្លាប់មនុស្សរួច ទម្លាក់ចូលទៅក្នុងរណ្ដៅមួយមានសាកសពប្រមាណ៣០នាក់។

នៅចុងឆ្នាំ១៩៧៧ នៅក្នុងភូមិខ្ញុំចាប់ផ្ដើមមានការផ្លាស់ប្ដូរអ្នកគ្រប់គ្រងឃុំ។ នៅពេលនោះប្រធានសហ-ករណ៍ថ្មីឈ្មោះ ង៉ាន់ ឈប់ឲ្យខ្ញុំកាន់ទន្លីលរួចបញ្ជូនខ្ញុំឲ្យទៅជីកប្រឡាយនៅកោះទៀរយៈពេល ៣ខែ។ នៅពេលត្រឡប់មកភូមិពន្លៃវិញឈ្មោះ ង៉ាន់ ចាត់តាំងខ្ញុំឲ្យធ្វើជាអនុក្រុម និងគ្រប់គ្រងប្រជាជនចំនួន១២គ្រួសារ។ តួនាទីជាអនុក្រុម គឺចាំទទួលការងារពីប្រធានសហករណ៍ រួចដាក់ការងារបន្តទៅ សមាជិកនៅក្នុងក្រុមធ្វើ។

នៅពេលនោះ ក្នុងភូមិពន្លៃក៏មានការជម្លៀសប្រជាជនចេញដែរ គឺលើកទី១ជម្លៀសប្រជាជនចេញនៅចុងឆ្នាំ១៩៧៧ ដែលភាគច្រើនគឺប្រជាជន១៧មេសា និងលើកទី២ ចាប់ផ្ដើមជម្លៀសប្រជាជនទៅតំបន់ដីខ្លាញ់នៅចុងឆ្នាំ១៩៧៨។ ប្រជាជននៅក្នុងភូមិពន្លៃដែលត្រូវបានអង្គការជម្លៀសទៅតំបន់ដីខ្លាញ់ទាំងពីរលើកមានចំនួន៦០គ្រួសារ។ ការជម្លៀសលើកទី២ គឺជម្លៀសប្រជាជនមូលដ្ឋានហើយក្នុងនោះក៏មានគ្រួសារឪពុកម្ដាយក្មេករបស់ខ្ញុំទៅជាមួយដែរ។

នៅដើមខែមករា ឆ្នាំ១៩៧៩ អង្គការជម្លៀសប្រជាជនឲ្យចេញពីភូមិទាំងអស់ ហើយគ្រួសារខ្ញុំបានធ្វើដំណើរទៅដល់អ្នកលឿងទើបត្រឡប់មកផ្ទះវិញ។ ពេលមកដល់ភូមិ ខ្ញុំមិនសូវបានស្នាក់នៅផ្ទះជាប់លាប់ទេព្រោះខ្លាចក្រែងលោគ្រួសារដែលអង្គការជម្លៀសទៅតំបន់ដីខ្លាញ់ ត្រឡប់មកវិញចងគំនុំមករករឿង និងសម្លាប់ខ្ញុំព្រោះខ្ញុំគឺជាអ្នកទៅប្រាប់ឲ្យប្រជាជនទាំងនោះជម្លៀសទៅខេត្តភាគខាងលិច។ ក្រោយមកប្រជាជនបានរសាយកំហឹង ហើយនៅឆ្នាំ១៩៨១ ខ្ញុំចាប់ផ្ដើមរកស៊ីជួញគោ-ក្របីបន្ថែមពីលើការងារធ្វើស្រែ ទើបជីវភាពគ្រួសាររបស់ខ្ញុំបានធូរធាររហូតមកដល់សព្វថ្ងៃ។



កើត ឈុន ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវជីវិតរបស់ខ្លួនក្នុងរបបខ្មែរក្រហមដល់ ភា រស្មី បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង អំឡុងពេលចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែកក្កដា ឆ្នាំ២០២២។
(ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# លីម អេង ៖ អតីតកងនេសាទក្នុងរបបខ្មែរក្រហម

***អេង ខណ្ណារីកា***




*លីម អេង អាយុ៧៥ឆ្នាំ រស់នៅក្នុងភូមិទី៩ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ លីម អេង អាយុ៧៥ឆ្នាំ រស់នៅក្នុងភូមិទី៩ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំគឺជាកសិករ ប៉ុន្តែដោយសារតែជរាភាព ខ្ញុំមិនអាចប្រកបរបរនេះបានទៀតទេ។ ខ្ញុំរៀបការប្រពន្ធឈ្មោះ សេត ឡាង និងមានកូនចំនួន៦នាក់។ ខ្ញុំកើតនៅភូមិទី ៩ ឃុំកោះសូទិន ស្រុកកោះសូទិននេះតែម្តង។ ខ្ញុំមានឪពុកឈ្មោះ គុយ លីម និងម្តាយឈ្មោះ អោ សេន។ ខ្ញុំគឺជាកូនច្បង ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៥នាក់។ នៅវ័យកុមារ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាវត្តចុងកោះសូទិន និងបន្តការសិក្សានៅទីរួមខេត្តកំពង់ចាម។ ខ្ញុំរៀននៅសាលាឯកជនមួយដើម្បីត្រៀមប្រឡងចូលថ្នាក់ទីពាសន្តមចាស់។ ក្រោយមកខ្ញុំសម្រេចចិត្តទៅរៀននៅសាលាព្រែកដំណឹងក្នុងស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែងវិញ ពីព្រោះខ្ញុំមានឪពុកមារស់នៅទីនោះ។ នៅពេលដែលខ្ញុំកំពុងស្នាក់នៅ និងរៀននៅស្រុកស៊ីធរកណ្តាល ខ្ញុំឮដំណឹងថាមានរដ្ឋប្រហារទម្លាក់សម្តេចឪ។ បន្ទាប់មកបងប្អូនរបស់ខ្ញុំមកបបួលខ្ញុំចូលធ្វើជាទាហាន លន់ នល់ នៅទីក្រុងភ្នំពេញ។ ខ្ញុំមិនបានចូលធ្វើទាហានទេ។ បាតុកម្មបានផ្ទុះឡើង និងដង្ហែរទៅទីរួមខេត្តកំពង់ចាម។ ដោយឃើញស្ថានភាពមិនស្រួល ខ្ញុំបានវិលត្រឡប់មករស់នៅជួបជុំគ្រួសារនៅភូមិកំណើតវិញ។

នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមបានចូលមកក្នុងភូមិ និងស្នាក់អាស្រ័យនៅក្រោមផ្ទះ និងក្រោយផ្ទះរបស់អ្នកភូមិ។ ពេលនោះគឺជាវេលានៃការផ្ទុះអាវុធរវាងទាហាន លន់ នល់ ដែលឈរជើងនៅទីរួមខេត្តកំពង់ចាម និងកងទ័ពរំដោះខ្មែរក្រហមដែលឈរជើងនៅតាមភូមិនានា ក្នុងស្រុកកោះ

សូទិន។ ភូមិទី៩ ទទួលរងគ្រាប់ផ្លោងយ៉ាងសន្ធឹកសន្ធាប់ដែលបានផ្លោងចេញពីភ្នំស្រីភ្នំប្រុស។ នៅក្នុងឆ្នាំ១៩៧១ ដដែល គ្រួសាររបស់ខ្ញុំបានរត់ភៀសខ្លួនចេញពីភូមិ ទៅរស់នៅជាមួយបងប្អូននៅភូមិជ្រែកឃ្មុំ ឃុំជ្រែកឃ្មុំ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដែលជាតំបន់រំដោះខ្មែរក្រហម។ បន្ទាប់ពីបានទៅដល់ទីនោះ ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើជាគ្រូបង្រៀននៅមូលដ្ឋាន។ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅរៀនវគ្គបណ្តុះបណ្តាលអស់រយៈពេល ៣ខែ ថែមទៀត។ បន្ទាប់ពីវគ្គបណ្តុះបណ្តាលបានបញ្ចប់ ខ្ញុំបានបង្រៀនថ្នាក់ទី៣ នៅសាលាបឋមសិក្សាស្វាយទាប ដែលមានមិត្តឈាន គឺជានាយកសាលា។

នៅឆ្នាំ១៩៧៣ ខ្ញុំរៀបការប្រពន្ធឈ្មោះ សេតឡាង និងទៅរស់នៅជាមួយគ្រួសារខាងប្រពន្ធ។ ដោយសារតែផ្ទះគ្រួសារខាងប្រពន្ធស្ថិតនៅឆ្ងាយ ខ្ញុំបានឈប់បង្រៀន។ ក្រោយមកទៀត ខ្ញុំស្ម័គ្រចិត្តចូលធ្វើជាពេទ្យ និងត្រូវបានបញ្ជូនទៅរៀនវគ្គបណ្តុះបណ្តាលរយៈពេល ៣ខែ បន្ថែមទៀត អំពីការចាក់ថ្នាំ ផ្សំថ្នាំ និងពិនិត្យមើលអាការជំងឺ។ បន្ទាប់ពីរៀនចប់ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាពេទ្យប្រចាំភូមិដើម្បីពិនិត្យ និងព្យាបាលប្រជាជនមូលដ្ឋាន។ នៅចុងឆ្នាំ១៩៧៣ មេភូមិ ដែលខ្ញុំមិនបានចាំឈ្មោះ បានជ្រើសរើសពេទ្យជំនាញវះកាត់។ នៅពេលនោះ បងថ្លៃខ្ញុំដែលជាពេទ្យមូលដ្ឋាន បានស្ម័គ្រចិត្តចូលរៀនជំនាញពេទ្យវះកាត់ និងត្រូវបានបញ្ជូនទៅរៀនបន្ត ប៉ុន្តែបងថ្លៃរបស់ខ្ញុំ មិនដែលវិលត្រឡប់មកភូមិវិញទេ។ នៅឆ្នាំ១៩៧៤ ខ្ញុំនាំប្រពន្ធ និងកូនមករស់នៅភូមិទី៩ ដែលជាភូមិកំណើតវិញ។ នៅពេលដែលខ្ញុំត្រៀមឆ្លងទន្លេមកភូមិ ម៉ារីន ទាហានលន់ នល់ បានបើកល្បាតចុះឡើងពិនិត្យមើលសភាពការណ៍ បន្ទាប់មក ក៏បន្តដំណើរទៅក្រុងកំពង់ចាម។ ខ្ញុំនិងប្រពន្ធកូន ស្នាក់នៅម្តុំកោះចិនមួយយប់សិន។ នៅពេលដែលសភាពការណ៍ស្ងប់ស្ងាត់ទើប ខ្ញុំនិងប្រពន្ធកូនជួលទូកជិះឆ្លងទន្លេមករស់នៅក្នុងភូមិកំណើត រហូតដល់ខ្មែរក្រហមទទួលជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា នៅឆ្នាំ១៩៧៥។

នៅឆ្នាំ១៩៧៦ ខ្ញុំនិងអ្នកភូមិផ្សេងទៀតចាប់ផ្តើមហូបបាយរួម។ ក្រោយមក ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅកងនេសាទភូមិ ដែលមានសមាជិកចំនួន ១០នាក់ ដើម្បីរកត្រីមកឲ្យរោងបាយ។ កងនេសាទក៏មានខ្មែរ-អ៊ីស្លាម ដូចជា មិត្តលាស់ មិត្តកូប និងមិត្ត ម៉ាន ដែលជាអ្នកជំនាញជួសមង ឬដោះមងដែលជាប់នៅបាតទន្លេដែរ។ ប្រធានកងនេសាទនៅពេលនោះ ឈ្មោះ វែង ថៃ, លាស់, កូប និង ម៉ាន។ កងនេសាទរបស់ខ្ញុំ គឺធ្វើការចាប់ពីពាក់កណ្តាលអធ្រាត្រ ដោយបានរាយមងនៅកណ្តាលទន្លេ បន្ទាប់មកទើបចូលមកសម្រាកវិញ។ រហូតដល់ម៉ោង៦ព្រឹក កងនេសាទបានបែរទូកទៅលើកមង និងប្រមូលបានត្រីគល់រាំង ត្រីក្អែក និងត្រីព្រួល ជាដើម។ បន្ទាប់មក កងដឹកជញ្ជូនបានដឹកត្រីដែលកងនេសាទរកបាន ទៅដាក់នៅរោងបាយរួមដើម្បីធ្វើម្ហូបឲ្យអ្នកភូមិ។

នៅឆ្នាំ១៩៧៧ ខ្ញុំឃើញកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតី ទាំងក្មេងចាស់ចូលមកក្នុងភូមិ។ ខ្ញុំមិនហ៊ាននិយាយរក និងមើលមុខកងទ័ពខ្មែរក្រហមទាំងនោះទេ។ ខ្ញុំបន្តធ្វើការនៅកងនេសាទ និងពេលខ្លះ ខ្ញុំបានសុំច្បាប់មកលេងប្រពន្ធ និងកូននៅផ្ទះ។ ក្រោយមក មិត្តលាស់ មិត្តកូប និងមិត្តម៉ាន នៅកងនេសាទភូមិ ត្រូវបានចាប់ខ្លួនយកទៅសម្លាប់។ ខ្ញុំមិនដឹងថាខ្មែរក្រហមសម្លាប់អ្នកទាំងនោះនៅកន្លែងណាទេ។ ខ្ញុំធ្វើការនៅកងនេសាទ រហូតដល់កងទ័ពវៀតណាមចូលមកនៅដើមឆ្នាំ១៩៧៩។ ខ្ញុំនិងគ្រួសាររួចផុតពីជីវិតពីរបបខ្មែរក្រហម និងប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិតរហូតមកដល់ពេលបច្ចុប្បន្ននេះ។

# សោម គង់ ៖ កងមនុស្សចាស់

សៀង កញ្ញា



សោម គង់ អាយុ៧៣ឆ្នាំ រស់នៅក្នុងភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សោម គង់ អាយុ៧៣ឆ្នាំ រស់នៅក្នុងភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ បានរៀបរាប់ថា ខ្ញុំមានបងប្អូនបង្កើតចំនួន៧ នាក់ បច្ចុប្បន្ននៅរស់ ៣នាក់។ កាលពីកុមារ ខ្ញុំចូលរៀននៅសាលាវត្តត្រពាំងធំ ត្រឹមថ្នាក់ទី៧ ក៏ឈប់រៀន ហើយមកជួយការងារឪពុកម្តាយ។

ខ្ញុំរៀបការនៅអំឡុងពេលកើតមានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ បន្ទាប់ពីរដ្ឋប្រហារ មានព្រឹត្តិការណ៍ទម្លាក់គ្រាប់បែក និងទម្លាក់គ្រាប់ណាប៉ាល់ មកលើភូមិរបស់ខ្ញុំ។ ផ្ទះរបស់ខ្ញុំ ត្រូវឆេះអស់គ្មានសល់ ដោយសារតែគ្រាប់ណាប៉ាល់។ ផ្ទះអ្នកភូមិជាច្រើនខ្នងទៀតក៏ឆេះដូចគ្នាដែរ ប៉ុន្តែមិនមានមនុស្សស្លាប់ឡើយ។ ចាប់តាំងពីថ្ងៃរដ្ឋប្រហារមក ប្រជាជនមិនហ៊ានរស់នៅក្នុងផ្ទះទេ ព្រោះប្រជាជនដឹងថានឹងមានការទម្លាក់គ្រាប់បែកកើតឡើង។ ប្រជាជននាំគ្នារត់ចូលទៅលាក់ខ្លួននៅក្នុងត្រង់សេ (លេណដ្ឋាន) ស្ទើររៀងរាល់ថ្ងៃ។ ស្ថិតនៅក្នុងស្ថានភាពច្របូកច្របល់នោះ ក្រុមចលនាបដិវត្តន៍ខ្មែរក្រហមបានហៅប្រជាជនទៅប្រជុំជាញឹកញាប់ ដើម្បីបញ្ចុះបញ្ចូលប្រជាជនឲ្យចូលរួមជាមួយក្រុមរបស់ខ្លួនប្រឆាំងនឹងរបប លន់ នល់។

ខ្ញុំមិនបានចូលប្រជុំជាមួយខ្មែរក្រហមទេ ហើយក៏មិនបានស្ម័គ្រចិត្តចូលបម្រើខ្មែរក្រហមដែរ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញខ្មែរក្រហមជម្លៀសប្រជាជនថ្មីជាច្រើនគ្រួសារឲ្យមករស់នៅក្នុងភូមិត្រពាំងឈូក។ ប្រជាជនថ្មីទាំងនោះ មិនត្រូវបានអនុញ្ញាតឲ្យរស់នៅ លាយឡំជាមួយនឹងប្រជាជនមូលដ្ឋានឡើយ ប៉ុន្តែអាចធ្វើការងារជាមួយប្រជាជនមូលដ្ឋានបាន។ ខ្ញុំត្រូវកម្មាភិបាលខ្មែរក្រហមថ្នាក់មូលដ្ឋានចាត់តាំងឲ្យធ្វើការនៅក្នុងកងតាៗ ប៉ុន្តែនៅពេលនោះ ក៏មានប្រជាជនវ័យកណ្តាល និងយុវជនក្នុងកងនោះដែរ។ កិច្ចការងាររបស់ខ្ញុំនៅក្នុងកងតាតា គឺធ្វើស្រែ ចម្ការ ភ្ជួររាស់ រែកដី និងកាប់ដី។

នៅឆ្នាំ១៩៧៨ ខ្ញុំ និងប្រជាជនមូលដ្ឋានមួយចំនួនទៀតដែលរស់នៅក្នុងឃុំត្រពាំងធំខាងត្បូង ត្រូវបានកម្មាភិបាលខ្មែរក្រហមថ្នាក់មូលដ្ឋានឈ្មោះ ម៉ែន ផ្លាស់ឲ្យទៅរស់នៅភូមិភាគបូព៌ា ក្នុងខេត្តកំពង់ចាម។



សោម គង់ (រូបខាងស្ដាំ) ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សោម គង់ ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ែន មិនបានប្រាប់ខ្ញុំថា ទៅធ្វើអ្វីនៅនោះឡើយ។ ពេលនោះ ខ្ញុំរួមជាមួយប្រពន្ធ និង កូនមួយនាក់ទៀត បានស្នាក់នៅតែក្នុងផ្ទះដែលអង្គការចែកឲ្យ ដោយមិនទាន់ទទួលការចាត់តាំងការងារពីអង្គការឡើយ។ មិនយូរប៉ុន្មាន ក៏កើតមានព្រឹត្តិការណ៍វាយប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាម។ ខ្ញុំនិងគ្រួសារ បានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ ពេលចូលមកដល់ស្រុកកំណើត ផ្ទះ និងដីរបស់ខ្ញុំត្រូវអ្នកភូមិផ្សេងទៀតយកធ្វើជាកម្មសិទ្ធិ ដូច្នេះ ខ្ញុំនិងគ្រួសារត្រូវបង្ខំចិត្តទៅរកទីតាំងថ្មីដើម្បីរស់នៅ ហើយខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ និងរត់ម៉ូតូឌុបដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។

# ស៊ីង គីមស្រ៊ុន ៖ អតីតកងចល័តវ័យកណ្តាល

**ទូច វណ្ណេត**



*ស៊ីង គីមស្រ៊ុន អាយុ៧២ឆ្នាំ រស់នៅក្នុងភូមិទី៨ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ( ស៊ាង ចិន្ដា/មជ្ឈមណ្ឌលឯកសារកម្ពុជា )*

ខ្ញុំឈ្មោះ ស៊ីង គីមស្រ៊ុន អាយុ ៧២ឆ្នាំ រស់នៅក្នុងភូមិទី៨ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានមុខរបរជាកសិករធ្វើស្រែចម្ការ។ ខ្ញុំមានភូមិកំណើតនៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ កៅ ឡេង និងម្ដាយឈ្មោះ ពិន ស្រ៊ី។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៧ នាក់។ នៅវ័យកុមារ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាគ្រូអ៊ុក។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ចាស់។ ខ្ញុំឈប់រៀននៅអាយុ១៣ឆ្នាំ ដើម្បីមកជួយការងារឪពុកម្ដាយនៅផ្ទះ និងមើលប្អូនៗ។ នៅអាយុ១៥ឆ្នាំ ខ្ញុំរៀបការប្ដី ធ្វើជាប៉ូលីសនៅដីហែ។ ខ្ញុំទៅរស់នៅជាមួយប្ដីនៅដីហែរ។ មួយរយៈក្រោយមកប្ដីរបស់ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការនៅត្រពាំងថ្កុង។ នៅពេលនោះ ខ្ញុំបង្កើតកូនបានមួយនាក់ និងវិលមករស់នៅដីហែរវិញ។

បន្ទាប់ពីមានរដ្ឋប្រហាររបស់ លន់ នល់ នៅដើមឆ្នាំ១៩៧០ បាតុកម្មបានផ្ទុះឡើង និងដង្ហែរទៅទីរួមខេត្តកំពង់ចាម។ អ្នកភូមិជាច្រើនបានចូលរួមបាតុកម្មនោះ។ ចំណែកខ្ញុំបានមករស់នៅផ្ទះជាមួយម្ដាយខ្ញុំនៅស្រុកកោះសូទិន។ នៅឆ្នាំ១៩៧១ ខ្ញុំឃើញកងទ័ពរំដោះខ្មែរក្រហមចូលមកដល់ភូមិ ហើយប្ដីរបស់ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការងារនៅភ័ស្តុភារនៅខេត្តព្រៃវែង។ នៅពេលនោះ ប្ដីរបស់ខ្ញុំមិនដែលមកលេងផ្ទះនៅកោះសូទិនទេ។ នៅឆ្នាំ១៩៧៣

ភូមិទី៨ គឺជាសមរភូមិក្តៅរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ ទាហានលន់ នល់ បានទម្លាក់គ្រាប់បែកជាច្រើន ទៅលើទីតាំងដែលមានកងទ័ពរំដោះខ្មែរក្រហមលាក់ខ្លួន។ នៅឆ្នាំ១៩៧៤ ខ្ញុំរត់គេចខ្លួនជាមួយកូនទៅរស់នៅជាមួយប្តីដែលទើបតែត្រូវបានផ្លាស់មកនៅស្រុកអូររាំងឪ។ នៅឆ្នាំ១៩៧៥ ខ្ញុំដឹងដំណឹងថាម្តាយរបស់ខ្ញុំដែលរស់នៅកោះសូទិនបានស្លាប់។ ខ្ញុំបាននាំកូន និងប្អូនតូចត្រឡប់មកភូមិវិញ ដោយបានដើរពីអូររាំងឪ រហូតមកដល់កោះចិន និងឆ្លងទៅខាងកោះសូទិន នៅព្រឹកបន្ទាប់។ នៅឆ្នាំ១៩៧៦ អង្គការបាត់តាំងខ្ញុំឲ្យធ្វើការងារនៅកងចល័តវ័យកណ្តាល ដោយឲ្យដើរទៅរែកដី ជីកប្រឡាយ ស្ទូងស្រូវ កាត់ថ្នាំ និងកាប់ពោត។ ខ្ញុំត្រូវក្រោកនៅម៉ោង៤ព្រឹក ដើម្បីតម្រង់ជួរ និងចាប់ផ្តើមធ្វើការនៅម៉ោង៦ដល់ម៉ោង១១ព្រឹក និងពីម៉ោង១ដល់ម៉ោង៥ល្ងាច។ ខ្ញុំទទួលបានរបបអាហារត្រឹមតែបបររាវប៉ុណ្ណោះ។

នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកគ្រប់គ្រង និងចាប់ផ្តើមចាប់ខ្លួនប្រធានកង មេភូមិ និងប្រជាជន១៧មេសាដើម្បីយកទៅសម្លាប់ចោល។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានដាក់ជាប្រជាជនត្រៀម គឺជាក្រុមប្រជាជនដែលខ្មែរក្រហមយកទៅសម្លាប់នាពេលឆាប់ៗខាងមុខនេះ។ មានប្រជាជនចាស់ និងប្រជាជន ១៧មេសា ជាច្រើនត្រូវបានចាប់ខ្លួនយកទៅសម្លាប់នាពេលនោះដែរ។ ខ្ញុំធ្វើការនៅក្នុងកងចល័តវ័យកណ្តាល រហូតដល់ពេលដែលកងទ័ពវៀតណាមចូលមកនៅដើមឆ្នាំ១៩៧៩។ ខ្ញុំរួចផុតពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហម និងប្រកបរបរជាកសិកររហូតដល់សព្វថ្ងៃ។



ជនជាតិភាគតិចចាមរស់នៅលើទូកតាមបណ្តោយដងទន្លេមេគង្គ ស្ថិតនៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។ ( ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ខ្ញុំខឹងប្រធានកងធ្វើបាបទើបសុំចូលធ្វើកងទ័ព

ចាន់ ឌីន



យុត ខេម អាយុ៦៣ឆ្នាំ រស់នៅភូមិត្រពាំងរមាំង ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យុត ខេម អាយុ៦៣ឆ្នាំ កើតនៅភូមិត្រពាំងរមាំង (បច្ចុប្បន្នភូមិត្រពាំងតាសោម) ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ សព្វថ្ងៃខ្ញុំរស់នៅភូមិឃុំដដែល និងប្រកបរបរជាកសិករ។ ខ្ញុំមានប្រពន្ធឈ្មោះ ប៉ក់ សារឿន អាយុ៦៧ឆ្នាំ និងកូនចំនួនប្រាំមួយនាក់ ស្រីបួននាក់។

នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមឈ្មោះ រ៉ុធ ដែលជាប្រធានកង ប្រើខ្ញុំឲ្យរែកដី និងជីកប្រឡាយស្ថិតនៅខាងជើងវត្តកោះក្អែករហូតមកដល់ខ្ទបត្របែក។ ថ្ងៃមួយពេលកំពុងធ្វើការ ខ្ញុំបានឈ្លោះប្រកែកគ្នាជាមួយក្មេងម្នាក់ទៀត ហើយខ្ញុំបានយកដងរែកវាយទៅលើក្បាលក្មេងម្នាក់នោះ។ មេកងបានឃើញខ្ញុំវាយទៅលើក្មេងនោះ ក៏ចាប់ចងខ្ញុំភ្ជាប់ទៅនឹងដើមត្នោត ទុករហូតដល់យប់ទើបដោះលែងខ្ញុំវិញ។ ខ្ញុំខឹងនឹងមេកងនោះណាស់។ ថ្ងៃមួយ ខ្ញុំបានលួចរត់ទៅកាន់អង្គភាពទ័ពស្រុក ដែលមានទីតាំងស្ថិតនៅឃុំអង្គតាសោម ដើម្បីសុំចូលធ្វើជាយោធា។ ពេលនោះខ្ញុំមិនទាន់បានចូលធ្វើកងទ័ពភ្លាមៗទេ គឺត្រូវមេបញ្ជាការអង្គភាពទ័ពស្រុកប្រើខ្ញុំឲ្យឃ្វាលគោចិញ្ចឹមមាន់ទា និងដាំបន្លែ ដើម្បីផ្គត់ផ្គង់ទៅដល់កងទ័ព។ បន្ទាប់មក ខ្ញុំបានចូលបម្រើកងទ័ពខ្មែរក្រហម ហើយត្រូវបានមេបញ្ជាការបញ្ជូនខ្ញុំទៅកាន់ភូមិទួលស្វាយព្រៃ ឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ ដើម្បីការពារព្រំដែន។

រយៈពេលជាច្រើនខែក្រោយមក គឺនៅក្នុងខែវស្សា ឆ្នាំ១៩៧៨ ខ្ញុំត្រូវបានមេបញ្ជាការទ័ពស្រុកបញ្ជូនឲ្យមកឈរជើងនៅភូមិបន្ទាយធ្លាយ ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ ដើម្បីត្រៀមប្រយុទ្ធជាមួយវៀតណាម។ នៅរដូវទឹកស្រក ខ្ញុំបានលួចគេចចេញពីមូលដ្ឋានកងទ័ពនៅស្រុកកោះអណ្តែតជាមួយមិត្តម្នាក់ឈ្មោះ ពោច ប៉ុន្តែ ខ្ញុំ និង ពោច ត្រូវកម្មាភិបាលខ្មែរក្រហមចាប់ខ្លួននៅភូមិអូរចំបក់។ ខ្ញុំបានកុហកកម្មាភិបាលទាំងនោះថា អង្គភាពទ័ពរបស់ខ្ញុំមានមូលដ្ឋាននៅភូមិទួលស្វាយព្រៃ។ ដូច្នេះ កម្មាភិបាលទាំងនោះបានបញ្ជូនខ្ញុំនិងពោចមកភូមិស្វាយព្រៃវិញ។

មកដល់ទួលស្វាយព្រៃ ប្រធានមន្ទីរស្វាយព្រៃឈ្មោះ គា បានបញ្ជូនខ្ញុំបន្តទៅអង្គការសោម ជាទីកន្លែងដែលខ្ញុំនិង ពោច ត្រូវបានបង្ខំឲ្យចូលធ្វើជាយោធាម្តងទៀតដើម្បីទៅចូលរួមប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាម នៅភូមិភាគបូព៌ា។ នៅពេលអ្នកបើកឡានហៀបនឹងដឹកកងទ័ពចេញទៅខាងបូព៌ា ខ្ញុំបានរត់គេចខ្លួនម្តងទៀត។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងឪពុកម្តាយ ព្រមទាំងប្អូនពីរនាក់ទៀត បានភៀសខ្លួនទៅដល់ភូមិ ពករុន ឃុំពោធិ៍ចំរើន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ រួចហើយបន្តដំណើរទៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ព្រោះខ្លាចកងទ័ពវៀតណាមសម្លាប់។ មួយរយៈក្រោយមក ខ្ញុំនិងគ្រួសារបានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ ដោយមានកងទ័ពវៀតណាមជាអ្នកជួយដឹកជញ្ជូន និងផ្តល់អាហារឲ្យហូបចុកតាមផ្លូវ។



ជួរភ្នំដំរីរមៀលមើលពីចម្ងាយ ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ភ្នំដំរីរមៀល ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ចាប គីមណា ៖ កងនារីក្នុងរបបខ្មែរក្រហម

## *សៀង កញ្ញា*



ចាប គីមណា អាយុ៧០ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ចាប គីមណា អាយុ៧០ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ចាប ឃីត និងម្ដាយឈ្មោះ សេង សំ។ បងប្អូនបង្កើតរបស់ខ្ញុំមានចំនួន១០នាក់។ សព្វថ្ងៃនៅរស់តែប្អូននាក់ប៉ុណ្ណោះ ដោយសារក្រោយរដ្ឋប្រហារទម្លាក់សម្ដេច ព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្អូនបង្កើតរបស់ខ្ញុំប្រាំនាក់បានចូលធ្វើកងទ័ពខ្មែរក្រហមតាមការស្នើសុំរបស់ប្រធានភូមិ ហើយចាប់តាំងពីចេញពីផ្ទះទៅធ្វើទ័ព ប្អូនរបស់ខ្ញុំទាំងប្រាំនាក់មិនដែលឃើញវិលត្រឡប់មកផ្ទះវិញ រហូតមកទល់សព្វថ្ងៃនេះ។ ខ្ញុំមិនដឹងថាប្អូនរបស់ខ្ញុំនៅឯណា និងស្លាប់ឬរស់នោះទេ។

បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញមានប្រជាជនថ្មីជាច្រើនបានមកដល់ភូមិរបស់ខ្ញុំ។ ខ្ញុំមិនហ៊ានសួរនាំអ្នកទាំងនោះទេ ព្រោះខ្លាចខ្មែរក្រហមយកខ្ញុំទៅសម្លាប់ចោល។ ទាំងប្រជាជនមូលដ្ឋាន និងប្រជាជនដែលជម្លៀសមកថ្មី គឺត្រូវកម្មាភិបាលខ្មែរក្រហមប្រើឲ្យធ្វើការដូចៗគ្នា។ កាលនោះ ប្រជាជនទាំងអស់ត្រូវបានកម្មាភិបាលខ្មែរក្រហមបែងចែកឲ្យនៅតាមកងរៀងៗខ្លួនរួមមាន កងនារី, កងយុវជន, កងកុមារ, កងមេម៉ាយ និងកងបុរស។ កងយុវជនត្រូវបានខ្មែរក្រហមចាត់តាំងឲ្យរែកដីដំបូក ដាក់តាមវាលស្រែ។ កងកុមារត្រូវបានខ្មែរក្រហមឲ្យដើររើសអាចម៍គោដាក់ស្រែ។ ខ្ញុំធ្វើការនៅក្នុងកងនារី មានភារកិច្ចរែកដីនិងជីកប្រឡាយ។ ខ្ញុំមិនដែលទទួលអាហារហូបចុកគ្រប់គ្រាន់ឡើយ ហើយខ្ញុំមានតែសម្លៀកបំពាក់មួយសម្រាប់ប៉ុណ្ណោះ។

នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចូលមកវាយខ្មែរក្រហម ខ្ញុំនិងកងនារីទាំងអស់នាំគ្នារត់ឡើងភ្នំ។ ខ្ញុំបានបែកគ្នាជាមួយឪពុកម្ដាយ និងបងប្អូនទាំងអស់។ ប្រហែលមួយខែក្រោយមក ទើបខ្ញុំវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ នៅតាមផ្លូវមកកាន់ស្រុកកំណើត កងទ័ពវៀតណាមបានឲ្យអង្ករ និងរបស់របរខ្លះទៀតសម្រាប់ដោះស្រាយពេលធ្វើដំណើរមកផ្ទះ។ មកដល់ភូមិកំណើត ខ្ញុំប្រកបរបរធ្វើស្រែចម្ការនៅលើដីស្រែដែលរដ្ឋអំណាចបែងចែកឲ្យ។ នៅឆ្នាំ១៩៧៩ ដដែល ខ្ញុំ



ចាប គីមណា ទទួលប្រអប់អនុស្សាវរីយ៍ពីក្រុមនិស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ទំនប់ខ្ទបត្របែក ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បានរៀបការជាមួយប្តីរបស់ខ្ញុំគឺជា ទាហានកម្ពុជាក្រោមឈ្មោះ កន សារិន។ កាលនោះខ្ញុំអាយុ២៧ឆ្នាំហើយ។

សព្វថ្ងៃ ខ្ញុំមានកូន៩នាក់។ កូនៗរបស់ខ្ញុំមានប្តីប្រពន្ធអស់ហើយ ហើយខ្ញុំក៏មិនពិបាករត់លុយ ឬខំធ្វើស្រែដូចពីមុនទៀតដែរ ព្រោះមានកូនប្រុសស្រីចិញ្ចឹម។ ពេលខ្លះ ខ្ញុំបាននិយាយរឿងរ៉ាវដែលខ្ញុំធ្លាប់ឆ្លងកាត់ពីសម័យខ្មែរក្រហមប្រាប់ទៅកូន។ ពេលស្តាប់រឿងរ៉ាវទាំងនោះហើយ កូនរបស់ខ្ញុំមានអារម្មណ៍អាណិតខ្ញុំជាខ្លាំង។ កូនខ្លះយំពេលស្តាប់ពុប្រវត្តិរបស់ខ្ញុំ។ សព្វថ្ងៃនេះ ខ្ញុំនិងប្តីគិតតែធ្វើបុណ្យទានសន្សំកុសល ដើម្បីបន់ស្រន់កុំឲ្យកើតក្នុងរបបដូចខ្មែរក្រហមទៀត។

# ទេព សារឿន ៖ កងចល័តនៅក្នុងរបបខ្មែរក្រហម

*សូ ហាន់*




ទេព សារឿន អាយុ៦១ឆ្នាំ រស់នៅភូមិស្រះតាអឹម ឃុំអន្លង់រស ស្រុកមេសាង ខេត្តព្រៃវែង ទទួលទស្សនាវដ្ដីស្វែងរកការពិតពីក្រុមការងាររមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទេព សារឿន អាយុ៦១ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិស្រះតាអឹម ឃុំអន្លង់រស ស្រុកមេសាង ខេត្តព្រៃវែង បានរៀបរាប់ថា ខ្ញុំមានឪពុកឈ្មោះ ម៉ែន ទុន និងម្ដាយឈ្មោះ ពៅ សុខ។ ខ្ញុំមានបងប្អូនចំនួន២នាក់ ប្រុសទាំង២នាក់ ហើយខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។ ខ្ញុំបានចូលសិក្សានៅសាលាបឋមសិក្សាស្រះតាអឹម ហើយឈប់រៀននៅត្រឹមថ្នាក់ទី១១ នៅក្នុងសម័យសង្គមរាស្ត្រនិយម។

ក្រោយពីមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំឃើញវត្តមានរបស់កងទ័ពវៀតកុង ចូលមករស់នៅក្នុងភូមិជាមួយប្រជាជន។ ទន្ទឹមគ្នានោះ ក៏មានការទម្លាក់គ្រាប់បែកកើតមានជាហូរហែ រហូតមកដល់ចុងឆ្នាំ១៩៧៣។ ខ្ញុំរស់នៅមានការលំបាកយ៉ាងខ្លាំង ដោយត្រូវរត់ចូលពួនក្នុងលេណដ្ឋានជាញឹកញាប់ ដើម្បីគេចពីការទម្លាក់គ្រាប់បែក។

នៅឆ្នាំ១៩៧៤ ការទម្លាក់គ្រាប់បែកបានស្ងប់ស្ងាត់ទៅវិញ។ ក្រោយមក កងទ័ពរំដោះខ្មែរក្រហមចាប់ផ្ដើមប្រមូលប្រជាជនធ្វើស្រែប្រវាស់ដៃ។

នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពេលយោធាខ្មែរក្រហមទទួលបានជ័យជម្នះ នៅទីក្រុងភ្នំពេញ ខ្ញុំសប្បាយរីករាយយ៉ាងខ្លាំង។ពេលនោះ ខ្ញុំបានចូលរួមមីទ្ទីញ និងដើរហែក្បួនស្រែកអបអរសាទរជ័យជម្នះរបស់ខ្មែរក្រហម។ ខ្ញុំនៅចងចាំពាក្យដែលខ្មែរក្រហមប្រើក្នុងអង្គមីទ្ទីញថា «ជយោ! បដិវត្តន៍!»។ មិនបានយូរប៉ុន្មាន អារម្មណ៍សប្បាយរបស់ខ្ញុំបានបាត់បង់អស់ទៅវិញ។ ខ្ញុំឃើញយោធាខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅរស់នៅតាមទីជនបទ ហើយបន្ទាប់មកធ្វើការជម្លៀសបន្តទៅកាន់តំបន់ផ្សេងៗទៀត។ ចំណែកការរស់នៅរបស់ប្រជាជនកាន់តែរឹតត្បិត និងមិនមានសិទ្ធិសេរីភាព។ ខ្មែរក្រហមធ្វើការបែងចែកការរស់នៅរបស់ប្រជាជនទៅតាមក្រុមគឺ៖ ក្រុមមនុស្សចាស់រស់នៅដោយមនុស្សចាស់, ក្រុមយុវជនរស់នៅដោយយុវជន, ក្រុមកុមាររស់នៅដោយកុមារ។

ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅលើកទំនប់ ជីកព្រែកនៅចន្ទៃ និងសង់ស្ថានីយ៍ស្តុកទឹកចេកធ្លុក ជាដើម។ នៅពេលខ្ញុំទៅលើកទំនប់ ជីកព្រែក និងសង់ស្ថានីយ៍ស្តុកទឹក ប្រធានកងចែករបបអាហារឲ្យខ្ញុំយកដាំហូបនៅការដ្ឋាន។ ប៉ុន្តែពេលត្រឡប់ចូលក្នុងភូមិវិញ ប្រធានកងឲ្យខ្ញុំហូបតែបបរលាយជាមួយសម្លដើមចេកប៉ុណ្ណោះ។

នៅក្នុងមូលដ្ឋានដែលខ្ញុំរស់នៅ មានរោងបាយចំនួន ៣កន្លែង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់តា សាក់ គឺជាប្រធានឃុំ។ ចំណែកនៅភូមិស្រះតាអឹមគ្រប់គ្រងដោយ ចាន់ ញឹម គឺជាប្រធានភូមិ។ ក្រោយមកការគ្រប់គ្រងនៅក្នុងសហករណ៍ក៏មានការផ្លាស់ប្តូរ ដោយខ្មែរក្រហមចាប់អ្នកគ្រប់គ្រងចាស់យកទៅសម្លាប់ចោល ហើយយកអ្នកថ្មីមកគ្រប់គ្រងជំនួសវិញ។ ខ្មែរក្រហមបានចោទប្រកាន់កម្មាភិបាលចាស់ថាចូលរួមជាមួយវៀតណាម ហើយក្បត់ អង្គការថ្នាក់លើ។ ខ្មែរក្រហមបានយកកម្មាភិបាល និងកងទ័ពមកពីខាងនិរតីមកគ្រប់គ្រងលើអ្នកដែលទើបឡើងថ្មីទាំងនោះ។ ប្រធានឃុំអង្គរសដែលឡើងថ្មីមានឈ្មោះដាន និងប្រធានភូមិស្រះតាអឹមមានឈ្មោះ អាត។ បើយើងធ្វើខុស អ្នកដឹកនាំថ្មីនឹងរាយការណ៍ទៅថ្នាក់លើភ្លាម ហើយជម្លៀសអ្នកប្រព្រឹត្តខុសទាំងនោះ ទៅស្រុកស្អាង និងយកអ្នកនោះ ទៅសម្លាប់ចោលនៅភ្នំឈើកាច់។ ក្រៅពីនោះ ខ្មែរក្រហមក៏ជម្លៀសប្រជាជនទៅកាន់ខេត្តពោធិ៍សាត់ និងបាត់ដំបងដែរ។

នៅឆ្នាំ១៩៧៨ ខ្ញុំបានស្គាល់នារីម្នាក់ ហើយបានស្នើសុំអង្គការដើម្បីរៀបការ។ នៅថ្ងៃរៀបការរបស់ខ្ញុំក៏មានអ្នករៀបការចំនួន១១គូផ្សេងទៀត។ អង្គការបានអនុញ្ញាតឲ្យឪពុកម្តាយ និងបងប្អូនអាចចូលរួមក្នុងកម្មវិធីរៀបការនេះបាន។ ពេលកម្មវិធីចាប់ផ្តើម អង្គការតម្រូវឲ្យគូនីមួយៗអង្គុយទន្ទឹមគ្នា បន្ទាប់មកមានតំណាង១គូឡើងប្តេជ្ញាចិត្ត និងសំដែងការដឹងគុណដល់អង្គការ។ ពេលចប់កម្មវិធី ខ្ញុំនិងប្តីប្រពន្ធ១១គូផ្សេងទៀត បាននាំគ្នាទៅហូបអាហារនៅតាមរោងបាយសហករណ៍រៀងៗខ្លួន។ ក្រោយពីរៀបការ ខ្ញុំនិងប្រពន្ធមានកូនចំនួន ៦នាក់។

មកដល់ចុងឆ្នាំ១៩៧៨ ខ្ញុំនិងគ្រួសារត្រូវបានអង្គការជម្លៀសចេញពីភូមិ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពេលខ្ញុំធ្វើដំណើរទៅដល់កំពង់សឹង ក៏ជួបកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងបានប្រកាសឲ្យខ្ញុំវិលមករស់នៅស្រុកកំណើតរបស់ខ្លួនវិញ។ ខ្ញុំបានជួបជុំជាមួយគ្រួសារឡើងវិញ។ នៅឆ្នាំ១៩៨០ គ្រួសាររបស់ខ្ញុំបានដាំបន្លែបង្ការ ធ្វើស្រែនិងចិញ្ចឹមសត្វ ទើបគ្រួសារខ្ញុំមានការហូបចុកគ្រប់គ្រាន់។ សព្វថ្ងៃនេះ ខ្ញុំពោះម៉ាយ និងទទួលការផ្គត់ផ្គង់ពីកូនចៅ ហើយពេលទំនេរ ខ្ញុំដាំបន្លែទុកសម្រាប់ហូបក្នុងគ្រួសារ។




ទេព សារឿន អាយុ៦១ឆ្នាំ រស់នៅភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# នួន នៅ ៖ អតីតពេទ្យក្នុងរបបខ្មែរក្រហម

ជុន ស្រីពេជ្រ



នួន នៅ រស់នៅភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នួន នៅ គឺជាអតីតពេទ្យនៅក្នុងរបបខ្មែរក្រហម។ សព្វថ្ងៃ នួន នៅ គឺជាអ្នកលក់ថ្នាំពេទ្យនៅក្នុងភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែងបានរៀបរាប់ថា ខ្ញុំកើតនៅឆ្នាំ១៩៥៤។ ឪពុករបស់ខ្ញុំឈ្មោះ លឹម នួន និងម្តាយឈ្មោះ កែប ម៉ៅ។ ខ្ញុំមានបងប្អូន៦នាក់ ប្រុស៤នាក់ និងស្រី២នាក់។ ប្អូនរបស់ខ្ញុំស្លាប់អស់ម្នាក់ដោយសារជំងឺគាំងបេះដូង កាលពី១០ឆ្នាំមុន។ ខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។

ដោយសារជីវភាពគ្រួសារមធ្យម ដូច្នេះ ឪពុកម្តាយរបស់ខ្ញុំបានបញ្ជូនខ្ញុំឲ្យទៅរៀននៅសាលាស្រះតាអឹម។ ខ្ញុំរៀនដល់ថ្នាក់ទី៧ចាស់។ នៅថ្ងៃដែលសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុក្នុងឆ្នាំ១៩៧០ ខ្ញុំមិនបានចូលរៀនទេ ដោយសារតែមានបាតុកម្មបានកើតឡើងនៅភូមិរបោះព្រីង ឃុំស្វាយយារ ស្រុកស្វាយជ្រំ ហើយសាលាក៏ត្រូវបានបិទទ្វារ។

នៅឆ្នាំ១៩៧១ នៅក្នុងឃុំអង្គរស មានការជ្រើសរើសពេទ្យស្ម័គ្រចិត្ត ហើយកងទ័ពរំដោះខ្មែរក្រហមបានស្នើសុំផ្ទះរបស់ខ្ញុំធ្វើជាទីកន្លែងរៀនពេទ្យ។ ខ្ញុំក៏បានចូលរៀនពេទ្យ តាមការជំរុញរបស់ឪពុក និងយល់ឃើញថា ការរៀនពេទ្យនឹងអាចធ្វើឲ្យជីវិតរស់បានស្រួលទៅថ្ងៃអនាគត។ ការរៀនពេទ្យក៏ជួបឧបសគ្គច្រើនណាស់ដែរ។ នៅពេលរៀនពេទ្យ ខ្ញុំមិនសូវបានសម្រាកទេ បណ្តាលឲ្យខ្ញុំឈឺ។ ប្រធានសង្គមកិច្ចឃុំចោទប្រកាន់ខ្ញុំថាធ្វើពុតជាឈឺ។ រយៈពេល ៣ខែ បន្ទាប់ពីបញ្ចប់ការរៀនពេទ្យ ខ្ញុំបានទទួលចំណេះដឹងមួយចំនួន ដូចជា ចាក់ថ្នាំ ផ្សំថ្នាំ ចំណាំប្រភេទថ្នាំគ្រាប់ ថ្នាំបុរាណ និងថ្នាំវីតាមីនដែលនាំចូលពីប្រទេសចិន និងអាមេរិក។ ខ្ញុំក៏បានជួយព្យាបាលប្រជាជនឲ្យជាសះស្បើយច្រើននាក់ដែរ។ នៅក្នុងសម័យនោះ ប្រជាជនភាគច្រើន គឺមានជំងឺគ្រុនចាញ់ ក្តៅខ្លួន និងរាក។

នៅឆ្នាំ១៩៧៤ ខ្ញុំលែងបាននៅផ្ទះទៀតហើយ។ ខ្ញុំត្រូវដើរចល័តគ្រប់ទីកន្លែងដើម្បីព្យាបាលអ្នកជំងឺនិងអ្នករបួស។ ជាដំបូង ខ្ញុំបានទៅ ពោធិ៍ កន្លែងដើម្បីព្យាបាលកម្មាភិបាលខ្មែរក្រហម និងយោធាខ្មែរក្រហមដែលប្រយុទ្ធគ្នាជាមួយកងទ័ព លន់ នល់។ ដោយសារខ្ញុំគឺជាគ្រូពេទ្យដូច្នេះខ្ញុំមិនដែលប្រកាន់បក្សពួកទេ។ ខ្ញុំព្យាបាលមនុស្សគ្រប់គ្នា ដែលកំពុងត្រូវការជំនួយ។ ខ្ញុំពុំសូវបានមកលេងផ្ទះទេ។ យូរៗម្តង

ទើបខ្ញុំហ៊ានសុំច្បាប់ប្រធានអង្គភាពមកលេងឪពុកម្តាយមួយទៅពីរថ្ងៃ។ ខ្ញុំមិនត្រឹមតែព្យាបាលប្រជាជននៅក្នុងភូមិស្រះតាអឹមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងព្យាបាលអ្នកជំងឺនៅមន្ទីរពេទ្យឃុំ អង្គរស មន្ទីរពេទ្យស្រុកមេសាង ព្រៃវែង និងស្រុកកញ្ជៀចទៀតផង។

នៅខែមិថុនា ឆ្នាំ១៩៧៨ មានលេចឮពាក្យចចាមអារ៉ាមថា សោ ភឹម បានក្បត់នឹងបដិវត្តន៍ ដូច្នេះ អ្នកដែលនៅក្រោមបង្គាប់របស់ សោ ភឹម ទាំងអស់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនយកទៅសម្លាប់ចោលរួមទាំងឪពុករបស់ខ្ញុំ។ ចំណែកខ្ញុំ ត្រូវបានខ្មែរក្រហមលែងឲ្យធ្វើពេទ្យ ហើយឲ្យមករស់នៅសហករណ៍ជាមួយប្រជាជនវិញ។ ដំបូងប្រជាជននៅក្នុងភូមិបាននាំគ្នានិយាយថា ខ្ញុំគឺជាជនក្បត់ជាតិ ប៉ុន្តែខ្ញុំបានខិតខំធ្វើយ៉ាងណាឲ្យប្រជាជននៅក្នុងសហករណ៍មើលឃើញថា ខ្ញុំគឺជាមនុស្សដែលតស៊ូ និងអត់ធ្មត់នឹងការងារ។ រាល់ថ្ងៃខ្ញុំត្រូវដើរប្រមូលជី លាមកមនុស្ស និងត្រូវទៅកាប់ខសយកមកដាក់នៅក្នុងរោងបាយរួម។ ចំណែកឯអាហារគឺខ្វះខាតជាងមុន ប៉ុន្តែមានប្រជាជននៅក្នុងសហករណ៍លួចឲ្យត្រីមកខ្ញុំហូបដែរ។ ខ្ញុំធ្វើការងារបណ្តើរ គិតបណ្តើរមិនដឹងថា ខ្មែរក្រហមនឹងយកខ្ញុំទៅសម្លាប់នៅពេលណានោះទេ ព្រោះរៀងរាល់ថ្ងៃខ្ញុំសង្កេតឃើញអ្នកដែលជាប់និន្នាការដូចខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមយកទៅសម្លាប់ម្តងម្នាក់ៗ។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំត្រូវបានឈ្លបខ្មែរក្រហមកត់ឈ្មោះចូលទៅក្នុងបញ្ជីដែលត្រូវនាំខ្លួនយកទៅសម្លាប់ចោល។ សំណាងល្អ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមករំដោះ ទើបខ្ញុំរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃ។

ខ្ញុំបានមករស់នៅក្នុងភូមិស្រះតាអឹមវិញ និងបានរៀបការប្រពន្ធ។ ខ្ញុំមានកូនចំនួន ៦នាក់។ ខ្ញុំរស់នៅយ៉ាងមានសុភមង្គល និងមានជីវភាពធូរធារ។ ខ្ញុំសប្បាយចិត្តដែលបានចែករំលែករឿងរ៉ាវរបស់ខ្ញុំប្រាប់ដល់ក្មេងជំនាន់ក្រោយឲ្យបានដឹង។



នួន នៅ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។
( ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ការិយាល័យ
# ព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្ដា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ
អ៊ីម៉ែល ៖ truthchenda.s@dccam.org

សូមអរគុណ!















# យុវសិស្សចំនួន ៣០នាក់ នៃវិទ្យាល័យ ឈើន លាន ហាន់ជ័យ ចូលរួមវេទិកាអន្តរជំនាន់ចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

**ទូច វណ្ណេត**




សិស្សានុសិស្សថតរូបជុំគ្នានៅខាងមុខមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សានុសិស្សទស្សនាផ្ទាំងពិព័រណ៍ដាក់តាំងនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃអាទិត្យទី១៤ ខែសីហា ឆ្នាំ២០២២ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមនៃមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំវេទិកាអន្តរជំនាន់ចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានការចូលរួមរបស់យុវសិស្សមកពីវិទ្យាល័យ ឈើន លាន ហាន់ជ័យ។ វេទិកាអន្តរជំនាន់នេះរៀបចំឡើងក្នុងគោលបំណង ដើម្បីជំរុញឲ្យការយល់ដឹងរបស់យុវសិស្សបន្ថែមលើប្រវត្តិសាស្ត្រខ្មែរក្រហម។ ជាកិច្ចចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានទទួលស្វាគមន៍ និង ដឹកនាំយុវសិស្សចូលទស្សនាផ្ទាំងពិព័រណ៍ធំៗ ស្តីពីប្រវត្តិមេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជន និងការធ្វើការងារនៅការដ្ឋាន និងពិព័រណ៍រូបភាពអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងខេត្តកំពង់ចាម ចងក្រងដោយអ្នកស្ម័គ្រចិត្តកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះ យុវសិស្សបន្តចូលទស្សនា បន្ទប់ឯកសារខ្មែរក្រហមដែលផ្ទុកឯកសារ



សិស្សានុសិស្សស្តាប់លោក ទេព សារី កូតទ្រ និងរៀបរាប់បទពិសោធន៍ជីវិតជាជនពិការឆ្លងកាត់របបខ្មែរក្រហម។ (ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

រាប់សែនទំព័រ។ កម្មវិធីបន្ទាប់ គឺជាការចាក់បញ្ចាំងវីដេអូឯកសារ ដែលមានចំណងជើងថា «កុំស្មានបងក្មេង» ដែលបង្ហាញអំពីតន្ត្រីវប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា។ យុវសិស្សទាំងអស់ទស្សនាវីដេអូឯកសារដែលមានរយៈពេលជិត២ម៉ោងនេះ ដោយយកចិត្តទុកដាក់។

ជាកិច្ចបន្ត ទេព សារី ដែលជាអតីតសិល្បករជំនាញប្រើប្រាស់ឧបករណ៍ទ្រអ៊ូ ទ្រសោ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រំឭកអំពីសាវតារ និងបទពិសោធន៍ជីវិតរបស់គាត់មុន និងក្នុងរបបខ្មែរក្រហម ដូចជាការបែកចេញពីក្រុមគ្រួសារ ការហូបចុកមិនគ្រប់គ្រាន់ ការធ្វើកម្លាំងពលកម្ម និងការរស់នៅក្នុងភាពភ័យខ្លាច។ ទេព សារី បញ្ជាក់ថា ខ្ញុំកើតនៅឆ្នាំ១៩៥២ ក្នុងគ្រួសារ កសិករនៅភូមិពន្លៃចក ឃុំមៀន ស្រុកអូរាំងឪ។ នៅអាយុ៦ឆ្នាំ ខ្ញុំពិការភ្នែកទាំងសងខាង ព្រោះខ្ញុំមានជំងឺពិសកុក។ ខ្ញុំមិនអាចទៅរៀនបានទេ គ្រាន់តែនៅផ្ទះជាមួយឪពុកម្តាយប៉ុណ្ណោះ។ នៅអាយុ១០ឆ្នាំ ខ្ញុំចាប់ផ្តើមរៀនប្រើប្រាស់ឧបករណ៍ភ្លេងបុរាណខ្មែរជំនាញផ្នែកទ្រអ៊ូ និងទ្រសោ។ បន្ទាប់ពីរៀនអស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំអាចដើរលេងភ្លេងបាន ដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ។ ពេលនោះ គឺជាសម័យសង្គមរាស្ត្រនិយម។ បន្ទាប់ពីមានរដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០មក ភូមិរបស់ខ្ញុំគឺជាសមរភូមិប្រទាញប្រទង់រវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម និងក្រោយមកត្រូវបានរំដោះ។ នៅពេលនោះ ខ្ញុំមានអាយុ១៨ឆ្នាំ។ ខ្ញុំបានស្ម័គ្រចិត្តចូលទៅព្រៃម៉ាគីតស៊ីជាមួយអ្នកភូមិផ្សេងទៀត។ ដោយសារតែពិការភាព និងជំនាញសិល្បៈរបស់ខ្ញុំ ខ្ញុំត្រូវបានដាក់ឲ្យបម្រើក្នុងកងសិល្បៈខ្មែរក្រហម។ ខ្ញុំអាចធ្វើដំណើរចុះឡើងបានដោយប្រើប្រាស់ដំបងឈើ និងមានពេលខ្លះសមមិត្តនៅក្នុងកងសិល្បៈជួយដឹកដៃដើរ។

រហូតដល់ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការសហករណ៍នៅម្តុំស្នួង។ នេះគឺជាការចាប់ផ្តើមរងទុក្ខលំបាក ពីព្រោះខ្ញុំត្រូវធ្វើការនៅក្នុងកងសិល្បៈផង និងនៅវាលស្រែផង។ ខ្ញុំត្រូវបានកំណត់ឲ្យធ្វើការដឹកដីដូចប្រជាជនដទៃ។ ចំណែកឯរបបអាហារវិញគឺមិន



សិស្សានុសិស្សទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» នៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សានុសិស្សទស្សនាពិព័រណ៍រូបថតដាក់តាំងនៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សានុសិស្សមើលឯកសារបទសម្ភាសន៍ដាក់តាំងនៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា)

គ្រប់គ្រាន់នោះឡើយ។ ខ្ញុំបានរួចផុតពីសេចក្តីអត់ឃ្លាន បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩។

បន្ទាប់ពី ការចែករំលែករឿងរ៉ាវជីវិតរបស់វាគ្មិនមក យុវសិស្សទាំងអស់ធ្វើដំណើរទស្សនកិច្ចសិក្សាទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ស្ថិតនៅវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ ក្នុងឱកាសចុះមកកាន់ទីតាំងចេតិយនេះ យុវសិស្សជួបនិយាយជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគឺ អៀង សារឿន ដែលបានរៀបរាប់អំពីបទពិសោធន៍រស់នៅ និងការសម្លាប់ ប្រជាជននៅក្នុងភូមិសាស្រ្តឃុំគគរ។ ក្នុងជំនួបសន្ទនាផ្ទាល់រយៈពេល ៣០នាទី យុវសិស្សស្គាល់អំពីទីតាំងធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់ប្រជាជននៅក្នុងរបបខ្មែរក្រហម ដូចជា៖ ទី១) វាលស្រែនៅភូមិចំការសាមសិប ទី២) ឡដុតថ្នាំជក់ និង ទី៣) មន្ទីរសន្តិសុខគគរដែលស្ថិតនៅក្នុងវត្តគគរ។

បន្ទាប់ពីការនិយាយប្រាប់របស់ អៀង សារឿន យុវសិស្សបានសួរសំណួរជាច្រើនទៅកាន់វាគ្មិន។ សិស្សឈ្មោះ គុណ ស្រីនិច រៀនថ្នាក់ទី១២-C មុខវិជ្ជាវិទ្យាសាស្រ្តសង្គម នៃវិទ្យាល័យ ឈីន លានហាន់ជ័យ បង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា៖ ខ្ញុំធ្លាប់រៀនមេរៀនប្រវត្តិសាស្រ្តនៅក្នុងថ្នាក់ ទាក់ទងប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យនេះ។ ខ្ញុំទទួលបានចំណេះដឹងថ្មីៗជាច្រើន តាមរយៈផ្ទាំងរូបភាព និងវីដេអូឯកសារ។ ខ្ញុំកាន់តែយល់ពីទុក្ខលំបាករបស់ប្រជាជនក្នុងរបបខ្មែរក្រហមនៅពេលលោកអ៊ុំសារឿនបានចែករំលែកបទពិសោធន៍ជីវិតរបស់គាត់។ សិស្សឈ្មោះ យាង ម៉េងលាង រៀនថ្នាក់ទី១២-C មុខវិជ្ជាវិទ្យាសាស្រ្តសង្គមនៃវិទ្យាល័យ ឈីនលានហាន់ជ័យ ចែករំលែកទស្សនៈរបស់ខ្លួនថា ខ្ញុំយល់ដឹងកាន់តែច្រើនអំពីប្រវត្តិសាស្រ្តខ្មែរក្រហម បន្ថែម។ ខ្ញុំមានការឈឺចាប់ និងការអាណិតអាសូរដល់ប្រជាជនកម្ពុជាដែលឆ្លងកាត់សង្រ្គាម និងរបបខ្មែរក្រហម។ ខ្ញុំបានដឹងអំពីការធ្វើការងារហួសកម្លាំង ការហូបមិនគ្រប់គ្រាន់ ការកាប់សម្លាប់ និងការរស់នៅក្នុងភាពភ័យខ្លាចនៅក្នុងរបបខ្មែរក្រហម។ ការចំណាយពេលវេលាស្វែងយល់អំពីរឿងរ៉ាវប្រវត្តិសាស្រ្តនាពេលចុងសប្តាហ៍នេះ គឺពិតជាល្អណាស់សម្រាប់ខ្ញុំ និងសិស្សានុ

សិស្សផ្សេងទៀត។ ខ្ញុំសូមអរគុណដល់លោកគ្រូ និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលរៀបចំកម្មវិធីនេះឡើង។

សិស្សឈ្មោះ ចម្រើន ស្រីមុី រៀនថ្នាក់ទី១២-C មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចែករំលែកអំពីចំណេះដឹងដែលខ្លួនទទួលបានថា៖ នេះគឺជាលើកទី១ ដែលខ្ញុំចូលរួម កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នាពេលចុងសប្តាហ៍នេះ។ ខ្ញុំមានការយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ បន្ថែមលើនេះទៀត ខ្ញុំបានទៅដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ និងដឹងទីតាំងសម្លាប់រង្គាលរបស់ខ្មែរក្រហម។ ខ្ញុំនឹងសួរនាំជីតារបស់ខ្ញុំពីបទពិសោធន៍ដែលគាត់បានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម។ សិស្សឈ្មោះ សុខខេង រក្សា រៀនថ្នាក់ទី១២-E មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ យល់ឃើញថា ការចូលរួមកម្មវិធីនេះគឺពិតជាល្អណាស់ ពីព្រោះខ្ញុំទទួលបាន ចំណេះដឹងថ្មីៗបន្ថែមលើអ្វីដែលខ្ញុំរៀននៅក្នុងថ្នាក់។ ខ្ញុំទស្សនាវីដេអូឯកសារ ស្តាប់ការនិយាយប្រាប់ អំពី បទពិសោធន៍ជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទស្សនកិច្ចទៅកាន់ស្តូបរំឭកសម្រាប់សហគមន៍ដើម្បីរំឭកដល់ជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំពេញចិត្តចំពោះ កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នាពេលចុងសប្តាហ៍នេះ។



សិស្សានុសិស្ស និង លោកគ្រូអ្នកគ្រូទស្សនកិច្ចចេតិយរំឭកសម្រាប់សហគមន៍។
( ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា )



សិស្សានុសិស្សថតរូបជុំគ្នានៅចេតិយរំឭកសម្រាប់សហគមន៍។
( ទូច វណ្ណេត / មជ្ឈមណ្ឌលឯកសារកម្ពុជា )

# សិស្សមកពីវិទ្យាល័យចំនួន ៣ ក្នុងខេត្តត្បូងឃ្មុំ ទទួលការអប់រំស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ

*គាត ស្រីឡែន ឈុំ រ៉ា និង ទី ស៊ីថា*



*សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលដង្វារ, វិទ្យាល័យ ហ៊ុនសែន ក្រែក និង វិទ្យាល័យ ហ៊ុនសែនខ្នារ មកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*នៅព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២២ សិស្សានុសិស្សចំនួន ៦៦នាក់ ក្នុងនោះមានសិស្សស្រី ៤៦ នាក់ និងលោកគ្រូអ្នកគ្រូចំនួន៣នាក់ មកពីវិទ្យាល័យចំនួន ៣ ក្នុងខេត្តត្បូងឃ្មុំ គឺវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន ក្តុលដង្វារ, វិទ្យាល័យ ហ៊ុនសែន ក្រែក និង វិទ្យាល័យ ហ៊ុនសែនខ្នារ បានចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ ការរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះក្នុងគោលបំណងដូចខាងក្រោម៖*

- *ផ្តល់ឱកាសដល់សិស្សានុសិស្សក្នុងការចែករំលែក និងបង្ហាញពីចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេនៅលើរឿងរ៉ាវដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។*
- *លើកទឹកចិត្តសិស្សឲ្យគិតពិចារណាលើផលវិបាកអន្តរកាលនៃកេរដំណែលនេះ ក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។*
- *ជំរុញការពិភាក្សាអំពីកេរដំណែលនេះនៅក្នុងគ្រួសារ និងសហគមន៍។*
- *ជំរុញការពិភាក្សាអំពីការលើកឡើងនូវយុទ្ធសាស្ត្រ*

មួយចំនួនក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេស។

- ចែកសៀវភៅសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។

ជាកិច្ចចាប់ផ្ដើមវេទិកាថ្នាក់រៀនចុងសប្ដាហ៍ លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានណែនាំខ្លួន និងបង្ហាញអំពីគោលបំណងនៃការបង្កើតមជ្ឈមណ្ឌលឯកសារកោះថ្មនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ក្រោមកិច្ចសហការណ៍យ៉ាងជិតស្និទ្ធរវាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការពារជាតិ និងមជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់មក លោក ឡុង ដានី បាននាំសិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ ដើរទស្សនាពិព័រណ៍នៃបណ្តុំរូបថត រូបគំនូរ និងផែនទី នៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ដោយចាប់ផ្ដើមពីបណ្តុំរូបថតនៃសង្គ្រាមនៅទសវត្សរ៍ឆ្នាំ១៩៦០ នៅតំបន់កោះថ្ម, បណ្តុំរូបថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩), បណ្តុំរូបថតនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩, បណ្តុំរូបថតភស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩), បណ្តុំរូបគំនូដែលសមមិត្ត ហ៊ុន សែន (សម្តេចតេជោ ហ៊ុន សែន) និងយុទ្ធមិត្ត៨រូបចាកចេញទៅប្រទេសវៀតណាមដើម្បីរៀបចំកម្លាំងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងផែនទីបង្ហាញផ្លូវដែលសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៨រូបបានចាកចេញ



លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ដល់សិស្សានុសិស្ស។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ធ្វើបទបង្ហាញអំពីគោលបំណងនៃការបង្កើតមជ្ឈមណ្ឌលឯកសារកោះថ្ម និងពិព័រណ៍រូបថតដែលបានដាក់តាំងបង្ហាញដល់សិស្សានុសិស្ស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្ស សួរសំណួរអំឡុងពេលចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីបន្ទាយយោធានៅភូមិកោះថ្មទៅតំបន់ព្រំដែនអាងដាច់ដើមគ្រយឹង (X-16) និងទីតាំងមួយចំនួននៅក្នុងស្រុក ឡុកនិញ ខេត្តសុងប៊ែរ ប្រទេសវៀតណាម និងការបង្កើតអង្គភាព១២៥ ដែលជាកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាដំបូងបង្អស់ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨។

ជាកិច្ចបន្តលោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ដល់សិស្សានុសិស្ស និងឲ្យសិស្សចូលសកម្មភាពក្នុងថ្នាក់ដូចខាងក្រោម៖

- វាស់ស្ទង់ចំណេះដឹងសិស្សមុនវេទិកាចាប់ផ្តើមដោយប្រើប្រាស់កម្រងសំណួរវាស់ស្ទង់មតិ។
- ចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ដល់សិស្សានុសិស្សទាំងអស់។
- បទបង្ហាញ និងពន្យល់ពីនិយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងកម្រិតបុគ្គល គ្រួសារ ឬសហគមន៍ និងប្រទេសជាតិ។
- បទបង្ហាញ និងពន្យល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។

បន្ទាប់មកលោក ផេង ពង្សរ៉ាស៊ី បានលើកយកគោលនយោបាយ៨ចំណុច ដែលខ្មែរក្រហមបានអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មកបកស្រាយបង្ហាញដល់សិស្សានុសិស្សមានដូចខាងក្រោម៖

១) ការជម្លៀសប្រជាជនដោយបង្ខំ។
២) ការលុបបំបាត់លុយ ផ្សារ ទ្រព្យសម្បត្តិឯកជន ប្រពៃណី សាសនា ទំនៀមទម្លាប់ និងបំផ្លាញសាលារៀន វត្តអារាម និងកន្លែងលក់ដូរផ្សេងៗ។
៣) ការបង្កើតសហករណ៍ និងការដ្ឋានការងារ។
៤) បំបាត់សិទ្ធិសេរីភាពប្រជាជន។
៥) បំបែកបំបាក់ក្រុមគ្រួសារ និងបង្ខំឲ្យធ្វើការងារហួសកម្លាំង។
៦) សម្លាប់អ្នកចេះដឹង អតីតទាហាន លន់ នល់ និងជនជាតិភាគតិចរួមមាន ចាម វៀតណាម ចិន ជាដើម។
៧) បង្កើតមន្ទីរឃុំឃាំងដើម្បីឃុំឃាំងប្រជាជនដែលត្រូវបានចោទថាក្បត់។
៨) ប្រកាសសង្គ្រាម និងបញ្ជូនកងទ័ពទៅតាមព្រំដែនជាមួយប្រទេសវៀតណាម។

ផលប៉ះពាល់បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ គឺសង្គមកម្ពុជាទាំងមូលបានបែកបាក់ បន្សល់ទុកនូវស្ត្រី មេម៉ាយ និងក្មេងកំព្រារាប់សែននាក់។ ប្រជាជនកម្ពុជាដែលនៅរស់រានមានជីវិតបានប៉ះដង្ហិចផ្លូវចិត្តធ្ងន់ និងមានគ្រាប់មីនរាប់ម៉ឺនគ្រាប់បានបន្តកប់នៅក្នុងប្រទេសកម្ពុជា។ កត្តាទាំងនេះបានបណ្តាលឲ្យប្រទេសកម្ពុជាធ្លាក់ក្នុងភាពក្រីក្ររហូតមកដល់សព្វថ្ងៃ។

នៅក្នុងឱកាសនោះ លោក ផេង ពង្សរ៉ាស៊ី ក៏បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារកុមារកម្ពុជា ដល់សិស្សានុសិស្សបានទស្សនា។ មុននឹងបញ្ចប់វេទិកាថ្នាក់រៀនលោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញពី



សិស្សកត់ត្រាអំឡុងចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

និយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងវាស់ស្ទង់ចំណេះដឹងសិស្សក្រោយវេទិកាបញ្ចប់ ដោយប្រើប្រាស់កម្រងសំណួរវាស់ស្ទង់មតិ។

បន្ទាប់ពីចប់វេទិកាថ្នាក់រៀន លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

លោកគ្រូ រ័ត្ន ភារុណ បង្រៀននៅវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ ដែលបានដឹកនាំសិស្សានុ-សិស្សចំនួន២២នាក់មកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍នៅមជ្ឈមណ្ឌលឯកសារកោះថ្ម បង្ហាញចំណាប់អារម្មណ៍ថា សិស្សានុសិស្សទទួលបានបទពិសោធន៍ក៏ដូចជាចំណេះដឹងបន្ថែម ទាក់ទងទៅនឹងរឿងរ៉ាវប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩) និងការងើបឡើងតស៊ូប្រឆាំងនឹងរបបខ្មែរក្រហម ដូចជា ការបង្កើតកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា (អង្គភាព១២៥) ចលនាបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ដើម្បីវាយផ្តួលរំលំរបបខ្មែរក្រហមរំដោះប្រជាជន និងប្រទេសជាតិឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ខ្ញុំសង្កេតឃើញថាសិស្សទទួលបានចំណេះដឹងច្រើនតាមរយៈការបង្រៀនរបស់លោកគ្រូ ក៏ដូចជា តាមរយៈការសួរដេញដោលរបស់សិស្សានុសិស្សទាក់ទងនឹងមេរៀនដែលលោកគ្រូបានបង្រៀន។ ខ្ញុំជឿជាក់ថា សិស្សានុសិស្សទទួលបានចំណេះដឹងច្រើនទាក់ទងនឹងប្រធានបទ ក៏ដូចជាមេរៀនដែលបានរៀននោះ។ ដោយសារសិស្សានុ-សិស្សទទួលបានចំណេះដឹងច្រើនទើបពួកគាត់អាចសួរបកទៅកាន់លោកគ្រូ និងចង់ដឹងបន្ថែមពីអ្វីដែលលោកគ្រូមិនបានបង្រៀនដល់គាត់ទៀត។ ជាចុងក្រោយ ខ្ញុំមានសំណូមពរដល់គណៈគ្រប់គ្រងមជ្ឈ-មណ្ឌលឯកសារកោះថ្ម បើកសិក្ខាសិលាខ្លីៗដល់យុវជនឲ្យបានកាន់តែច្រើនទាក់ទងនឹងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមជាដើម ដើម្បីឲ្យយុវជនបានយល់ដឹងកាន់តែច្រើន ហើយអាចទប់ស្កាត់ការកកើតមានឡើងនូវអំពើរហឹង្សាធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មដូចរៀបរាប់ខាងលើទៀត។



សិស្សកត់ត្រាអំឡុងចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





សិស្សកត់ត្រាអំឡុងចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យុវសិស្ស គី កេត ភេទប្រុស អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ នៅវិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែនក្តុលផ្សារ មានចំណាប់អារម្មណ៍ថា គ្រាន់តែមកដល់មជ្ឈមណ្ឌលឯកសារកោះថ្មដំបូង ខ្ញុំមានអារម្មណ៍ថាបានសិក្សាមួយផ្នែកនៃប្រវត្តិសាស្ត្រខ្មែរ នៅរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាខ្ញុំបានដឹងអំពីការសម្លាប់មនុស្សអំពើដ៏ឃោរឃៅ ការរំលោភសិទ្ធិមនុស្ស ការបង្អត់អាហារ និងការបំផ្លាញរចនាសម្ព័ន្ធប្រទេសជាតិជាដើម។ បន្ទាប់មកខ្ញុំបានសិក្សាដោយផ្ទាល់ជាមួយលោកគ្រូខ្មែរទ្ធេសថែមទៀត ខ្ញុំកាន់តែទទួលបានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ក៏ដូចជា វិធីទប់ស្កាត់របបកម្ពុជាប្រជាធិបតេយ្យកុំឲ្យកើតឡើងម្តងទៀត។ នៅមុនពេលនិងក្រោយពេលខ្ញុំចូលរួមវេទិកា គឺមានភាពខុសគ្នា គឺនៅមុនពេលខ្ញុំចូលរួមវេទិកានេះ ខ្ញុំគ្មានអារម្មណ៍ថាមិនចង់សិក្សាប្រវត្តិសាស្ត្ររបស់ខ្លួនឯងទេ តែនៅពេលដែលខ្ញុំបានចូលរួមវេទិការួចមក ខ្ញុំបានដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ក៏ដូចជា ការឈឺចាប់របស់ប្រជាជន និងបានតាំងចិត្តថាមិនឲ្យមានអំពើនេះកើតឡើងម្តងទៀតទេ។ ចុងក្រោយខ្ញុំមានសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ជួយបើកវគ្គបណ្តុះបណ្តាលសម្រាប់សិស្សជំនាន់ក្រោយឲ្យបានយល់ដឹងអំពីរបបកម្ពុប្រជាធិបតេយ្យកាន់តែច្បាស់ និងជាពិសេសនោះ គឺការទប់ស្កាត់របបកម្ពុជាប្រជាធិតេយ្យកុំឲ្យកើតឡើងម្តងទៀត ។

យុវសិស្ស រឿន សាម៉ី ភេទស្រី អាយុ១៨ឆ្នាំ រៀនថ្នាក់ទី ១២ មកពីវិទ្យាល័យក្រែក រៀបរាប់ថា បន្ទាប់ពីខ្ញុំបានចូលរួមវេទិកានេះរួចមក ខ្ញុំមានអារម្មណ៍ថា ខ្ញុំកាន់តែចង់ដឹង និងចង់ស្វែងយល់អំពីរបបខ្មែរក្រហមថែមទៀត ព្រោះក្រោយពេលដែលខ្ញុំបានចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្តាហ៍នៅថ្ងៃនេះរួចហើយ ធ្វើឲ្យខ្ញុំមានចំណេះដឹងអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងវិធីទប់ស្កាត់របបនេះកុំឲ្យកើតឡើងម្តងទៀត ។

# «ទួលពិឃាដ» (ត)

## ៨. ជម្លៀសក្នុងជម្លៀសខប្បធម៌បញ្ច្រាសទិសនៃអង្គការបដិវត្តន៍

### ភ្នំពេញ, ភូមិក្រាំង, ភូមិព្រៃក្រឡាញ់ធំ, ភូមិក្រាំង, ស្រុកអូររាំងឪ ខេត្តកំពង់ចាម

ជាងមួយខែក្រោយពីការរៀបការរបស់បងស្រី និងបងណាត ថ្ងៃមួយព្រលឹមស្រាងៗ ខ្ញុំចេញទៅចាំគោដូចសព្វដងនៅខាងជើងភូមិក្រាំង។

រៀបនឹងចងមីត្នោតឲ្យស៊ីស្មៅ ក៏ឮសំឡេងគេបាញ់គ្រាប់បែ ៤០ បួនដប់គ្រាប់យ៉ាងរន្ទាន់រំពងខ្ទរពេញភូមិ ខ្ញុំភ័យស្ទន់ស្មោ ទាញខ្សែគោខុសៗ រួចចងគោនឹងស្ទឹងដំកប់ក្នុងដីរត់តម្រង់ចូលភូមិសំដៅរកផ្ទះយ៉ាងលឿន។

ពេលមកដល់ ខ្ញុំឃើញបងស្រីចិន្តា ប្អូនរ៉ា និងតាយាយនៅជុំគ្នា បងចិន្តាគាត់កំពុងចងបង្វិចខោអាវនឹងភួយកញ្ចាស់ជាពីរដុំ ឯតាយាយស្ពាយបង្វិចខោអាវខ្ចប់នឹងក្រមាចាស់ៗ។ ខណៈនោះខ្ញុំឃើញបងណាតរត់យ៉ាងត្រហេបត្រហបភ័យញ័រតក់ស្លុត មានយួរឆ្នាំងបាយ កំសៀវទឹក កំពឹតកំពៀតចាស់ៗ និងអង្ករប្រេកនឹងអាវចាស់មួយ រត់ចេញផ្លោះរបងពីរោងបាយយ៉ាងលឿន។

សំឡេងកាំភ្លើងពុកាន់តែជិតទៅៗ អ្នកភូមិឯទៀតរត់ចេញមកប្រសេចប្រសាច ហើយស្រែកថា "ឆាប់ឡើងៗពួកទាហានខោអាវត្រួយចេកនិរតីកៀរប្រជាជនឲ្យចេញពីភូមិទាំងអស់"។

បងណាត បានសុំផ្ញើជីតានឹងរទេះគោអ្នកភូមិ ចំណែកយាយផ្ញើនឹងរទេះគៀវអ្នកភូមិផ្សេងទៀត ហើយគាត់ក៏ស្ទុះវែកអំរែកខោអាវ ចំណែកខ្ញុំរែកឆ្នាំងម្ខាង និងថ្នក់អង្ករម្ខាងជាមួយនឹងអម្រែកធាងត្នោត ឯប្អូនរ៉ា យួរកំសៀវដែលមានទឹកខ្វះសម្រាប់ហូបតាមផ្លូវ បងស្រីចិន្តា យួរកាតូ និងមានចានស្លាបព្រាដៅរ៉ាខ្មៅ កញ្ចាស់ៗបីបួននៅក្នុងនោះ ហើយរូតរះដើរផងរត់ផងយ៉ាងលឿនចេញពីភូមិ ខ្លាចពួកទាហានអាវត្រួយចេកមកទាន់។ ដោយធ្វើដំណើរតាមបញ្ចកងឈ្លបម្នាក់ពីរនាក់បណ្ដើរអ្នកភូមិទាំងហ្វូងៗ ឆ្ពោះទៅរកកន្លែងសម្ងាប់របស់ពួកគេដោយវិធីផ្សេងៗ និងផ្សងព្រេងតាមយថាកម្មដូចចករសាត់អណ្ដែតគ្មានកោះត្រើយ។

គិតមកដល់លើកនេះ គ្រួសារខ្ញុំត្រូវបានគេជម្លៀសបីដងហើយនៅក្នុងរបបនោះ។

---

## ១៧ មេសា ១៩៧៥
## លាចាកទ្រនំចាស់, ទឹកភ្នែកអ្នកភ្នំពេញ

ខ្ញុំនៅចាំថ្ងៃមួយពេលនោះខ្ញុំកំពុងហូបមីស្រុសទឹកក្ដៅដែលជាជំនួយរបស់អាមេរិកាំងដល់កុមារ គឺជាថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥។ ពួកខ្មែរក្រហមបានទទួលជ័យជម្នះលើពួកទាហាន លន់ នល់ គាំទ្រដោយអាមេរិកាំង។ ពួកគេបានជម្លៀសប្រជាជនទាំងអស់ឲ្យចេញពីទីក្រុងភ្នំពេញរួមទាំងគ្រួសារខ្ញុំផង។ អំឡុងពេលដែលប្រជាជនទះដៃអបអរសាទរនឹងជ័យជម្នះ ដែលយើងគិតថាបានបញ្ចប់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃយូរអង្វែងមកហើយរវាងខ្មែរនិងខ្មែរ។

ស្របពេលនោះពួកទាហានខ្មែរក្រហមបានបាញ់កាំភ្លើងឡើងលើគំរាមប្រជាជនឲ្យចេញពីលំនៅដ្ឋានរយៈពេលបីថ្ងៃ ដើម្បីអង្គការបដិវត្តន៍បោសសម្អាតទាហានដែលជាបរិវារអាមេរិកាំងចក្រពត្តិនិយម ហើយបើមានកាំភ្លើងត្រូវយកមកជូនអង្គការបដិវត្តន៍។

ខ្ញុំឃើញប្រជាជនដើរពេញផ្លូវណែនណាន់តាន់តាប់ ម្ដាយខ្ញុំ បងប្រុស និងបងស្រីរៀបចំអីវ៉ាន់ដាក់លើកង់ ហើយចាក់សោរផ្ទះ។ ចំណែកឪពុកខ្ញុំគាត់មិនទាន់មកដល់ទេ ព្រោះគាត់

បានប្រាប់ម្ដាយខ្ញុំថា ទៅទិញថ្នាំពេទ្យទុកតាមខ្លួនក្រែងកូនៗឈឺ ថ្កាត់តាមផ្លូវ។

ពួកទាហានរំដោះអាវខ្មៅបានមកភ្ជង់គ្រួសារខ្ញុំនឹងកាំភ្លើងជាមួយចំពុះទុងសស្វាចគំរាមថា"ចេញទៅៗ នៅរោចាំស្អីទៀត?" ម្ដាយខ្ញុំសំពះអង្វរចាំបន្តិចសិនទៅក្មួយ ព្រោះប្ដីខ្ញុំទៅសុំថ្នាំពេទ្យមិនទាន់មកទេ។ នេះជាសម្ដីម្ដាយខ្ញុំប្រាប់ទៅពួកគេ ពួកវានៅតែសម្លុតចេញទៅៗ ទោះជាម្ដាយខ្ញុំយំអង្វរដល់ពួកគេយ៉ាងណាក៏ដោយ។ ឪពុកខ្ញុំនៅតែមិនទាន់មកដល់ម្ដាយរង់ចាំយ៉ាងអន្ទះសាខ្វល់ខ្វាយ ណាមួយពួកគេកំពុងគំរាមទៀត។

ម្ដាយខ្ញុំអស់សង្ឃឹមថាបែកគ្នាពីឪពុកៗ និយាយអួលដើមក ទឹកភ្នែក



ទិដ្ឋភាព៖ ពួកទាហ៊ានខ្មែរក្រហមកំពុងតែភ្ជង់កាំភ្លើងទៅម្ដាយខ្ញុំ ដើម្បីឲ្យក្រុមគ្រួសារខ្ញុំចាកចេញពីទីក្រុងភ្នំពេញ ដែលម្ដាយនិងកូនៗរង់ចាំប្ដីនិងឪពុកយ៉ាងអន្ទះសារ។ (ឡុង វង្សសមិទ្ធ/សៀវភៅទូលពិយាដ)

រលីងរលោងប្រាប់បងវុឌ្ឍខ្ញុំថា "កូនវុឌ្ឍ ចូរកូនសរសេរក្រដាសបិទនឹងទ្វារផ្ទះ ដើម្បីឲ្យឪពុកដឹងថាកូនៗនិងម៉ាក់ចេញដំណើរទៅស្រុកកំណើតហើយ សូមប៉ាទៅតាមក្រោយចុះ ម៉ាក់ និងកូនៗមិនអាចចាំប៉ាបានទេ ព្រោះពួកទាហានរំដោះសម្លុតគំរាមបាញ់ បើចេញមិនទាន់ពេលវេលា"។

មិនទាន់សរសេរចប់ផង ខ្ញុំបានឃើញឪពុកគាត់រត់ពុះជ្រែកហ្វូងមនុស្សតាមផ្លូវ សម្លឹងមើលមកផ្ទះ មើលទៅគាត់ហត់ស្ទើរសន្ធប់ ហើយនិយាយទាំងដង្ហក់ថា "តស់ៗ ប្រញាប់ឡើង! រួចគាត់ញាត់កញ្ចប់ថ្នាំដាក់ក្នុងការុងចងនឹងចង្កើរម៉ូតូម៉ូបីឡែត មានអីវ៉ាន់សំពីងសំពោងទូលស្ពាយ ចេញដំណើរទៅ។

# អនិច្ចាខ្មែរ!
# ម្ចាស់ទូកដរព្រែកព្នៅ

តាមផ្លូវធ្វើដំណើរ ខ្ញុំឃើញតែប្រជាជនរែកទូលអីវ៉ាន់ព្រោងព្រាត មានកាំភ្លើងគេដាក់គរនៅមុខផ្ទះ ដោតនឹងទង់ជ័យសជាសញ្ញាចុះចាញ់។

ធ្វើដំណើរមកដល់ព្រែកព្នៅ មានទូកដកាណូតស្ពាបចក្រចំហៀង ប្រាំទៅប្រាំមួយគ្រឿង។ ម្ចាស់ទូកដទាំងនោះរត់មកប្រទាញប្រទុងដៃម្ដាយខ្ញុំ ហើយនិយាយថា៖ "ម៉ោះមីង! ឡើងកាណូតខ្ញុំមក មិនយកថ្លៃទេ" ម្ដាយខ្ញុំតប "ជិះគ្រាន់អត់ក្មួយ? មានគ្នាប្រាំបីនាក់"។ ម្ចាស់ទូកដប្រាប់ថា"បាន! មិនអីទេមីង"។ ម្ចាស់ទូកដបានលើកអីវ៉ាន់ដាក់ក្នុងទូកៗ ឪពុកនិងម្ដាយខ្ញុំបីប្អូនភ្លោះម្នាក់មួយ ចំណែកបងប្រុសស្រីខ្ញុំ និងប្អូនបានដើរលុយទឹកចូលទៅក្នុងទូកដ។ ម្ចាស់ទូកដចាប់ផ្ដើមបញ្ឆេះម៉ាស៊ីនចេញទៅ។

ទឹកប្រៀបគែមកាណូត ម្ដាយខ្ញុំទាញប្អូនភ្លោះមកឱបនឹងដើមទ្រូង ដូចមេមាន់ត្រដាងស្លាបក្រុងលើកូនជាម្លប់ៗ ម្ដាយខ្ញុំក្រឡេកមើលទឹករលកបោកផ្ទប់មកម្ដងៗស្ទើរលិចកាណូត ហើយបានពោលមកកូនៗថា"កូនៗនៅឲ្យស្ងៀមជិតដល់ត្រើយម្ខាងហើយ"។ អារម្មណ៍គាត់ពិតជាព្រួយខ្លាំងណាស់ ប្រសិនបើ កាណូតលិច កូនៗច្បាស់ជាលង់ស្លាប់មិនខាន។ មិនយូរប៉ុន្មានគាត់ក៏ទាញបាវមួយ ទម្លាក់ចូលទៅក្នុងទន្លេព្រុស្សូរប្រុង ឪពុកនិងកូនៗមើលមុខគ្នាងឿងឆ្ងល់។ គាត់ប្រាប់ម្ចាស់ទូកដថា "មិនអីទេក្មួយ បើកទៅមុខបន្តទៀតទៅ។ ពេលនោះ ទូកដូចជាងើបខ្ពស់បន្តិច ហើយ ទូកចាប់ផ្ដើមបន្ថយសំឡេងបានន័យថា ជិតដល់ត្រើយហើយ។

មកដល់យើងដើរឆ្លងទឹកមកច្រាំងទន្លេ រួចរាល់ម្ដាយខ្ញុំលូកយកលុយពីក្នុងបាវមួយបាច់ធំៗ ខ្ញុំមើលទៅក្រដាសលុយមានរូបខ្សែង ហុចទៅឲ្យម្ចាស់ទូកដ ហើយនិយាយថា "ក្មួយ ទុកចុះ" ម្ចាស់ទូកដមើលទៅរំភើបខ្លាំងណាស់មានទឹកភ្នែកស្រិចៗចេញមក

ផង ហើយនិយាយមកកាន់ម្ដាយខ្ញុំថា “អរគុណមីងច្រើនហើយ! ខ្ញុំមិនដែលបានកាន់លុយច្រើនដូច្នេះទេ” ហើយពោលមកកាន់ម្ដាយខ្ញុំបន្តថា “សូមគ្រួសារមីងធ្វើដំណើរឲ្យបានសុខសប្បាយ”។ ម្ដាយខ្ញុំតបថា “អរគុណហើយក្មួយ!”។

ពេលឆ្លងទូកដងទន្លេសាបព្រែកព្នៅ រួចយើងដើរកាត់ព្រៃកាត់វាលដេកក្នុងព្រៃមុខកំពូល។ ឃើញតែលេណដ្ឋានជាមួយសាកសពទាហានលន់ នល់ និងខ្មែរក្រហមអណ្ដែតក្នុងទន្លេ និងក្នុងព្រៃមុខកំពូលមានក្លិនស្អុយអសោច។

នៅពេលនោះឃើញមានប្រជាជនខ្លះ មានតែខ្លួន មិនមានអីវ៉ាន់នឹងគេទេ ដើរផងយំផង ងាកក្រោយរកមើលបងប្អូនក្រែងលោបានឃើញ។ ខ្លះទៀតពកូនខ្ចីដូចទើបឆ្លងទន្លេមានរុំកន្សែងនៅក្បាល ហើយដើរយឺតៗឱបកូនប្ដីជួយគ្រាទាំងមុខស្រពោនឯខ្លះទៀតមានរុំរបួសនឹងដៃព្យួរសេរ៉ូមជិះលើរទេះរុញ ដោយប្រពន្ធពកូនខ្ចីដូចទើបនឹងចេញពីមន្ទីរពេទ្យ។ ពេលនោះដែរខ្ញុំឃើញគេរោមមើលស្ត្រីម្នាក់កំពុងតែដេកលើស្មៅ ឈឺពោះឆ្លងទន្លេឃើញទារកសុទ្ធតែឈាមក្រហមរងាល។ ប៉ុណ្ណឹងហើយពួកខ្មែរក្រហមមកពីក្រោយស្រែកថាដើរទៅៗកុំនៅរេរាគួរឲ្យអាណោចអាធ័មជាទីបំផុត។

ពេលនោះរូបភាពសោកសង្រេងអ្វីក៏មានដែរម្នាក់ៗដើរទៅមុខមិនហ៊ានមាត់ព្រោះឃើញកងទ័ពបដិវត្តន៍កំពុងតែឈរភ្ជង់កាំភ្លើងមើលមកពួកយើង។

ការធ្វើដំណើរតាមផ្លូវមានតែពីរគ្រួសារទេ គឺគ្រួសារខ្ញុំ និងគ្រួសារពូហ៊ុល ដែលជាប្អូនបង្កើតឪពុកខ្ញុំ។

ធ្វើដំណើរមកដល់ភូមិរកាកោង ពួកខ្មែរក្រហមឲ្យពួកខ្ញុំឡើងជិះកប៉ាល់



ទិដ្ឋភាព៖ នៅតាមផ្លូវពេលជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញ ខ្ញុំឃើញទិដ្ឋភាពវេទនាជាច្រើន ក្នុងនោះមានស្ត្រីម្នាក់កំពុងឆ្លងទន្លេ ទារកឈាមក្រហមច្រាល។
(ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

ដើម្បីឆ្ពោះទៅស្រុកកំណើត។ នៅក្នុងកប៉ាល់មានមនុស្សច្រើនកកកុញ។ គ្រួសារខ្ញុំគេឲ្យឡើងជិះនៅលើដំបូល។ ខ្ញុំសង្កេតឃើញឪពុកម្ដាយបានរៀបចំដំបាយ លើដំបូលកប៉ាល់ហើយដួសឲ្យកូនៗហូបស្រោចនឹងទឹកស៊ីអ៊ីវ។ ធ្វើដំណើរពេលយប់ អាកាសធាតុត្រជាក់ដោយទឹកសន្សើមម្ដាយបានយកភួយមកដណ្ដប់ឲ្យកូនៗ ដែលដេកតម្រៀបជួរគ្នា។

ខ្ញុំដេកមើលទៅលើឃើញព្រះចន្ទ្រាខែខ្នើត កំពុងបណ្ដើរតារាព្រោងព្រាត មិនខុសពីឪពុកម្ដាយកំពុងមើលថែកូនៗនោះដែរ។ ផ្ទៃទឹករលកបោកនឹងកប៉ាល់បែកផ្កាត្រែងនិងផ្សែងបំពង់ស៊ីម៉ាំងហុយទ្រលោមឡើងលើ។ ឪពុកនិងម្ដាយអង្គុយត្របោមក្បាលជង្គង់ទំពាបាយមួយៗ មើលមកកូនដេករហង់ តម្រង់ទិសទៅរកអ្វីដែលមិនអាចទស្សន៍ទាយបាន តើវាសនាជីវិតទៅជាយ៉ាងណា?។

ព្រលឹមស្រាងៗថ្ងៃអើតលឹមៗ កប៉ាល់ចាប់ផ្ដើមស៊ីផ្លេ និងបន្ថយសំឡេង ហើយងាកក្បាលបុកច្រាំងទន្លេ។ ឪពុកម្ដាយដាស់កូនៗឲ្យងើបឡើងរៀបចំអីវ៉ាន់ ហើយពោលថា “យើងដល់ភូមិព្រែកពោធិ៍ហើយ”។

# ទប្បធម៌បញ្ច្រាសទិសនៃបដិវត្តន៍ អ្នកក្រុងចូលស្រែ

**ស្រុកស្រីសន្ធរ ឃុំទូរី វត្តព្រៃពោធិមណ្ឌល**

បន្ទាប់ពីឡើងគោករួច ពួកខ្មែរក្រហមឲ្យអ្នក១៧ មេសា ប្រមូលផ្តុំគ្នានៅវត្តព្រែកពោធិមណ្ឌល ភូមិព្រែកពោធិ ឃុំទូរី ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ហើយប្រជុំណែនាំ អ្នកក្រុងចូលស្រែឲ្យដឹងពីច្បាប់អង្គការៗ រួចគេបែងចែកទៅតាមភូមិនីមួយៗដែលអង្គការកំណត់។

សម្ភារៈ របស់របរដែលនាំទៅជាមួយត្រូវគេដកហូតដូចជា កង់ ម៉ូតូ នាឡិកា ស្បែកជើង គ្រឿងអលង្ការ លុយកាក់ ។ល។ ដោយពោលថា អង្គការយើងមិនត្រូវការរបស់ពួកចក្រពត្តិមូលធននិយមទេ យើងត្រូវការតែប្រជាជនបដិវត្តន៍ស្អាតស្អំ។ ម៉ូតូម៉ូមីឡូតឪពុកខ្ញុំនិងលុយកាក់ត្រូវបានគេដកហូតអស់នៅសល់មាសជាខ្សែក និងគ្រឿងប្រាក់បន្តិចបន្តួចដែលម្តាយខ្ញុំលួចលាក់ទុក។

គេដឹកគ្រួសារខ្ញុំតាមរទេះសេះ រទេះគោ ឆ្លងកាត់ភូមិប្រាមយ៉ាម ហើយបន្តឆ្លងដងទន្លេតូច ដោយក្បូនប្ញស្សី ទើបយើងមកដល់ភូមិយោគ ដែលជាភូមិកំណើតឪពុកខ្ញុំ។ យើងស្នាក់នៅទីនោះមួយយប់។ ស្អែកឡើងបានបន្តដំណើរដោយថ្មើរជើងតាមទំនប់ប្រកតន្ទ្រីទួលសំរោងទង ដើម្បីមករស់នៅភូមិកំណើត គឺភូមិក្រាំងនេះឯង។

ពេលមកដល់ភូមិក្រាំង អ្នកភូមិជិតឆ្ងាយមកទទួលសាទរ និងក្តីនឹករលឹកដល់ឪពុកម្តាយខ្ញុំ ដែលបានបែកចេញពីភូមិ ជាយូរខែឆ្នាំ។ អ្នកភូមិខ្លះបានកាប់ផ្លែដូងហុចឲ្យគ្រួសារខ្ញុំម្នាក់មួយៗ ដូចជា ការដឹងគុណដល់ឪពុកខ្ញុំ។

មិនបានប៉ុន្មានថ្ងៃផង កម្មាភិបាលបានឲ្យអ្នកថ្មីទាំងអស់យកសម្លៀកបំពាក់ទាំងប៉ុន្មានជ្រលក់មក្លឿឲ្យទៅជាពណ៌ខ្មៅ និងបែងចែកឲ្យប្រជាជនមូលដ្ឋានខ្លះ ហើយប្រមូលអ្នក១៧ មេសា មកអប់រំទាំងអស់ឲ្យឈប់ប្រើពាក្យប៉ាម៉ាក់ កុងម៉ា គូអ៊ី កូវសោ ។ល។ ព្រោះពាក្យនេះជាពាក្យពួកសក្តិភូមិ ត្រូវហៅថា ពុក ឪ ម៉ែ តា យាយ ពូមីង។ គេហៅអ្នក ១៧ មេសា ថា ជាប្រជាជនថ្មី។

គេបែងចែកប្រជាជនថ្មីនីមួយៗទាំងអស់ឲ្យទៅរស់នៅតាមផ្ទះ និងធ្វើការជាមួយប្រជាជនចាស់តាមសហករណ៍ប្រវាស់ដៃដើម្បីឲ្យស្គាល់របៀបរបបរស់នៅ ដូចប្រជាជនមូលដ្ឋាន។ រស់នៅតាមសហករណ៍ប្រវាស់ដៃបានប៉ុន្មានខែ គេបានប្រមូលប្រជាជនទាំងអស់ឲ្យមកហូបបាយរួមគ្នាក្នុងសហករណ៍ភូមិវិញ។

ច្រើនខែក្រោយមក គេបានជម្លៀសអ្នកថ្មីទាំងអស់ដែលរស់នៅភូមិក្រាំង រួមទាំងគ្រួសារខ្ញុំផង ឲ្យទៅនៅភូមិព្រៃក្រឡាញ់តូច និងភូមិព្រៃក្រឡាញ់ធំ។

---

# អ្នកភូមិព្រៃក្រឡាញ់ធំចិត្តធម៌ កងចល័តកុមារ

ពេលមករស់នៅក្នុងភូមិព្រៃក្រឡាញ់ធំ ពួកកម្មាភិបាលបដិវត្តន៍បានឲ្យគ្រួសារខ្ញុំនៅផ្ទះតូចមួយក្បែរផ្លូវរទេះមានអណ្តូងមួយនៅក្បែរនោះ ដែលជាផ្ទះតាអ៊ុំ យាយផាត អ្នកមូលដ្ឋាន។ ដោយមានការរាប់អានរាក់ទាក់យ៉ាងល្អពីសំណាក់អ្នកភូមិព្រោះគេស្គាល់ឪពុកខ្ញុំច្បាស់ជាគ្រូបង្រៀនធ្លាប់មកបង្រៀនកូនអ្នកស្រុកនៅក្នុងភូមិនេះ។

គេចាត់តាំងឲ្យឪពុកម្តាយខ្ញុំជួយធ្វើស្រែ បងស្រី និងខ្ញុំឲ្យចាំក្របី ប្អូនៗឲ្យចាំគោ។

ថ្ងៃណាក៏ដូចថ្ងៃណាដែរ ព្រឹកព្រលឹមខ្ញុំតែងតែទៅសាលារៀនយកចបកាប់ និងបង្គីទៅកាប់ដីដាក់តាមផ្លូវតាមការបញ្ជារបស់មេកងកុមារ និងធ្វើថ្នាលសម្រាប់កុមារតូចៗ បត់ជើងធំ និងប្រមូលដាក់ក្នុងរណ្តៅមួយដែលគេហៅថា "ជីលេខ១" ។ ពេលថ្ងៃ

(តនៅលេខក្រោយ)

**ឡុង ទឡ្ហសមិទ្ធ**

*រូបក្របមុខ៖*

*កម្មាភិបាលខ្មែរក្រហមចូលរួមវគ្គរៀនសូត្រអំពីមាគ៌ារបស់បក្ស*
*នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*រូបក្របក្រោយ៖*

*នារីកម្មករបដិវត្តន៍នៅរោងចក្រផលិតកៅស៊ូក្រែប នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*
*(ពីឆ្នាំ១៩៧៥-១៩៧៩)*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 272, August 2022 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.